

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

ការគ្រប់គ្រងឥណទានខ្លាតភ្លូច

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាធី**

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ហ៊ុយ ឆុចលីម**

ថៅ ស្រីនិច

សាស្ត្រាចារ្យណែនាំ

លោក **ង្រុំ សុគុណ**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ ជំនាន់ទី ១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេររបាយការណ៍ ២០១៧

សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ហ៊ុយ វុចលីម** និង **ថៅ ស្រីនិច** ជានិស្សិតជំនាន់ទី ១០ បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៣-២០១៧ ។

ខ្ញុំសូមគោរពប្រណិបត្តិយ៉ាងខ្ពង់ខ្ពស់ និងកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះ

លោកឪពុក អ្នកម្តាយ ដែលលោកទាំងពីរ បានផ្តល់កំណើតដល់រូបកូន និងខិតខំប្រឹងប្រែងតស៊ូ ចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងផ្តល់ដំបូន្មានប្រៀនប្រដៅដល់កូនដោយក្តីស្រលាញ់មេត្តា ព្រមទាំងផ្តល់កម្លាំងចិត្ត និងការផ្គត់ផ្គង់ការសិក្សាចាប់ពីថ្នាក់តូចរហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រដែលជាគោលបំណងរបស់កូនជាស្ថាពរ ។ គុណបំណាច់ដ៏ធំធេងនេះធ្វើឲ្យរូបកូនមិនអាចបំភ្លេចបានឡើង ហើយកូនសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកតាមថែរក្សា និងប្រសិទ្ធិពរជ័យសិរីបវរជូនដល់លោកទាំងពីរឲ្យ ជួបតែសេចក្តីសុខ សេចក្តីចម្រើន មានកម្លាំងមាំមួន និងឈ្នះរាល់ឧបសគ្គដើម្បីជាម្លប់ដល់កូនចៅជានិរន្តតរៀងទៅ ។

ឯកឧត្តមសាកលវិទ្យាធិកា លោកសាកលវិទ្យាធិការង ប្រធានការិយាល័យស្រាវជ្រាវ លោក លោកស្រី សាស្ត្រចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្ទេរចំណេះដឹង រួមទាំងបទពិសោធន៍ល្អៗ ដល់យើងទាំងអស់គ្នា ។

លោកសាស្ត្រាចារ្យ **ព្រុំ សុគុណ** ដែលបានជួយណែនាំ និងផ្តល់នៅយោបល់ល្អៗ ព្រមទាំងជួយណែនាំរូបខ្ញុំទាំងពីរនាក់ ឲ្យមកដល់ចំណុចជោគជ័យនៃការរៀបចំរបាយការណ៍កម្មសិក្សានេះឡើង ។

សូមថ្លែងអំណរអរគុណចំពោះ លោកអគ្គនាយកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលបានអនុញ្ញាតឲ្យរូបខ្ញុំទាំងពីរនាក់បានចុះកម្មសិក្សាស្រាវជ្រាវ ។

សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះលោកប្រធាន **ដួង សុខ** និងអនុប្រធាន សាខាបាទី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយបង្ហាត់បង្ហាញ និងការផ្តល់នូវភាពងាយស្រួលក្នុងការចុះកម្មសិក្សានេះ ។

មិត្តភក្តិទាំងអស់គ្នា ដែលបានគាំទ្រ លើកទឹកចិត្ត ផ្តល់កម្លាំងចិត្ត និងផ្តល់គំនិតល្អៗដល់រូបយើងខ្ញុំ ។

ជាទីបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យ ដល់លោកឪពុក អ្នកម្តាយ លោកសាកលវិទ្យាធិការ លោកសាស្ត្រាចារ្យ លោកប្រធាន និងបុគ្គលិកទាំងអស់ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ព្រមទាំងមិត្តភក្តិអស់គ្នា សូមជូនពរឲ្យមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ។

អារម្ភកថា

វិស័យធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជាមានការរីកចម្រើន ដុះដាលគួរឲ្យកត់សំគាល់ និងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រមទាំងបានចូលរួមចំណែកនូវការកាត់បន្ថយភាពក្រីក្របានមួយចំណែកផងដែរ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទីជាគ្រឹះស្ថានដែលចាប់បើកប្រតិបត្តិការអាជីវកម្មតាំងពីឆ្នាំ ១៩៩៦ មកម្លេះ ហើយនៅបច្ចុប្បន្ននេះគ្រឹះស្ថានផ្តល់នៅសេវា និងផលិតផលជាច្រើនដល់អតិថិជនដូចជាសេវាឥណទាន (ឥណទានក្រុមធានា ឥណទានបុគ្គល ឥណទានសម្ភារប្រើប្រាស់ ឥណទានកែលម្អគេហដ្ឋាន ឥណទានអាជីវកម្ម ឥណទានឡជីវឧស្ម័ន ឥណទានក្រុមឯករាជ្យ) សេវាផ្ទេរប្រាក់ និងសេវាប្រាក់បញ្ញើរ (គណនីរីករាយ គណនីប្រាថ្នា គណនីកើនទ្រព្យ គណនីពាណិជ្ជ) ។ ម៉្យាងទៀតឥណទានជាប្រភពមួយក្នុងចំណោមសេវាកម្ម និងផលិតផលទាំងនោះដែលជាចំណូលយ៉ាងសំខាន់ចំពោះស្ថាប័ន វាទាមទារឲ្យមានការគ្រប់គ្រងឲ្យមានប្រសិទ្ធភាព បើមិនដូច្នេះទេវានឹងនាំឲ្យមានបញ្ហាដល់ស្ថាប័ន និងសេដ្ឋកិច្ចជាតិ ។ ការសិក្សាស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើការគ្រប់គ្រងឥណទានខ្នាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី ដែលនឹងធ្វើការបកស្រាយលំអិតអំពីការគ្រប់គ្រងឥណទាន មុនពេលបញ្ចេញទុន ពេលបញ្ចេញទុន ក្រោយពេលបញ្ចេញទុន និងការដោះស្រាយបំណុលដែលកើតឡើង ព្រមទាំងបង្ហាញពីប្រសិទ្ធិភាពនៃការគ្រប់គ្រងឥណទានពីឆ្នាំ ២០១៤-២០១៥ ផងដែរ ។ ទោះបី ជាការរៀបចំរបាយការណ៍មួយនេះមានលក្ខណៈ យកចិត្តទុកដាក់ខ្លាំងយ៉ាងណាក្តី ក៏នៅតែអាចមានចំណុចខ្វះខាតដោយប្រការណាមួយដោយចេតនា ។ យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងពាក្យពេជ្រ អក្ខរាវិរុទ្ធ នឹងខ្លឹមសារ ហើយយើងខ្ញុំរងចាំទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីឲ្យរបាយការណ៍កម្មសិក្សានេះកាន់តែមានភាពប្រសើរឡើង ។

ជាទីបញ្ចប់យើងខ្ញុំសង្ឃឹមថារបាយការណ៍បញ្ចប់ការសិក្សាមួយនេះ និងអាចក្លាយជាអត្ថបទស្រាវជ្រាវដែលអាចអោយយើងស្វែងយល់កាន់តែច្បាស់ពីដំណើរការផ្តល់ឥណទាន និងដើម្បីជាប្រភពពត៌មាន ឬក៏ជាទិន្នន័យដែលអាចឲ្យនិស្សិតជំនាន់ក្រោយយកទៅធ្វើការប្រើប្រាស់ និងអ្នកដែលពាក់ព័ន្ធនៅក្នុងវិស័យនេះធ្វើការស្វែងយល់ឲ្យកាន់តែច្បាស់លាស់ជាងនេះ។

មាតិកា

បញ្ជីអក្សរកាត់ vi

បញ្ជីតារាង vii

បញ្ជីរូប vii

បញ្ជីដ្យាក្រាម vii

សេចក្តីផ្តើម

១. លំនាំបញ្ហា ១

២. ចំណោទបញ្ហា ២

៣. ទំហំ និងដែនកំណត់ ២

៤. គោលបំណងនៃការស្រាវជ្រាវ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៣

ជំពូកទី ១

រំលឹកឡើងវិញ

១.១ ទស្សនៈទូទៅនៃឥណទាន ៦

១.១.១ និយមន័យឥណទាន ៦

១.១.២ គោលបំណងនៃការផ្តល់ឥណទាន ៦

១.១.៣ មុខងារឥណទាន ៦

១.១.៤ ប្រភេទឥណទាន ៧

១.១.៥ សមាសភាគនៃដំណើរការឥណទាន ៩

១.២ ដំណើរការនៃការគ្រប់គ្រងឥណទាន ១០

១.២.១ ការលើកទឹកចិត្ត ១០

១.២.២ ការពិនិត្យសំណើរសុំលើកដំបូង ១០

១.២.៣ ការស៊ើបអង្កេតឥណទាន.....១០
១.២.៤ ការសម្រេចចិត្តផ្តល់ឥណទាន.....១១
១.២.៥ ការត្រួតពិនិត្យគណនី.....១១
១.២.៦ ការប្រមូល.....១១
១.៣ ការគណនាការប្រាក់.....១១
១.៣.១ ការប្រាក់ទោល.....១១
១.៣.២ ការប្រាក់សមាស.....១២
១.៤ ការវាយតម្លៃក្នុងការផ្តល់ឥណទាន.....១៣
១.៤.១ ចរិកលក្ខណៈ (character).....១៣
១.៤.២ សមត្ថភាព (Capacity).....១៤
១.៤.៣ ដើមទុន (Capital).....១៤
១.៤.៤ វត្ថុបញ្ចាំ (Collateral).....១៤
១.៤.៥ លក្ខខ័ណ្ឌ (Condition).....១៤
១.៤.៦ សុភវិនិច្ឆ័យ (Common Sense).....១៥
១.៤.៧ សារៈសំខាន់នៃ C′ s សំរាប់ការវិភាគឥណទាន.....១៥
១.៥ លក្ខណៈទូទៅនៃហានិភ័យឥណទាន.....១៥
១.៥.១ និយមន័យ.....១៥
១.៥.២ កត្តាដែលបង្កឲ្យមានហានិភ័យឥណទាន.....១៦
១.៥.៣ វិធីសាស្ត្រទប់ស្កាត់ហានិភ័យឥណទាន.....១៧
១.៥.៤ ករណីឥណទានមានបញ្ហា.....១៧
១.៥.៥ យុទ្ធសាស្ត្រដោះស្រាយបំណុលមានបញ្ហា.....១៨
១.៦ តួនាទី និងអត្ថប្រយោជន៍ឥណទាន.....១៩
១.៦.១ តួនាទីឥណទានក្នុងសេដ្ឋកិច្ច.....១៩
១.៦.២ អត្ថប្រយោជន៍ចំពោះអ្នកខ្ចីឥណទាន.....២០
១.៦.៣ អត្ថប្រយោជន៍ចំពោះធនាគារ.....២០

១.៦.៤ អត្ថប្រយោជន៍ចំពោះសង្គម ២១

ជំពូកទី ២

ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី

២.១ ជីវប្រវត្តិ និងរបត់នៃការរីកចម្រើនរបស់អម្រឹត ២២
២.២ ជីវប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាទី ២៣
២.៣ ទីស្នាក់ការកណ្តាលរបស់អម្រឹត ២៣
២.៤ អត្តសញ្ញាណ និងអត្ថន័យនៃឈ្មោះ បាវចនា និងផ្លាកសញ្ញា ២៤
២.៥ ទីតាំងភូមិសាស្ត្រ និងតំបន់ប្រតិបត្តិការរបស់អម្រឹតសាខាបាទី ២៥
២.៦ ទស្សន: និងបេសកកម្មរបស់ អម្រឹត ២៥
២.៧ រប្បធម្មរបស់អម្រឹត ២៦
២.៨ រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី ២៧
២.៩ ផលិតផល និងសេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី ២៨

ជំពូកទី ៣

ការគ្រប់គ្រងឥណទានខ្នាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី

៣.១ លក្ខណៈទូទៅនៃឥណទានខ្នាតតូច ៣០
៣.១.១ និយមន័យ ៣០
៣.១.២ ទំហំ និងអត្រាការប្រាក់ ៣០
៣.១.២.១ ឥណទានក្រុមធានា SC (Solidarity Credit) ៣០
៣.១.២.២ ឥណទានបុគ្គល IC (Individual Credit) ៣០
៣.១.៣ គោលបំណងនៃការផ្តល់ឥណទានខ្នាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ៣២
៣.២ គោលការណ៍ឥណទាន ៣២
៣.២.១ គោលការណ៍ឥណទានក្រុមធានា SC (Solidarity Credit) ៣២
៣.២.២ គោលការណ៍ឥណទានបុគ្គល IC (Indivindual Credit) ៣៤
៣.៣ សកម្មភាពអនុវត្តន៍ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ៣៤
៣.៣.១ សកម្មភាពមុនពេលទំលាក់ទុន ៣៤
៣.៣.១.១ ឥណទានក្រុមធានា ៣៥

៣.៣.១.២ ឥណទានបុគ្គល ៣៨
៣.៣.២ សកម្មភាពពេលទំលាក់ទុន ៤០
៣.៣.២.១ ឥណទានក្រុមធានា ៤០
៣.៣.២.២ ឥណទានបុគ្គល ៤១
៣.៣.៣ សកម្មភាពក្រោយពេលទំលាក់ទុន ៤២
៣.៣.៣.១ ឥណទានក្រុមធានា ៤២
៣.៣.៣.២ ឥណទានបុគ្គល ៤៤
៣.៤ លក្ខខ័ណ្ឌក្នុងការសង ៤៥
៣.៤.១ ឥណទានក្រុមធានា ៤៥
៣.៤.២ ឥណទានបុគ្គល ៤៥
៣.៥ វិធីសាស្ត្រនៃការគណនាការប្រាក់ និងប្រាក់ដើមត្រូវសង ៤៦
៣.៥.១ ការគណនាការប្រាក់ ៤៧
៣.៥.២ ការគណនាការប្រាក់បន្តលើបំណុលខកខានមិនបានសង ៤៧
៣.៥.៣ ការពន្យាពេលសងប្រាក់ ៤៨
៣.៦ ការជាកពិន័យ និងការលុបចោលប្រាក់ពិន័យ ៤៨
៣.៦.១ ការពិន័យ ៤៨
៣.៦.២ ការលុបបំណុលបាត់បង់ ៤៩
៣.៧ ហានិភ័យឥណទានដែលធ្លាប់ជួបប្រទះ ៤៩
៣.៨ យុទ្ធសាស្ត្រក្នុងការទប់ស្កាត់ហានិភ័យ ៥០
៣.៩ នីតិវិធីដោះស្រាយបញ្ហាពេលជួបហានិភ័យ ៥១
៣.៩.១ ឥណទានបុគ្គល ៥១
៣.៩.២ ឥណទានក្រុមធានា ៥២
៣.១០ លទ្ធផលនៃការស្រាវជ្រាវ ៥៣
៣.១០.១ សមតុល្យឥណទានខ្ជាតតូចពីឆ្នាំ ២០១៤-២០១៦ ..... ៥៣
៣.១០.២ សមតុល្យឥណទានខ្ជាតតូចដែលសងយឺត ២០១៤-២០១៦ ..... ៥៤
៣.១០.៣ សមតុល្យឥណទានដែលលុបចេញពីបញ្ជី ២០១៤-២០១៦ ..... ៥៥

៣.១១ ការសិក្សាទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ អម្រឹតសាខាបាទី ៥៧
៣.១១.១ ចំណុចខ្លាំងរបស់អម្រឹត ៥៧
៣.១១.២ ចំណុចខ្សោយរបស់អម្រឹត ៥៧

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ៥៨
២. អនុសាសន៍ ៥៩

ឯកសារយោង

ឧបសម្ព័ន្ធ

បញ្ជីអក្សរកាត់

AFD	Accelerated freez dried
GRET	Group de Recherache et d'Echanges Technologiue
IC	Individual Credit
LFP	La Fayette Participation
PROOARCO	Economique (Promotion and Participation in Economic Cooperate Company)
SC	Solidarity Credit
SIDI	Soiete d'Investment et de development International (International Investment and Delopment Company)

បញ្ជីតារាង

- តារាងទី១៖ សមតុល្យឥណទានសរុប ៥៣
- តារាងទី២៖ សមតុល្យឥណទានដែលសងយឺត (PAR > 30 days) ៥៤
- តារាងទី៣៖ សមតុល្យឥណទានដែលលុបចេញពីបញ្ជី (Write off) ៥៥

បញ្ជីរូប

- រូបសញ្ញារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ២៤
- ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី ២៥

បញ្ជីដ្យាក្រាម

- ក្រាបដ្យាក្រាមសមតុល្យឥណទានសរុប ៥៣
- ដ្យាក្រាមសមតុល្យឥណទានដែលសងយឺត (PAR > 30 days) ៥៤
- ដ្យាក្រាមសមតុល្យឥណទានដែលលុបចេញពីបញ្ជី (Write off) ៥៥

សេចក្តីផ្តើម

សេចក្តីផ្តើម

១. លំនាំបញ្ហា

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលប្រកាន់ភ្ជាប់គោលនយោបាយ ទីផ្សារសេរី ដែលកំពុងមានការរីកចម្រើនស្ទើរគ្រប់វិស័យ ហើយជាពិសេស វិស័យធនាគារ គឺមានការរីកចម្រើនយ៉ាងឆាប់រហ័សដោយផលិតផល និងសេវាកម្មមួយចំនួនកំពុងផ្តល់នូវ **សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ សេវាប្តូរប្រាក់ និងការផ្តល់សេវាឥណទាន** ទៅឲ្យអតិថិជន ដើម្បីបំពេញតម្រូវការរបស់ពួកគាត់ ។

បច្ចុប្បន្ននេះយើងសង្កេតឃើញថាមានស្ថាប័នហិរញ្ញ ជាច្រើនរួមទាំងស្ថាប័នជាតិ និងអន្តរជាតិកំពុងរួមចំណែកក្នុងការបម្រើសេវាកម្ម ដែលកំពុងមានការប្រកួតប្រជែងគ្នាយ៉ាងខ្លាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចជា៖ ធនាគារ អេស៊ីលីដា ភីអិលស៊ី,ធនាគារ ហត្ថាកសិករ លីមីតធីត, ធនាគារ ស្តាបនា លីមីតធីត, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ ជាដើម ។ ដោយផ្តោតទៅលើការធ្វើប្រតិបត្តិការឥណទានរបស់ខ្លួនជារៀងរាល់ថ្ងៃ តាមបណ្តា ខេត្ត-ក្រុង នានាទូទាំងប្រទេសកម្ពុជា ។

ជាមួយគ្នានេះដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលជាគ្រឹះស្ថាននាំមុខគេនៅប្រទេសកម្ពុជា ដែលបានចាប់ផ្តើមអាជីវកម្មរបស់ខ្លួនចាប់តាំងពីឆ្នាំ ១៩៩១មកម្លេះ ។ ហើយបច្ចុប្បន្ននេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតបានពង្រីកសាខារបស់ខ្លួនជាច្រើននៅតាមបណ្តា ខេត្ត-ក្រុង ដើម្បីចូលរួមចំណែកក្នុងការផ្តល់ឥណទានផ្នែកហិរញ្ញវត្ថុ ដល់ប្រជាជន តំបន់ដាច់ ស្រយាល អាជីវកម្មខ្នាតតូច មធ្យម ឬក៏អ្នកមានគោលបំណងចង់បើក ឬពង្រីកអាជីវកម្មរបស់ខ្លួនជាដើម ក្នុងគោលបំណងជួយសម្រួលដល់កម្រិតជីវភាពរបស់ប្រជាជនដែលរស់នៅតាមជនបទ ។ អម្រឹត អាចដំណើរការទៅបានក៏ដោយសារតែមានការជឿទុកចិត្ត និងគាំទ្រពីសំណាក់អតិថិជនទាំងឡាយដែលបានប្រើប្រាស់ សេវាឥណទាន សេវាប្រាក់សន្សំ សេវាផ្ទេរប្រាក់ជាដើម ដោយគ្រឹះស្ថានយកប្រាក់ដែលអតិថិជនបានផ្ទើរនោះ ទៅវិនិយោគបន្តទៀត តាមរយៈការផ្តល់ឥណទានដោយយកការប្រាក់សមរម្យ ។

ដោយសង្កេតឃើញថា សេវាកម្មឥណទានជា សេវាកម្មមួយដែលឈានមុខគេក្នុងសេវាកម្មទាំង បី របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត និងមានភាពទូលំទូលាយផងនោះ ដូច្នេះហើយទើបធ្វើឲ្យយើងខ្ញុំទាំងពីរនាក់ជ្រើសរើសយកប្រធានបទដែលទាក់ទងនឹង " ការគ្រប់គ្រងឥណទានខ្នាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត " មកធ្វើការសិក្សាស្រាវជ្រាវ ។

២. ចំណោទបញ្ហា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតមានផលិតផលឥណទាន និងសេវាកម្មជាច្រើនប្រភេទ សម្រាប់បំពេញទៅតាមតម្រូវការរបស់អតិថិជន ។ ឥណទានបានផ្តល់នូវប្រភពចំណូលយ៉ាងធំ ចំពោះគ្រឹះស្ថាន អតិថិជន និងសេដ្ឋកិច្ចជាតិ ប៉ុន្តែបើគ្រប់គ្រងមិនល្អទេវានឹងជះឥទ្ធិពលអាក្រក់ផងដែរ ។ ដូច្នេះហើយទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ ដើម្បីធ្វើការសិក្សាស្វែងយល់ថា

- តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី មានការគ្រប់គ្រងឥណទានយ៉ាងដូចម្តេចដែរ?
- តើគ្រឹះស្ថានដោះស្រាយបំណុលមានបញ្ហាយ៉ាងដូចម្តេច ?
- តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតមានភាពខ្លាំង និងភាពខ្សោយយ៉ាងណាខ្លះក្នុងការផ្តល់ឥណទានរបស់ខ្លួន ?

៣. ទំហំ និងដែនកំណត់

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទីមានសេវាកម្មជាច្រើន ក៏ប៉ុន្តែនៅក្នុងការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើ ការគ្រប់គ្រងឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ទាំងឥណទានក្រុមធានា និងឥណទានបុគ្គលដែលធ្វើការសង្កត់ធ្ងន់ទៅលើសកម្មភាព ៣ យ៉ាងគឺ សកម្មភាពមុនពេលទំលាក់ទុន សកម្មភាពពេលទំលាក់ទុន សកម្មភាពក្រោយពេលទំលាក់ទុន ព្រមទាំងនីតិវិធី និងលក្ខខ័ណ្ឌ ខ្វី-សងមួយចំនួនទៀត ។ ម៉្យាងទៀត ដើម្បីវាស់វែងពីប្រសិទ្ធិភាពនៃការផ្តល់ឥណទាន ទិន្នន័យពីឆ្នាំ ២០១៤- ២០១៦ ដែលត្រូវប្រមូលយកមកវិភាគ ។

៤. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវ គឺដើម្បីស្វែងយល់ពីការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ។ ហើយកម្មវត្ថុនៃការសិក្សានេះ ទាក់ទងនឹងចំណុចសំខាន់ៗមួយចំនួន៖

- ស្វែងយល់ពីស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត
- ពិនិត្យពីនីតិវិធី និងការគ្រប់គ្រងឥណទានខ្នាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត
- ស្វែងយល់ពីដំណោះស្រាយចំពោះឥណទានមានបញ្ហា
- យល់ដឹងអំពីភាពខ្លាំង និងភាពខ្សោយនៃប្រតិបត្តិការ ផ្តល់កម្ចីខ្នាតតូចរបស់គ្រឹះ

ស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី ។

៥. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការស្រាវជ្រាវនេះ យើងខ្ញុំសង្ឃឹមថាឯកសារនេះ នឹងចូលរួមចំណែកផ្តល់ចំណេះដឹង ក្នុងការផ្សារភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ហើយជាពិសេសចំពោះនិស្សិតដែលចង់ស្វែងយល់ពីឥណទានអាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ។ ម៉្យាងទៀតវាក៏ជាឯកសារសម្រាប់អ្នកស្រាវជ្រាវបន្ត និងជាពត៌មានដែលឆ្លុះបញ្ចាំងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់គ្រឹះស្ថាន ។

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលបានទិន្នន័យមួយដែលមានលក្ខណៈពេញលេញ និងមានភាពច្បាស់លាស់ក្រុមនាងខ្ញុំបានប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវ ពីរគឺ៖

- **ទិន្នន័យចំបង**

ប្រភពទិន្នន័យចំបងៗ ដែលយើងទទួលបានដែលទាក់ទងទៅនឹងការនៃការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតគឺ៖

- ការជួបសម្ភាសន៍ផ្ទាល់ជាមួយនឹងភ្នាក់ងារឥណទាន
- ជួបសម្ភាសន៍ជាមួយនឹងអនុប្រធាន ប្រធានសាខាស្រុក ការគ្រប់គ្រងឥណទាន។

- **ទិន្នន័យបន្ទាប់បន្សំ**

ទិន្នន័យបន្ទាប់បន្សំ ជាទិន្នន័យដែលមានស្រាប់ ដូចជាឯកសារមួយចំនួនដែលបានមកពីគ្រឹះស្ថានដែលទាក់ទងទៅនឹងការអនុវត្តការគ្រប់គ្រងឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី ។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសរសេររបាយការណ៍កម្មសិក្សានេះត្រូវបែងចែកជា បីជំពូកធំៗ គឺ៖

- **សេចក្តីផ្តើម**
- **ជំពូកទី១: ការរំលឹកទ្រឹស្តី**

នៅក្នុងជំពូកនេះដែរយើងត្រូវរំលឹកឡើងវិញនៅទ្រឹស្តីមួយចំនួន ដែលទាក់ទងនឹងឥណទាន ដូចជា និយមន័យ គោលបំណង មុខងារ តួនាទី ដំណើរការឥណទាន ទ្រឹស្តី (C's) ដែលជាចំណុចសំខាន់ដែលត្រូវវិភាគ ។

❖ **ជំពូកទី២: ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី**

ក្នុងជំពូកទី២នេះ គឺបង្ហាញទៅលើស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាទី កំឡុងពេលដែលចុះកម្មសិក្សាដែលរួមមាន ទីតាំងពីប្រវត្តិ ទីតាំងសាខា និមិត្តសញ្ញា អត្ថន័យនៃឈ្មោះ ពណ៌ នៅលើផ្លាកសញ្ញា ខ្លឹមសារ នៃវប្បធម៌រួម បេសកកម្ម ទស្សនៈវិស័យ ព្រម ទាំងទីផ្សារគោលដៅទៀតផង ។

❖ **ជំពូកទី៣: ការគ្រប់គ្រងឥណទានខ្នាតតូចរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាបាទី**

នៅក្នុងជំពូកនេះ គឺជាគោលបំណងមួយដ៏ធំក្នុងការសិក្សាស្រាវជ្រាវទៅលើ ដំណើរការនៃ ការផ្តល់ឥណទានខ្នាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទីដែលកំពុងតែអនុវត្តន៍ ។ និងការសិក្សាវែកញែកទៅលើភាពខ្លាំង និងភាពខ្សោយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខា បាទីបន្ទាប់ពីចុះកម្មសិក្សារួច ដើម្បីបន្តឈានដល់ការធ្វើសេចក្តីសន្និដ្ឋាន ។

❖ **សេចក្តីសន្និដ្ឋាន និង អនុសាសន៍**

ការសន្និដ្ឋាន គឺផ្តោតសំខាន់ ទៅលើភាពខ្លាំង និង ភាពខ្សោយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី ក៏ដូចជាការផ្តល់នូវអនុសាសន៍ខ្លះៗ ទាក់ទងទៅនឹងអ្វីដែលជាចំណុចខ្វះខាត ។

គំនូសបំព្រួញរចនាសម្ព័ន្ធនៃការស្រាវជ្រាវ



ជំពូក១

រំលឹកទ្រឹស្តី

ជំពូកទី១
រំលឹកទ្រឹស្តី

១.១ ទស្សនៈទូទៅនៃឥណទាន

១.១.១ និយមន័យឥណទាន

ឥណទាន គឺជាការផ្តល់កម្ចីដល់សាធារណៈជនក្នុងរយៈពេលជាក់លាក់ណាមួយ និងប្រមូលត្រឡប់មកវិញទាំងប្រាក់ដើម និងការប្រាក់តាមកិច្ចសន្យាដែលបានកំណត់ ។[1]

ឥណទាន គឺជាការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់ជាបណ្តោះអាសន្នទៅឲ្យអ្នកខ្ចីនៅបរិមាណតម្លៃមួយ អាចជាវត្តុ ឬរបឹយវត្តុ (លុយ) ជាមួយនឹងការសន្យា នឹងសងត្រឡប់ទៅឲ្យម្ចាស់ដើមវិញនៅបរិមាណមួយធំជាងមុន ។[2]

១.១.២ គោលបំណងនៃការផ្តល់ឥណទាន

គោលបំណងនៃការផ្តល់ឥណទានរបស់ ធនាគារ ឬ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺ៖

- ចង់ទទួលបានចំណូលបន្ថែមពីការប្រាក់ ដើម្បីបង្កើនទ្រព្យ និងតម្លៃភាគហ៊ុន
- ចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម
- ផ្តល់ជាទុនដល់សាធារណៈជនទូទៅ ដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុរបស់ពួកគេ
- បង្កើនការងារដល់ប្រជាពលរដ្ឋ និងអាចជួយកាត់បន្ថយភាពក្រីក្រ ។

១.១.៣ មុខងារឥណទាន

នាពេលបច្ចុប្បន្នប្រភពមូលនិធិឥណទានជាច្រើនកំពុងតែមានដំណើរការយ៉ាងខ្លាំង ដូច្នេះហើយមិនថាអាជីវកម្មតូច-ធំ គ្រប់ប្រភេទរួមទាំងអតិថិជនណាចង់ខ្ចីអាចដាក់ពាក្យស្នើរសុំខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ ឬក្រុមរកស៊ីទិញលក់សញ្ញប័ណ្ណ និងតំលៃមូលប័ត្ររបស់ពួកគេ ដែលកំពុងតែកាន់កាប់។ ហើយពួកគេក៏អាចទិញទំនិញជឿ(ឥណទាន)ពីការលក់ទំនិញវាយ ឬអាចស្នើរសុំឥណទានពីស្ថាប័នសន្សំ ឬធនាគារពាណិជ្ជព្រមទាំងស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត។

គោលការណ៍ឥណទានគឺ[3]:

- ផ្តល់ទុនដល់កសិករសម្រាប់ទិញឧបករណ៍ និងមធ្យោបាយកសិកម្ម
- ផ្តល់កម្ចីដើម្បីកែតំរូវ ឬពង្រីកមុខរបរកសិករឲ្យប្រសើរឡើង

[1] សួន ចំរើន (២០១៥), ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ, ទំព័រទី ៥១
[2] អេង កែវពិសិដ្ឋ (២០១៥), ការគ្រប់គ្រងឥណទាន, ទំព័រទី ១០
[3] សួន ចំរើន (២០១៥), ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ, ទំព័រទី ៥១-៥២

- ផ្តល់ដល់ការហ្វឹកហ្វឺនវិជ្ជាជីវៈលើកម្មវិធីផលិតកម្មដើម្បីឲ្យកសិករចេះរៀបចំគម្រោង និងការប្រើប្រាស់មូលធនឲ្យបានសមស្រប។

- ផ្តល់ទុនដល់កសិករអាចរក្សាទុក និងអាចលក់កសិផលរបស់ខ្លួន នៅពេលណាដែលមានតម្លៃសមស្រប

- កាត់បន្ថយការប្រើប្រាស់ឥណទាន ដែលមានការប្រាក់ខ្ពស់ហួសហេតុ របស់បណ្តាលឈ្មួញមួយចំនួន

- បង្កើតការងារជូនប្រជាជនតាមជនបទ ដើម្បីកាត់បន្ថយការចាកចេញពីស្រុកកំណើតទៅស្វែងរកការងារធ្វើនៅបណ្តាលប្រទេសជិតខាង។

- បង្កើនផលិតភាពក្នុងស្រុកតាមរយៈការផ្តល់សេវាឥណទានក្នុងដំណើរការ អភិវឌ្ឍន៍និងការបែងចែកផលិតផល ។

១.១.៤ ប្រភេទឥណទាន

ប្រតិបត្តិការឥណទានបានកើតឡើងក្នុងទំរង់ផ្សេងៗគ្នាជាច្រើន ។ ការធ្វើចំណាត់ថ្នាក់នៃប្រភេទឥណទានជាមូលដ្ឋាន គឺពឹងផ្អែកលើគោលបំណងនៃឥណទាននិងវិធីសាស្ត្រសងបំណុល ។ ហើយវាមានពីរទំរង់ដែលផ្សេងគ្នា គឺឥណទានឯកជន និងឥណទានសាធារណៈ ។[4]

❖ **ឥណទានឯកជន**: គឺជាឥណទានដែលបានប្រើដោយបុគ្គល ឬដោយអ្នកជំនាញជាច្រើនដែលនាំទៅរកការដោះដូរក្នុងវិស័យឯកជននៃសេដ្ឋកិច្ចរបស់យើង ។ ឥណទានឯកជនមានធាតុពីរយ៉ាងគឺ

➢ <u>ឥណទានសម្រាប់អ្នកប្រើប្រាស់</u>: គឺជាអ្វីដែលអ្នកប្រើប្រាស់ចង់បាន និងត្រូវការ គឺការទិញទំនិញ-សេវាកម្មជាមួយការសន្យាដោយផ្អែកលើចំណូលរបស់ ពួកគាត់នាពេលអនាគត។ នៅក្នុងឥណទានអ្នកប្រើប្រាស់មាន ៣ប្រភេទ

- ឥណទានរាយ: គឺជាប្រភេទឥណទានដែលអ្នកប្រើប្រាស់ទិញទំនិញសម្រេច និងសេវាកម្មដោយផ្ទាល់ពីអ្នកលក់ដោយប្រើឥណទានវិល កិច្ចសន្យាសងរំលស់ ឬឥណទានសេវា ។

✓ ឥណទានវិល: គឺជាកិច្ចព្រមព្រៀងមួយដែលអនុញ្ញាត ឲ្យអ្នកប្រើប្រាស់ទិញទំនិញដោយប្រើឥណទានរហូតដល់ចំនួនអតិបរិមាមួយកំណត់ ។ ឧទាហរណ៍: Credit Card

✓ ឥណទានសងរំលស់: ជាការទិញដែលមានទ្រង់ទ្រាយធំ និងច្រើនមុខហើយទំនិញដែលទិញជាសេរីថេរសំណងទៀងទាត់លើរយៈពេលវែងកំណត់តាមពេលវេលា ។ កិច្ចសន្យាធ្វើ

[4] អេង កែវពិសិដ្ឋ (២០១៥), ការគ្រប់គ្រងឥណទាន, ទំព័រទី២០

ឡើងនៅពេលទិញទំនិញម្តងៗ (បន្ទុកហិរញ្ញវត្ថុ លក្ខខ័ណ្ឌសម្រាប់បញ្ជាក់អំពីគោលការណ៍អតិថិជនមិនព្រមសង)

✓ ឥណទានសេវា: ជាឥណទានដែលកើតឡើងពីអ្នកផ្តល់សេវាយល់ព្រមផ្តល់ ហើយរង់ចាំសំណង ឬអ្នកប្រើប្រាស់ ។

• ឥណទានសាច់ប្រាក់: ជាប្រភេទឥណទានដែលអ្នកខ្ចីទទួលមូលនិធិពីអ្នក ផ្តល់កំចីដោយ ដោះដូរជាមួយនឹងការចុះកិច្ចព្រមព្រៀងសងមូលនិធិត្រឡប់មកវិញនៅពេលណាមួយតាមកាលកំណត់ជាមួយនឹងការប្រាក់ ឬបន្ទុកហិរញ្ញវត្ថុ ។ ហើយវិធីទូទាត់មានដូចជា ការសងរំលស់ និងការសងតែម្តង ។

✓ កម្ចីសងរំលស់: ជាកម្ចីរៀបចំឡើងជាសេរីថេរ ដោយអ្នកខ្ចីធានាសងទៀងទាត់តាមពេលវេលាដែលកំណត់ ។

✓ កម្ចីសងតែម្តង: ជាទូទៅកម្ចីមានរយៈពេលខ្លី ហើយមូលនិធិនេះជាបុរេប្រទានមូលនិធិសម្រាប់រយៈពេល ១ឆ្នាំ ឬតិចជាងនេះ ។ កម្ចីនេះមានចុះកិច្ចព្រមព្រៀងសងមូលនិធិទាំងប្រាក់ដើម និងការប្រាក់ ឬបន្ទុកហិរញ្ញវត្ថុនៅចុងការបរិច្ឆេទ ។

• ឥណទានអចលនវត្ថុ: ជាប្រភេទទីបី នៃឥណទានសម្រាប់អ្នកប្រើប្រាស់ គឺជាឥណទានដែលកើតឡើងពីការខ្ចីមូលនិធិដោយមានការធានាពីអចលនទ្រព្យ ឬមានដាក់វត្ថុបញ្ចាំដើម្បីទទួលបានកម្ចី ។

➢ <u>ឥណទានអាជីវកម្ម</u>: គឺជាទំរង់ឥណទានមួយដែលចំណាស់បំផុត ។ហើយឥណទានអាជីវកម្មមាន ២ប្រភេទ

• ឥណទានសម្រាប់អ្នកលក់: ជាឥណទានសម្រាប់ទទួលទំនិញវត្ថុធាតុដើម និងសារពើភ័ណ្ឌសម្រាប់លក់បន្ត ។

• ប្រតិបត្តិការមូលនិធិហិរញ្ញវត្ថុ: មូលនិធិហិរញ្ញវត្ថុជាលុយ ដែលមានតម្រូវការចាំបាច់សម្រាប់ការចាប់ផ្តើម ការថែទាំ និងប្រតិបត្តិការអាជីវកម្ម ។

❖ **ឥណទានសាធារណៈ**: វាគឺជាកម្ចីកម្រិតរដ្ឋាភិបាល ដើម្បីមានហិរញ្ញវត្ថុសម្រាប់ទិញទំនិញសេវាកម្ម និងកម្មវិធីសុខមាលភាពផ្តល់ទៅឲ្យប្រជាពលរដ្ឋ ។ រដ្ឋាភិបាលធ្វើការខ្ចីប្រាក់នៅពេលដែលចំណូលពន្ធមិនគ្រប់គ្រាន់ ដើម្បីទូទាត់សម្រាប់កម្មវិធីដែលផ្តល់ជូនដល់ប្រជាពលរដ្ឋ។ ការខ្ចីរបស់ រដ្ឋាភិបាលតាមរយៈការលក់សញ្ញាប័ណ្ណរបស់រដ្ឋាភិបាលដែលបានធ្វើការសន្យាសងមូនិធិទៅឲ្យអ្នកវិនិយោគជាមួយការប្រាក់នៅពេលអនាគតដែលបានសន្យាលើសញ្ញាប័ណ្ណនោះ។

១.១.៥ សមាសភាគនៃដំណើរការឥណទាន

មានកត្តាជាច្រើន គួរសំរេចដោយម្ចាស់បំណុលមុន និងទទួលយកការសន្យារបស់អ្នកស្នើសុំដើម្បីសងបំណុលដោយប្រើឥណទានជំនួសសាច់ប្រាក់សុទ្ធ ។ ក្នុងនោះ គឺមានប្រតិបត្តិការឥណទានមួយគត់ ដែលអាចកំណត់ពីការកិច្ចនេះបានហើយមានការពាក់ព័ន្ធ និងការទទួលខុសត្រូវពីមន្ត្រីឥណទាន។[5]

- ហានិភ័យ: អ្នកទិញ ឬកូនបំណុលអាចមិនសង ឬសងមិនគ្រប់ចំនួននៅទីបញ្ចប់ ។ ដូច្នេះហើយអ្នកលក់ និងបាត់បង់តម្លៃរបស់ទំនិញ សេវា និងមូលនិធិជាដើម ដែលបានផ្តល់ទៅឲ្យកូនបំណុល។
- ពេលវេលា: ក្នុងប្រតិបត្តិការឥណទានអ្នកលក់ និងត្រូវរងចាំទទួលការសងត្រលប់ពីអតិថិជន ។ ក្នុងករណីនេះអ្នកលក់អាចខាតបង់ចំណូលដែលរកបានពីការវិនិយោគ ហើយក៏អាចកើតមានតំរូវការខ្ចីមូលនិធិបន្ថែម ដើម្បីធ្វើការទូរទាត់វិក័យបត្ររបស់ខ្លួនផ្ទាល់។
- ការធានាឬ វត្ថុបញ្ចាំ: អ្នកលក់ឬអ្នកឲ្យខ្ចីតម្រូវឲ្យអ្នកទិញ ឬអ្នកខ្ចី មានការធានា ឬវត្ថុបញ្ចាំដែលជាផ្នែកមួយនៃប្រតិបត្តិការឥណទាន ។ ហើយវត្ថុបញ្ចាំត្រូវជាវត្ថុមានតម្លៃដែលជាកម្មសិទ្ធិរបស់អ្នកខ្ចី ឬអ្នកទិញ ដែលវត្ថុនេះជាកិច្ចសន្យាមួយដើម្បីកាត់បន្ថយហានិភ័យដែលបានបាត់បង់ ។ កូនបំណុលបានផ្តល់សិទ្ធិជាម្ចាស់ឲ្យទៅអ្នកផ្តល់ឥណទាន និងយល់ព្រមប្រគល់ឲ្យអ្នកផ្តល់ឥណទាននូវវត្ថុបញ្ចាំនេះក្នុងករណីដែលមានហេតុការណ៍មិនសងបំណុល ។
- ការឯកភាពតាមច្បាប់: ប្រតិបត្តិការឥណទានជ:ឥទ្ធិពលដោយច្បាប់ ។ ច្បាប់នេះត្រូវបានអនុញ្ញាតដោយរដ្ឋដើម្បីការពារទាំងកូនបំណុល និងម្ចាស់បំណុល ។ ច្បាប់ទាំងនេះនឹងពន្យល់អំពីវិធីជៀសវាងការជាកពិន័យ និងរាល់ការចំណាយថ្លៃដើមដែលពាក់ព័ន្ធនឹងទំនាស់ ។ ដូច្នេះការបណ្តុះបណ្តាលតម្រូវឲ្យអ្នកធ្វើការឥណទានយល់ដឹងអំពីទំនាក់ទំនង ប្រតិបត្តិការឥណទានប្រកបដោយគុណភាព ។
- ចំណាយប្រតិបត្តិការ: អ្នកលក់នឹងត្រូវទទួលរងនូវការចំណាយបន្ថែមជាច្រើនបន្ទាប់ពីបានទទួលការសន្យាសងរបស់កូនបំណុល ការចំណាយទាំងនោះមានដូចជា ៖
  - Must be paid to credit personnel
  - Procedure cost, Print form for example
  - Computer and other equipment are required

[5] អេង កែវពិសិដ្ឋ (២០១៥) , ការគ្រប់គ្រងឥណទាន, ទំព័រទី២២

ហើយចំណាយមួយទៀតដែលមិនអាចជៀសផុត គឺចំណាយលើផ្នែកច្បាប់ និងការទារប្រាក់ត្រឡប់ ។

- អតិផរណា: ជាបាតុភូតមួយដែលនាំឲ្យតម្លៃទីផ្សារទូទៅឡើងថ្លៃ (ទំនិញ និងសេវា) ប្រសិនបើ ការសងប្រាក់ត្រូវបានពន្យាក្នុងអំឡុងពេលមួយដែលកំពុងកើតមានអតិផរណានោះ អំណាចទិញនៃធនលាភជាដុល្លាមិនគ្រប់ចំនួន ដូចតម្លៃដើមនៃដុល្លាដែលបានផ្តល់ជូនទៅកូនបំណុលនោះទេ ។

- បន្ទុកហិរញ្ញវត្ថុ: ជាចំនួនបន្ថែមអាចបង់បន្ថែមលើតម្លៃ ដែលកូនបំណុលបានទទួល ។ ម៉្យាងទៀតនឹងជួយគ្រប់គ្រងចំណាយថ្លៃដើម ការខាតបង់ចំណូលរកបានពីការវិនិយោគ និងកំរៃចំណាយលើច្បាប់ ។ បើសិនបន្ទុកហិរញ្ញវត្ថុមិនបញ្ចាក់ច្បាស់ គេមិនអាចបញ្ចូលកម្រៃទៅក្នុងទំនិញ និងសេវាកម្មរបស់ក្រុមហ៊ុនបានឡើយ ។

១.២ ដំណើរការនៃការគ្រប់គ្រងឥណទាន

ដំណើរការនៃការគ្រប់គ្រងឥណទាន គឺជាជំហានបន្តបន្ទាប់ដែលទាក់ទងទៅនឹងការលើកទឹកចិត្តក្នុងជំរើសទិញដោយប្រើឥណទាន ការវិភាគគ្រោះថ្នាក់នៃពាក្យសុំធ្វើជំរើសទិញដោយឥណទាន និងការប្រមូលបំណុល បន្ទាប់ពីកិច្ចសន្យាឥណទានត្រូវបានធ្វើ ។ នៅក្នុងដំណាក់កាលនីមួយៗ អ្នកគ្រប់គ្រងឥណទានត្រូវបង្កើតនយោបាយប្រតិបត្តិការ ដើម្បីជួយ ធានានូវគណនីឥណទាននីមួយៗ ឲ្យមានកម្រិតចំណាយសមរម្យតាមពេលកំណត់ ។[6]

១.២.១ ការលើកទឹកចិត្ត

ការលើកទឹកចិត្ត គឺលើកទឹកចិត្តចំពោះអតិថិជនណាដែលមានប្រវត្តិសងល្អ ។

១.២.២ ការពិនិត្យសំណើរសុំលើកដំបូង

ការពិនិត្យសំណើរសុំលើកដំបូង គឺជាការផ្តល់ឥណទានសម្រាប់អ្នកប្រើប្រាស់ជាច្រើន បានប្រើប្រព័ន្ធផ្តល់ពិន្ទុឥណទាន(ដោយប្រើទ្រព្យសម្បត្តិ បំណុល និងប្រាក់ចំណេញ ដើម្បីគណនា) សម្រាប់ត្រួតពិនិត្យលើសំណើរសុំខ្ចីឥណទានថ្មីៗ ។ ហើយលទ្ធផលដែលទទួលបាន គឺសម្រាប់វាយតម្លៃសុវត្ថិភាពហិរញ្ញវត្ថុអាជីវកម្មដែលស្នើសុំឥណទាន ។

១.២.៣ ការស៊ើបអង្កេតឥណទាន

ការស៊ើបអង្កេតឥណទាន គឺមានការទាក់ទងទៅនឹង សកម្មភាពនៃការប្រមូលពត៌មានសំខាន់ៗ ដើម្បីធ្វើការសម្រេចចិត្តផ្តល់ឥណទាន ។ បញ្ហាសំខាន់អ្នកគ្រប់គ្រងឥណទានគឺប្រមូល

[6] អេង កែវពិសិដ្ឋ (២០១៥), ការគ្រប់គ្រងឥណទាន, ទំព័រទី ២៥

ព័ត៌មានជាមួយនឹងរយៈពេលខ្លីហើយចំណាយតិច ។

១.២.៤ ការសម្រេចចិត្តផ្តល់ឥណទាន

ការសម្រេចចិត្តផ្តល់ឥណទាន: គឺសេចក្តីសម្រេចមួយដែលត្រូវបានធ្វើដោយអ្នកគ្រប់គ្រងឥណទាន ថាតើគួរតែផ្តល់ ឬមិនគួរផ្តល់នូវពាក្យស្នើសុំឥណទាន ។ បន្ទាប់ពីធ្វើការស៊ើបអង្កេតត្រូវបានបញ្ចប់ អ្នកគ្រប់គ្រងឥណទានត្រូវតែសម្រេច ប្រសិនបើកិច្ចសន្យាការទូទាត់សងនៅពេលក្រោយមានសុពលភាព ឬមានភាពប្រាកដប្រជា ។

១.២.៥ ការត្រួតពិនិត្យគណនី

ការត្រួតពិនិត្យគណនី គឺជាការត្រួតពិនិត្យដែលទាក់ទងទៅនឹងការឃ្លាំមើលទៅលើគណនីដើម្បីបញ្ជាក់ថាបំណុលសរុបមានលក្ខណៈសមរម្យសម្រាប់អតិថិជន ។ ពេលខ្លះមួយផ្នែកនៃសកម្មភាពត្រួតពិនិត្យនេះទាមទារឲ្យអ្នកគ្រប់គ្រងនូវរាល់ព័ត៌មានរបស់អតិថិជន ដើម្បីធ្វើការសម្រេចចិត្តថាតើគួរតែបន្ថែម ឬកំហិតទៅលើតម្រិតបន្ទាត់ឥណទាន ។

១.២.៦ ការប្រមូល

ការប្រមូល គឺជាកិច្ចខិតខំប្រឹងប្រែងជាច្រើនដើម្បីទទួលបានការទូទាត់បំណុលរបស់អតិថិជនដែលបានជំពាក់តាមកាលកំណត់ ។ សកម្មភាពការប្រមូល គឺជាទិដ្ឋភាពដែលមានសារៈសំខាន់បំផុតនៃប្រសិទ្ធភាពការគ្រប់គ្រងឥណទាន ។ កម្មវិធីប្រមូលដែលមានក្រិតក្រមនិងកែលំអរលំហូរសាច់ប្រាក់ រក្សាទំនាក់ទំនងល្អជាមួយអតិថិជន និងបង្កើនការលក់ ។ ធានានូវគណនីឥណទាននីមួយៗ ឲ្យមានកំរិតចំណាយសមរម្យតាមពេលកំណត់ ។

១.៣ ការគណនាការប្រាក់

ការប្រាក់ (Interest) គឺជាទឹកប្រាក់ដែលកូនបំណុល (debtor) សងបន្ថែមលើប្រាក់ដើមទៅឲ្យម្ចាស់បំណុល (Creditor)ជាឈ្នួលនៃការប្រើប្រាស់ប្រាក់របស់គេ ។ ហើយការគណនាការប្រាក់មាន ២ប្រភេទ[7]

១.៣.១ ការប្រាក់ទោល

ការប្រាក់ទោល គឺជាការប្រាក់ដែលគិតលើប្រាក់ដើមគ្រប់គ្រា ។ ការប្រាក់របស់គ្រានីមួយៗមិនត្រូវបានបូកបញ្ចូលជាមួយប្រាក់ដើមដើម្បីគិតការប្រាក់ក្នុងគ្រាក្រោយឡើយ ។

រូបមន្តសម្រាប់ការគណនាការប្រាក់ទោល

$$I = Pv \times r \times t$$

[7] ព្រុំ សុគុណ (២០១៩), គណិតវិទ្យាហិរញ្ញវត្ថុ, ទំព័រ ២១-២១-៣៩

PV (Present Value) : ប្រាក់ដើម

t (Number of Conversion periods) : ចំនួនឆ្នាំនៃការវិនិយោគ

I (Interest) : ការប្រាក់

r (Interest Rate) : អត្រាការប្រាក់ប្រចាំឆ្នាំ

Ex: ទឹកប្រាក់ ៨០០ $ ត្រូវបានខ្ចីក្នុងរយៈពេល ៦ខែ ។ ចូរគណនាការប្រាក់ដែលត្រូវសង បើអត្រាការប្រាក់ ៧.៧៥% ។

✍ <u>ចម្លើយ</u>

- គណនាការប្រាក់ដែលត្រូវសង

តាមរូបមន្ត: $I= Pv \times r \times t$

ដោយ PV = ៨០០$, r= ៧.៧៥%= ០.០៧៧៥, t= ៦ខែ

យើងបាន I = ៨០០ × ០.០៧៧៥ × ៦/១២

= ៣១$

ដូច្នេះ ការប្រាក់ដែលគាត់ត្រូវសងគឺ ៣១$

១.៣.២ ការប្រាក់សមាស

ការប្រាក់សមាស គឺជាការប្រាក់ដែលគិតលើការប្រាក់ ។ មានន័យថាការប្រាក់ដែលទទួលបានពីគ្រាទី ១ ត្រូវបូកបន្ថែមជាមួយប្រាក់ដើមដើម្បីគិតការប្រាក់នៅគ្រាទី ២ ហើយគេធ្វើរបៀបនេះរហូតដល់ Maturity ។

រូបមន្តសម្រាប់គណនាការប្រាក់សមាស

$$I = Fv - Pv$$

I (Interest) : ការប្រាក់

PV (Present Value) : ប្រាក់ដើម

Fv (Future Value) : តម្លៃអនាគត ឬប្រាក់អនាគត

Ex លោក A មានលុយ ១,០០០,០០០ $ បានយកទៅដាក់ចងការក្នុងរយៈពេល ៣ឆ្នាំ ដោយអត្រាការប្រាក់ ១០% ។

ក. គណនាតម្លៃអនាគតដែលលោក A ទទួលបានក្នុងរយៈពេលកំណត់នោះ ។

ខ. គណនាការប្រាក់ដែលគាត់ទទួលបានចុងគ្រា ។

ចម្លើយ

ក. គណនាតម្លៃអនាគតដែលលោក A ទទួលបាន

តាមរូបមន្ត $Fv = Pv (1+r)^t$

ដោយ Pv = ១,០០០,០០០$, r= ១០%= ០.១០ , t= ៣ឆ្នាំ

យើងបាន $Fv = ១,០០០,០០០ (1+ ០.១០)^{៣}$

= ១,៣៣១,០០០ $

ដូច្នេះ តម្លៃអនាគតដែលលោក A ទទួលបានគឺ ១,៣៣១,០០០ $

ខ. គណនាការប្រាក់ដែលគាត់ទទួលបានចុងគ្រា

តាមរូបមន្ត I = Fv - Pv

ដោយ Fv = ១,៣៣១,០០០ $, Pv= ១,០០០,០០០$

យើងបាន I = ១,៣៣១,០០០- ១,០០០,០០០

= ៣៣១,០០០ $

ដូច្នេះ ការប្រាក់ដែលគាត់ទទួលបានចុងគ្រាគឺ ៣៣១,០០០ $

១.៤ ការខាយតម្លៃក្នុងការផ្តល់ឥណទាន

ដើម្បីឆ្លើយតបសំនួរនេះ គឺគេបានរៀបរាប់នៅក្នុង C' s នៃការវិភាគឥណទាន " C' s of Credit Analysis " C's of Credit Analysis រួមមាន

- ចរិកលក្ខណៈ (Character)
- សមត្ថភាព (Capacity)
- ដើមទុន (Capital)
- វត្ថុបញ្ចាំ (Collateral)
- លក្ខខ័ណ្ឌ (Condition)
- សុភវិនិច្ឆ័យ (Common Sense)

១.៤.១ ចរិកលក្ខណៈ: (character)

ចរិកលក្ខណៈ: គឺជាចំនួនអរូបីយ៍សំរាប់បុគ្គលផ្ទាល់ ដែលទាក់ទងទៅនឹងភាពសុចរិក និងភាពខ្លាំងប្រកបដោយសីលធម៌ ។ កត្តាដែលរាប់បញ្ចូលទៅក្នុងការកំណត់អំពីចរិកលក្ខណៈ: រួមមានទំលាប់ផ្ទាល់ខ្លួន និង អាកប្បកិរិយាដែលសំដែងចេញដូចជា ការផឹកស៊ី ឬការលេងល្បែងស៊ីសងជាដើម ។

ចំពោះចរិកលក្ខណៈនៃឥណទាន គឺជាការសំដែងនូវចេតនាដ៏ល្អរបស់អ្នកប្រើប្រាស់ឥណទានដោយស្មគ្រចិត្តក្នុងការទូទាត់សំណងរបស់គាត់តាមកិច្ចសន្យា ។

១.៤.២ សមត្ថភាព (Capacity)

សមត្ថភាព គឺជាលទ្ធភាពរបស់អ្នកស្នើសុំឥណទានបញ្ជាក់អំពីកាតព្វកិច្ចសងតាមពេលកំណត់នៃកិច្ចសន្យា ។ ការវាយតម្លៃទៅលើសមត្ថភាពនៃអ្នកស្នើសុំ ជាទូទៅវាជាប់ទាក់ទងនឹងការស៊ើបអង្កេតទៅលើចំណូល ការងារ ការចំណាយផ្សេងៗ និងភាពជំពាក់បំណុលគេ ។

Ex អ្នកស្នើសុំឥណទានម្នាក់មានចំណូលមិនគ្រប់គ្រាន់ដើម្បីសងបំណុលនេះប្រហែលមកពីកម្រិតចំណូលរបស់គាត់ទាប ឬក៏កម្រិតនៃបំណុលរបស់គាត់ខ្ពស់ពេក ។

ចំណូលត្រូវតែមាននិរន្តភាព និងអាចព្យាករណ៍បាន ។ សមត្ថភាពត្រូវទទួលរងការគំរាមកំហែង ប្រសិនបើបុគ្គលម្នាក់ៗឆ្ពោះទៅរកភាពអត់ការងារធ្វើ ឬចំណូលបានកាត់បន្ថយ។

១.៤.៣ ដើមទុន (Capital)

ដើមទុន គឺជាភាពខ្លាំងខាងផ្នែកហិរញ្ញវត្ថុរបស់អ្នកស្នើសុំឥណទាន ជាបឋមបានបង្ហាញត្រង់ចំណុចកំរិតនៃទ្រព្យបម្រុង ។ ទ្រព្យសកម្មទាំងនេះអាចជាទ្រព្យសកម្មរូបី មានដូចជា សមតុល្យគណនីសំចៃ ឬ ជាទ្រព្យសកម្មអរូបី មានដូចជា សកម្មភាពស្វែងរកការងារផ្សេងៗបានរហ័សពីព្រោះគេមានការយល់ដឹង និងជំនាញពិសេសរបស់គេ ។

ទ្រព្យសម្បត្តិទាំងនេះអាចផ្តល់ភាពងាយស្រួលដល់អ្នកស្នើសុំ ក្នុងករណីខ្លះដើម្បីជាការពឹងពាក់ប្រសិនបើហិរញ្ញវត្ថុមានភាពមិនអនុគ្រោះ ។

១.៤.៤ វត្ថុបញ្ចាំ (Collateral)

វត្ថុបញ្ចាំ គឺជាកិច្ចការនៃសិទ្ធិជាកម្មសិទ្ធិលើទ្រព្យសម្បត្តិនៅពេលដែលអ្នកប្រើប្រាស់ឥណទានមិនបានទូទាត់សំណងតាមកិច្ចសន្យា។ វត្ថុបញ្ចាំ ជាវត្ថុមួយដើម្បីធានាលើការកំចី ឬជាកាតព្វកិច្ចឥណទាន។ ហើយយើងអាចនិយាយបានថាវាជាវត្ថុសំរាប់ទិញការប្រើប្រាស់ឥណទាន ។

១.៤.៥ លក្ខខ័ណ្ឌ (Condition)

លក្ខខ័ណ្ឌ គឺជាប្រភេទនៃការវិភាគឥណទានមួយ ដើម្បីចង់ដឹងថា តើអ្នកស្នើសុំឥណទានមានទំនាក់ទំនងយ៉ាងណាជាមួយប្រព័ន្ធសេដ្ឋកិច្ច និងមើលថា តើព្រឹត្តិការណ៍សេដ្ឋកិច្ច និងមានឥទ្ធិពលកម្រិតណា ចំពោះលទ្ធភាពសងបំណុលរបស់គាត់ ។

Ex ក្រុមការងារ គួរតំរូវឲ្យអ្នកស្នើសុំឥណទាន ពន្យល់ពីអ្វីដែលគាត់ធ្វើនៅកំឡុងខែរងារ អាយុ ជំនាញការងារ ចំណេះដឹង និងលក្ខខ័ណ្ឌផ្សេងៗទៀតដែលនឹងជះឥទ្ធិពលដល់លទ្ធភាពអ្នកស្នើសុំក្នុងការរក្សាប្រាក់ចំណូល ។

១.៤.៦ សុភវិនិច្ឆ័យ (Common Sense)

សុភវិនិច្ឆ័យ គឺជាការកាត់ក្តីដ៏ល្អ ។ ជាធម្មតានេះគឺជាឧបករណ៍វិភាគឥណទានមួយបន្ទាប់ពីគណនីមួយបានបញ្ជាក់ថានឹងក្លាយជាបំណុលពិបាកទារ ។

អ្នកវិភាគឥណទាននឹងបញ្ជាក់ថាការប្រើការវិនិច្ឆ័យ ដើម្បីជៀសវាងការទំនាក់ទំនងឥណទានជាលើកដំបូងបង្អស់ ។ ធម្មតាការប្រៀបធៀប ការអង្កេត និងការគណនាអាចនឹងបង្ហាញថាកំចី ឬគណនីឥណទាន គឺមិនគួរផ្តល់ឲ្យ ។ ពេលខ្លះវាគឺជាការទទួលខុសត្រូវរបស់អ្នកផ្តល់ឥណទានដើម្បីកំណត់ថាគួរ ឬមិនគួរបន្តផ្តល់ឥណទាន ។

មានពេលខ្លះ អ្នកទទួលខុសត្រូវក្នុងការផ្តល់ឥណទាន ធ្វើការបញ្ជាក់ពីការបន្តផ្តល់ឥណទានក៏មិនបានសមរម្យដែរ ។

អ្នកវិភាគឥណទាន អាចនឹងព្រមទទួលយកការវិនិច្ឆ័យមួយជំនួសពួកគេសំរាប់អ្នកខ្ចី ។

១.៤.៧ សារៈសំខាន់នៃ C’ s **សំរាប់ការវិភាគឥណទាន**

នៅក្នុងឥណទានអ្នកប្រើប្រាស់ អ្នកវិភាគឥណទានបានសង្កត់ធ្ងន់ទៅលើ ចរិកលក្ខណៈ និងសមត្ថភាព ជាងកត្តាផ្សេងទៀតដែលមានឥទ្ធិពលដល់ដើមទុនរបស់អ្នកស្នើសុំ ។ហើយជាទូទៅអ្នកគ្រប់គ្រងឥណទាន តែងចង់បានការសងបំណុលដោយស្ម័គ្រចិត្ត និងតាមលទ្ធផលរបស់អតិថិជនជាជាងពឹងលើការរឹបអូសយកមកធ្វើជាកម្មសិទ្ធិវិញ ។ អ្នកវិភាគឥណទាន កំណត់យក Character ជាផ្នែកមួយដ៏សំខាន់បំផុតនៅក្នុង C’ s of credit analysis។

អ្នកវិភាគឥណទានភាគច្រើនបានប្រកាន់យកចរិតជាកត្តាសំខាន់របស់ C’s នៃការវិភាគឥណទាន ។ បើសិនអ្នកខ្ចីខ្វះទំនួលខុសត្រូវ (ចរិក) លើឥណទានគេនឹងអាចគេចវេស ឬមានការយឺតយ៉ាវក្នុងការសង ។ ចំពោះបណ្តាស្របច្បាប់ការប្រមូលបំណុលអាចធ្វើទៅបាន ប៉ុន្តែឆន្ទៈសងតាមការព្រមព្រៀងជាគុណសម្បត្តិមួយរបស់អតិថិជនដែលឥណទានស្វែងរក។

១.៥ លក្ខណៈទូទៅនៃហានិភ័យឥណទាន

១.៥.១ និយមន័យ

ហានិភ័យឥណទាន គឺជាកម្រិតនៃគ្រោះថ្នាក់ដែលកើតឡើងចំពោះប្រាក់កម្ចីរបស់ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយទទួលរងនូវការខាតបង់ដោយសារអតិថិជនរបស់ខ្លួន មិនសងបំណុលតាមកិច្ចសន្យា ឬមិនសងគ្រប់ចំនួនទឹកប្រាក់ ទាំងប្រាក់ដើម និងការប្រាក់ ។ ហានិភ័យនេះធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុយកចិត្តទុកដាក់ជាងគេ ព្រោះហានិភ័យនេះអាចធ្វើឲ្យក្ស័យធនបាន ។

ដូច្នេះ មុននឹង សម្រេចចិត្តផ្តល់ឥណទានធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែងតែសិក្សាទៅលើហានិភ័យជាចំបង លុះត្រាតែធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុយល់ថាគ្មានហានិភ័យ ឬមានហានិភ័យទាបទើបអាចផ្តល់ឥណទានបាន ។[8]

១.៥.២ កត្តាដែលបង្ករឲ្យមានហានិភ័យឥណទាន

ហានិភ័យឥណទានអាចបណ្តាលមកពីកត្តាមួយចំនួនដូចជា មូលហេតុដែលបណ្តាលមកពីអតិថិជន មកពីធនាគារ មកពីសង្គម និងធម្មជាតិ[9]

- **មូលហេតុបណ្តាលមកពីអតិថិជន**

- ការព្យាករណ៍លើការវិនិយោគនៅទាប មិនមានសកម្មភាពគ្រប់គ្រាន់
- ការពិចារណាមិនដិតដល់ទៅលើការវិនិយោគណាមួយ ឬចូលចិត្តការវិនិយោគណាដែលមានប្រាក់ចំណេញច្រើន
- ត្រូវបានដៃគូវិនិយោគបោកប្រាស់
- អតិថិជនខ្លះមានបំណងបោកប្រាស់ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែម្តង ទោះមានលទ្ធភាពក៏ដោយ។

- **មូលហេតុបណ្តាលមកពីធនាគារ**

- បុគ្គលិកមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីវាយតម្លៃអតិថិជន
- បុគ្គលិកមិនមានភាពស្មោះត្រង់
- អតិថិជនជាសាច់ញាតិរបស់បុគ្គលិក
- បុគ្គលិកផ្ទាល់មានចេតនាធ្វើឲ្យមានកំហុស ។

- **មូលហេតុបណ្តាលមកពីសង្គម និងគ្រោះធម្មជាតិ**

- មានសង្គ្រាម
- ការធ្លាក់ចុះនៃសេដ្ឋកិច្ច
- ការផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ច ឬរដ្ឋាភិបាល
- ភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី ។

[8] ងួន ហោង (២០១៤), រូបិយវត្ថុ និងធនាគារ, ទំព័រ ១១៤
[9] ងួន ហោង (២០១៤), រូបិយវត្ថុ និងធនាគារ, ទំព័រ ១១៥

១.៥.៣ វិធីសាស្ត្រទប់ស្កាត់ហានិភ័យឥណទាន

ដើម្បីកាត់បន្ថយនូវហានិភ័យឥណទាន ទាំងឡាយណាដែលអាចនឹងកើតមានឡើងដូចបានរៀបរាប់ខាងលើ ត្រូវផ្តោតទៅលើកត្តាសំខាន់ ពីរ[10]

- ធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវពីអតិថិជន
  - គោលបំណងនៃការសុំខ្ចី
  - ពិនិត្យមើលអាជីវកម្ម
  - វិភាគលើរបាយការណ៍ហិរញ្ញវត្ថុ
  - ពិនិត្យលើប្រវត្តិរូបរបស់អ្នកខ្ចី
  - ត្រូវមានវត្ថុបញ្ចាំ ឬ អ្នកធានា ។
- ធនាគារត្រូវធ្វើការពង្រឹងសមត្ថភាពទៅលើបុគ្គលិក
  - ជ្រើសរើសបុគ្គលិកដែលមានជំនាញខាងឥណទាន
  - បណ្តុះបណ្តាលបន្ថែមដល់បុគ្គលិកជាការចាំបាច់
  - ដាក់ពិន័យ ឬដាក់ទោសទៅលើបុគ្គលិកដែលមានកំហុស
  - ណែនាំបុគ្គលិកឲ្យឯកភាពគ្នាក្នុងការបំពេញការងារ
  - លើកទឹកចិត្តរាល់បុគ្គលិកដែលធ្វើការបានល្អ ។

១.៥.៤ ករណីឥណទានមានបញ្ហា

បំណុលមានបញ្ហាកើតឡើងដោយសារកង្វះសាច់ប្រាក់របស់កូនបំណុល ក្នុងការទូទាត់សងការប្រាក់ និងប្រាក់ដើមនៃបំណុល។ នៅពេលដែលមានបញ្ហាកើតឡើងសញ្ញាណានៃវិបត្តិផ្ទៃក្នុងនិងក្រៅ ក៏កើតមានឡើងដែរ ។ មន្ត្រីឥណទានត្រូវតែស្វែងយល់ពីរោគសញ្ញានៃវិបត្តិទាំងនោះឲ្យបានទាន់ពេល និងត្រូវខិតខំរិះរកវិធានការទប់ស្កាត់ដោះស្រាយ ឬកែប្រែស្ថានភាពនោះ។ ការប្រាស្រ័យទាក់ទងរវាងមន្ត្រីឥណទាន និង អតិថិជនកាន់តែខ្លាំង ព័ត៌មានដែលអាចទទួលបានចំពោះស្ថានភាពរបស់កូនបំណុលកាន់តែច្បាស់ ។

<u>**សញ្ញាណព្រមាន**</u>

ទោះបីមានការការពារយ៉ាងណាក៏ដោយ ក៏ធនាគារភាគច្រើននូវតែជៀសមិនផុតពីការផ្តល់ឥណទានជួបនឹងបញ្ហា ។ ជាធម្មតាអ្នកខ្ចី តែងតែមានការខកខានសងមួយដង ឬច្រើនដង រីឯវត្ថុ

[10] ងួន ហោង (២០១៤), រូបិយវត្ថុ និងធនាគារ, ទំព័រ ១១៥

បញ្ហាំត្រូវបានថយចុះយ៉ាងខ្លាំងហើយស្ថានភាពនៃឥណទានមានបញ្ហាស្ថិតក្នុងទំរង់ផ្សេងៗគ្នា ប៉ុន្តែមានលក្ខណៈមួយចំនួនអាចចាត់ទុកថា ជាសញ្ញាព្រមានដល់ធនាគារ ។ សញ្ញាព្រមានទាំងនោះរួមមាន ដូចជា៖

- ភាពមិនប្រក្រតី ឬក៏ការពន្យាពេលនៃការផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលមិនអាចពន្យល់បានការពន្យាពេលនៃការសង ឬការពន្យាពេលក្នុងការទំនាក់ទំនងជាមួយធនាគារ
- ចំពោះឥណទានអាជីវកម្មការរៀបចំបំណុលឡើងវិញនូវបំណុលកំពុងជំពាក់ ឬក៏ការបំបាត់ចោលនូវភាគលាភ ឬក៏ការផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទាន
- ក្រុមហ៊ុនផ្លាស់ប្តូរអ្នកត្រួតពិនិត្យ
- ចំពោះឥណទានអាជីវកម្មការផ្លាស់ប្តូរភ្លាមៗនៅក្នុងវិធីសាស្ត្រ ដែលប្រើប្រាស់ដោយក្រុមហ៊ុនចំពោះគណនីរំលស់ សោធននិវត្តន៍ តម្លៃរបស់ស្តុក គណនីពន្ធ ឬការទទួលស្គាល់ចំណូល
- ការបង្វែរទិសនៃការលក់ពិតប្រាកដ លំហូរសាច់ប្រាក់ពីអ្វីដែលបានព្យាករណ៍ នៅពេលដែលគេស្នើសុំ ។

ការស្វែងយល់អត្តសញ្ញាណទាន់ពេល នៃបញ្ហាលំបាករបស់កូនបំណុលធ្វើឲ្យធនាគារមានពេលប៉ាន់ប្រមាណសភាពការណ៍ពិត និងបង្កើតយុទ្ធសាស្ត្រទប់ទល់បញ្ហា ។ នៅពេលនោះ មន្ត្រីឥណទានត្រូវតែធ្វើការត្រួតពិនិត្យកូនបំណុលនិងចាត់វិធានការតាមដានចំណុចមួយចំនួន ដូចខាងក្រោម ៖

- វិភាគបញ្ហារបស់កូនបំណុល
- ពិគ្រោះយោបល់ជាមួយផ្នែកធនាគារដែលមានជំនាញក្នុងផ្នែកស្រោចស្រង់ការឲ្យខ្ចី
- សំណូមពរការពន្យាពេលការទូទាត់ប្រាក់ ប្រសិនបើចាំបាច់
- ត្រួតពិនិត្យសកម្មភាពគណនី សម្រាប់ឥណទាន និងវត្ថុបញ្ចាំ
- បង្កើតផែនការដើម្បីកែលម្អសកម្មភាព

១.៥.៥ យុទ្ធសាស្ត្រដោះស្រាយបំណុលមានបញ្ហា

រាល់បំណុលមានបញ្ហា គឺមានលក្ខណៈខុសៗគ្នា ហើយក៏មិនមានវិធីតែមួយដើម្បីដោះស្រាយនោះទេ ។ មានវិធីសាស្ត្រសំខាន់ៗដូចខាងក្រោម ៖

- បង្កើតកម្មវិធីរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ
- ពិនិត្យឡើងវិញ ចំពោះការរៀបចំឯកសារបន្ថែម និងការធានា

- រក្សាវត្ថុបញ្ចាំបន្ថែម
- ស្វែងរកមូលនិធិបន្ថែម
- លក់វត្ថុបញ្ចាំ
- លក់ទ្រព្យសកម្ម
- ចាត់វិធានការច្បាប់ ដូចជា កោះហៅអ្នកធានាមកសងបំណុល
- រក្សាដើមទុនដែលបានពីម្ចាស់កម្មសិទ្ធិ ឬភាគីផ្សេងៗ
- រៀបចំឯកសារសម្រាប់ការក្ស័យធន ។

១.៦ តួនាទី និងអត្ថប្រយោជន៍ឥណទាន

១.៦.១ តួនាទីឥណទានក្នុងសេដ្ឋកិច្ច

នៅក្នុងការរស់នៅប្រចាំថ្ងៃតែងតែមានការពាក់ព័ន្ធជាមួយនឹងឥណទាន(ការខ្ចី)ដោយជៀសពុំរួចឡើយដើម្បីបំពេញទៅតាមកង្វះខាតនានា ។ ហើយការប្រើប្រាស់ឥណទាននេះដែរវាអាចមានទាំងគុណសម្បត្តិ រួមទាំងគុណវិបត្តិ ដោយកត្តាទាំងនេះវាអាស្រ័យទៅលើមូលហេតុនៃតម្រូវការ និងសមត្ថភាពនៃអ្នកខ្ចី ។[11]

- **ឥណទានសម្រាប់អ្នកប្រើប្រាស់**

- <u>គុណសម្បត្តិ</u>

ជាទូទៅអ្នកប្រើប្រាស់ទទួលបានអត្ថប្រយោជន៍ ពីការប្រើប្រាស់ឥណទាន ពីព្រោះពួកគេអាចប្រើចំណូលនៅពេលអនាគតរបស់ពួកគេដើម្បីធ្វើការទូទាត់លើទំនិញ និងសេវាដែលពួកគេមានតម្រូវការ ។ ដូច្នេះពួកគេអាចបង្កើនកម្រិតជីវភាពនៃការរស់នៅរបស់ពួកគេនាពេលបច្ចុប្បន្ន ។

ម្យ៉ាងទៀត បើអ្នកប្រើប្រាស់អាចធ្វើដំណើរជុំវិញពិភពលោកដោយប្រើប័ណ្ណឥណទានសម្រាប់ធ្វើការទូទាត់ថ្លៃប្រេង ថ្លៃឧស្ម័ន សណ្ឋាគារ សំបុត្រយន្តហោះ ជាការល្អ ព្រោះពុំចាំបាច់យកសាច់ប្រាក់ចំនួនច្រើនតាមខ្លួននោះទេ ។

- <u>គុណវិបត្តិ</u>

ក្នុងករណីប្រើហួសកម្រិតមិនចំគោលដៅ អាចធ្វើឲ្យបាត់បង់នូវលទ្ធភាពក្នុងការទូទាត់សងនៅទឹកប្រាក់ដែលបានខ្ចី ។ ក្នុងករណីធ្ងន់ធ្ងរ ជាលទ្ធផលអាចបង្កឲ្យក្ស័យធន បាត់បង់ទ្រព្យសម្បត្តិ គ្រួសារបែកបាក់គ្នា ធ្វើឲ្យអ្នកដទៃបាត់បង់នូវការជឿទុកចិត្តមកលើខ្លួន និងបាត់បង់លទ្ធភាពសន្សំប្រាក់សម្រាប់គោលបំណងក្នុងពេលអនាគត ។

[11] អេង កែវពិសិដ្ឋ (២០១៥),ការគ្រប់គ្រងឥណទាន, ទំព័រទី ៥០

- **ឥណទានសម្រាប់ការប្រើប្រាស់ក្នុងអាជីវកម្ម**

- <u>គុណសម្បត្តិ</u>

អាជីវកម្មជាច្រើនមានទំនុកចិត្តលើឥណទាន ដើម្បីពង្រីកទីផ្សារ និងស្វែងរកអ្នកប្រើប្រាស់របស់ពួកគេ ប្រសិនបើពួកគេផ្តល់ឱកាសសម្រាប់អតិថិជនរបស់ពួកគេមានជម្រើសទិញដោយឥណទាន នោះនឹងមានមនុស្សជាច្រើនអាចចូលរួមទិញបាន ។ ហើយអាជីវកម្មក៏អាចពង្រីកការផលិត និងសន្និធិទំនិញយ៉ាងច្រើនប្រសិនបើពួកគេអាចទទួលបានការទិញដោយប្រើឥណទាន ។

- <u>គុណវិបត្តិ</u>

សម្រាប់ការប្រើប្រាស់ក្នុងអាជីវកម្មមានដូចជា ការលក់ដោយជំពាក់នៅពេល ដែលអ្នកទិញមិនព្រមទូទាត់សង វានឹងធ្វើឲ្យម្ចាស់ទំនិញខាតបង់ប្រាក់ចំណេញដែលពួកគេនឹងទទួលបានពីទំនិញទាំងនោះ ។ សរុបមកការប្រើប្រាស់ឥណទានអាចផ្តល់ផលល្អ និងផលអាក្រក់ដែលអាស្រ័យទៅលើ ថាតើអ្នកដែលអាចខ្ចីនូវប្រាក់នោះត្រឹមត្រូវ ចំគោលដៅរបស់ពួកគេដែរឬទេ ? រួមជាមួយនឹងលទ្ធភាពសងត្រឡប់មកវិញរបស់អ្នកខ្ចីផងដែរ ។

១.៦.២ អត្ថប្រយោជន៍ចំពោះអ្នកខ្ចីឥណទាន

- ពេលមានចំណូលកើនឡើង: អតិថិជនជាទូទៅអាចទទួលបាននូវផលប្រយោជន៍ ពីការប្រើប្រាស់ឥណទាន ពីព្រោះថាគេអាចប្រើប្រាស់ចំណូលនៅពេលអនាគត ដើម្បីចំណាយទៅទិញទំនិញ ឬសេវាកម្មដែលពួកគេត្រូវការ ។ ដូច្នេះ ពួកគេអាចពង្រីកកម្រិតជីវភាពនាពេកបច្ចុប្បន្នឲ្យរីកចម្រើនបាន ដោយផ្អែកលើសមត្ថភាពដើម្បីស្វែងរកប្រាក់ និងទទួលបានទុននាពេលអនាគត

- មានមូលធនគ្រប់គ្រាន់នៅក្នុងការធ្វើអាជីវកម្ម: អតិថិជនអាចប្រើប្រាស់ ឥណទានដើម្បីបង្កើតអាជីវកម្ម ឬពង្រីកអាជីវកម្ម ដើម្បីស្តារ និងលើកកម្ពស់អាជីវកម្មរបស់ខ្លួនបានថែមមួយកម្រិតទៀត ។[12]

១.៦.៣ អត្ថប្រយោជន៍ចំពោះធនាគារ

ទទួលបានការប្រាក់: ដែលជាហេតុធ្វើអោយចំណូលរបស់ខ្លួនកើនឡើង ។ ការផ្តល់ឥណទានអាចធ្វើឲ្យសាច់ប្រាក់ដែលមាននៅក្នុងធនាគារ អាចចរាចរបានដែលធ្វើឲ្យប្រតិបត្តិការរបស់ធនាគារទទួលបានប្រសិទ្ធិភាពខ្ពស់ព្រមទាំងអាចបង្កើនទំនុកចិត្តពីភាគទុនិក និងអតិថិជនផងដែរ។

[12] ងួន ហោង (២០១៤), រូបិយវត្ថុ និងធនាគារ, ទំព័រ ៩៩-១០០

១.៦.៤ អត្ថប្រយោជន៍ចំពោះសង្គម

- ចរាចរលុយដំណើរការនៅលើទីផ្សារ
- ផ្ទេរលុយពីអ្នកមានធនធាននៅពេលទំនេរទៅឲ្យអ្នកខ្វះដើមទុន
- ធ្វើឲ្យការវិនិយោគកើនឡើង
- សំបូរការងារធ្វើ
- ធ្វើឲ្យសេដ្ឋកិច្ចមានដំណើរការ ឬធ្វើឲ្យសេដ្ឋកិច្ចកើនឡើង ។

ជំពូក២

ស្ថានភាពទូទៅរបស់ក្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាបាធី

ជំពូកទី ២

ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាទី

២.១ ជីវប្រវត្តិ និងរបត់នៃការរីកចម្រើនរបស់អម្រឹត

- ១៩៩១ GRET ដែលជាអង្គការក្រៅរដ្ឋាភិបាលរបស់ប្រទេសបារាំង បានបង្កើតគម្រោងសាកល្បងដើម្បីផ្តល់ឥណទានខ្នាតតូចបំផុតដល់ប្រជាជនកម្ពុជានៅតាមជនបទ។ គម្រោងសាកល្បងលើកដំបូងនេះ (EXPE 1) បានចាប់ផ្តើមដំណើរការ ជាមួយនឹងសេវាហិរញ្ញវត្ថុតែមួយគត់ដែលត្រូវបានគេស្គាល់ថាឥណទានក្រុមធានា ។

- ២០០០ ជាមួយនឹងជំនួយផ្នែកប្រឹក្សាយោបល់ពី Horus-Development Finance គម្រោងនេះបានប្រែក្លាយជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (អឹមអឹមតេ) ដែលមានដើមទុនចុះបញ្ជីចំនួន ៣៣០ លានរៀល និងមានភាគទុនិកចំនួនពីរគឺ GRET និង SIDI ។

- ២០០១ អឹមអឹមតេ បានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា ។

- ២០០២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អឹមអឹមតេទទួលយកជាផ្លូវការនូវភាគទុនិកថ្មីចំនួនពីរបន្ថែមទៀតគឺ La Fayette Participation (LFP) ដែលជាបុត្រសម្ព័ន្ធរបស់ Horus-Development Finance និង PROPARCO (ជាមួយនឹងការរួមបញ្ចូលដើមទុន ២០% នៃភាគហ៊ុនសរុប) ។

- ២០០៣ I & P បានចូលជាម្ចាស់ភាគហ៊ុនថ្មីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អឹមអឹមតេ ។

- ២០០៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអឹមអឹមតេ បានប្តូរឈ្មោះជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត នៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៤ ។ ភាគទុនិក LFP បានទិញយកភាគហ៊ុន PROPARCO ។

- ២០០៦ Advans SA SICAR បានក្លាយជាភាគទុនិក ។ Advans SA គឺជាក្រុមហ៊ុនបណ្តាក់ទុកវិនិយោគមួយ បង្កើតទៅក្នុងឆ្នាំ ២០០៥ ដោយ Horus Development Finance ដែលមានការចូលរួមពីស្ថាប័នហិរញ្ញវត្ថុធំៗដូចជា EIB WfW IFC AFD FMO និង CDC ។

- ២០០៧ Botta (ក្រុមហ៊ុនវិនិយោគរបស់បុគ្គលិកអម្រឹត) បានក្លាយជាភាគទុនិក ។

- ២០០៨ យោងតាមច្បាប់ស្តីពីធនាគារនៅកម្ពុជា Advans បានក្លាយជាភាគទុនិកនាំមុខ និងភាគទុនិកមានឥទ្ធិពលជាមួយនឹងភាគហ៊ុនចំនួន ៣១,៣២% ។ SIDI និង I &P បានចាកចេញហើយ FMO Oikocredit និង PROPARCO ចូលមកវិនិយោគ ។

- ២០០៩ នៅខែមករា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត បានទទួលអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណៈជន ។ នៅដំណាច់ឆ្នាំដដែល សាខាទាំងអស់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

អម្រឹត ត្រូវបានរៀបចំរួចជាស្រេច ដើម្បីទទួលប្រាក់បញ្ញើពីសាធារណជន ។

- ២០១២ Advans SA បានបង្កើតភាគហ៊ុនដល់ ៤៤,៤២% នៃដើមទុនសរុប ដោយទិញយកភាគហ៊ុនរបស់ Oikocredit ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត បានពង្រឹងវិធីសាស្ត្រ និងមូលដ្ឋានក្នុងការគ្រប់គ្រងសាច់ប្រាក់នៃឥណទានបុគ្គល និងធ្វើតេស្តសាកល្បងផលិតផលឥណទានសហគ្រាសខ្នាតតូច និងមធ្យម ។

- ២០១៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត បានដាក់ឲ្យប្រើប្រាស់នូវឥណទានខ្នាតតូច និងមធ្យម និងធ្វើតេស្តសាកល្បងផលិតផល កសិកម្ម (AGRIFIN) ដែលជាផលិតផលនៅតាមជនបទ បង្កើតឡើងដើម្បីផ្តល់ជូនសហគ្រិនកសិកម្មខ្នាតតូច និងមធ្យមជាមួយនឹងតម្រូវការដើមទុនដើម្បីពង្រឹកសកម្មភាពរបស់ខ្លួន ។

- ២០១៤ អម្រឹតបានដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធស្នូលរបស់ធនាគារគឺ T២៤ និងឥណទានកសិកម្ម ។

- ២០១៥ អម្រឹតបានក្លាយជាបុត្រសម្ព័ន្ធពេញលេញរបស់ Advans នៅក្នុងខែមីនា ។ Advans SA FMO និង IFC បានទិញយកភាគហ៊ុនរបស់ GRET និង PROPARCO ។ អម្រឹតបានដាក់ឲ្យប្រើប្រាស់នូវសេវាហិរញ្ញវត្ថុចល័ត កាលពីខែ សីហា ឆ្នាំ ២០១៥ ។ អម្រឹតបានចូលរួមក្នុងពិធីខួបទី ១០ឆ្នាំរបស់ Advans ទាំងក្នុង និងក្រៅ ។

២.២ ជីវប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាទី

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី បានបង្កើតឡើងនៅ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ដែលចាប់ផ្តើមដំណើរការដំបូង ជាមួយនឹងសេវាឥណទានក្រុមធានា និងឥណទានបុគ្គល ។ ហើយរហូតមកដល់បច្ចុប្បន្ន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី មានដំណើរការសេវាកម្មដូចជា សេវាឥណទាន (ឥណទានសម្ភារប្រើប្រាស់ ឥណទានកែលម្អគេហដ្ឋាន ឥណទានអាជីវកម្ម ឥណទានឡជីវឧស្ម័ន ឥណទានក្រុមឯករាជ្យ) សេវាផ្ទេរប្រាក់ និងសេវាប្រាក់បញ្ញើរ (គណនីរីករាយ គណនីប្រាថ្នា គណនីកើនទ្រព្យ គណនីពាណិជ្ជ) ។

២.៣ ទីស្នាក់ការកណ្តាលរបស់អម្រឹត

អម្រឹត ជាស្ថាប័នមីក្រូហិរញ្ញវត្ថុដែលបានផ្តល់សេវាហិរញ្ញវត្ថុទៅឲ្យប្រជាពលរដ្ឋនៅតាមជនបទក្នុងព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ១៩៩១ មកម្លេះ ។ **អម្រឹត** មានទីស្នាក់ការកណ្តាលនៅផ្ទះលេខ ៣៥ BA ផ្លូវ ១៦៩ សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

បើគិតមកត្រឹមឆ្នាំ ២០១៥ អម្រឹតបានប្រតិបត្តិការនៅតាមបណ្តាខេត្ត ក្រុងចំនួន ១៧គឺ

ភ្នំពេញ កណ្តាល កំពង់ចាម កំពត ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ តាកែវ សៀមរាម បាត់ដំបង បន្ទាយមានជ័យ សួង កំពង់ឆ្នាំ កំពង់ធំ រតនគិរី ព្រះសីហនុ ព្រៃកតាមាក់ ហើយក្នុងរយៈពេលថ្មីៗនេះអម្រឹតបានពង្រីកសាខារបស់ខ្លួននៅតាមបណ្តាខេត្តផ្សេងៗទៀត ។

២.៤ អត្តសញ្ញាណ និងអត្ថន័យនៃឈ្មោះ បាវចនា និងផ្លាកសញ្ញា

➢ អត្តសញ្ញាណនៃឈ្មោះ បាវចនា និងផ្លាកសញ្ញា

ដើម្បីធ្វើទំនាក់ទំនងទស្សនិកជនគោលដៅពីរផ្សេងគ្នាគឺ (១) អតិថិជន (២) ម្ចាស់ជំនួញ ឥណទានយកមកវិនិយោគ ម្ចាស់ភាគហ៊ុន ក្រុមព្រឹក្សាភិបាល បុគ្គលិករបស់អម្រឹត អង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតត្រូវមានផ្លាសសញ្ញាពីរ (មួយជាអក្សរខ្មែរ និងមួយទៀតជាអក្សរឡាតាំង) ដែលអត្តសញ្ញាណ និងអត្ថន័យតែមួយដូចគ្នាទាំងស្រុង ។

ផ្លាកសញ្ញាជាអក្សរខ្មែរ ផ្លាកសញ្ញាជាអក្សរអង់គ្លេស

➢ អត្ថន័យនៃឈ្មោះ បាវចនា និងផ្លាកសញ្ញា

- **អម្រឹត** : មានអត្ថន័យចំជាភាសាខ្មែរ" ភាពយូអង្វែង មិនចេះស្លាប់ ឬជាទឹកទិព្វ និងមានន័យជាទំនៀមទំលាប់ថា ភាពរីកចំរើន និងត្រជាក់ត្រជុំ" ។

- **នៅជាមួយអ្នកដើម្បីអ្នក** : បង្ហាញពីតម្លៃ និងទំនាក់ទំនងជិតស្និតរវាង អម្រឹត ជាមួយអតិថិជនតាមរយៈការផ្តល់ និងការបំរើសេវាជូនពួកគាត់ជានិរន្តរ៍ក្នុងគោបំណងជួយលើស្ទួយកម្រិតជីវភាពរបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើង។

- **សញ្ញាស្នាមញញឹមដែលភ្ជាប់ពីជើង" ត" នៃឈ្មោះអម្រឹត** : សញ្ញានេះបង្ហាញពីទំនាក់ទំនងរវាងភាពជោគជ័យឬភាពរីករាយរបស់អតិថិជនទៅនិងសេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថាន "អម្រឹត"

➢ អត្ថន័យនៃពណ៌លើផ្លាកសញ្ញា

- **ពណ៌បៃតង** : តំណាងឲ្យភាពស្រស់ស្រាយ របស់អតិថិជនក្នុងការប្រើប្រាស់សេវា

ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន" អម្រឹត" ។

- **ពណ៌មាស** : តំណាងឲ្យសមិទ្ធផលដ៏ត្រចះត្រចង់ដែល អតិថិជនទទួលបានពីការវិនិយោគរបស់ខ្លួន។

២.៥ ទីតាំងភូមិសាស្ត្រ និងតំបន់ប្រតិបត្តិការរបស់អម្រឹតសាខាបាទី

រូបទី១: ទីតាំងភូមិសាស្ត្ររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាទីមានទីតាំងស្ថិតនៅ ភូមិចក ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ។

២.៦ ទស្សន: និងបេសកកម្មរបស់ អម្រឹត

- **ទស្សន:**

ជាស្ថានប័នហិរញ្ញវត្ថុឈានមុខដែលរួមចំណែកក្នុងការកែលម្អជីវភាពប្រជាពលរដ្ឋ ឲ្យល្អប្រសើរ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជា។

- **បេសកកម្ម**

ផ្តល់សេវាហិរញ្ញវត្ថុ ច្រើនប្រភេទដល់ប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលទាប និងសហគ្រាសខ្នាតតូចបំផុត តូច និងមធ្យម ដោយធានាបាននូវលទ្ធផលប្រតិបត្តិការកម្រិតខ្ពស់ផ្នែកហិរញ្ញវត្ថុនិងសង្គម។

លទ្ធផលប្រតិបត្តិការកំរិតខ្ពស់ផ្នែកហិរញ្ញវត្ថុ និងសង្គមមានន័យថាប្រសិទ្ធិភាពក្នុងការស្វែងរកអត្រាការប្រាក់ចំនេញខ្ពស់ធៀបនឹងដើមទុនទ្រព្យម្ចាស់ ឬទ្រព្យសកម្ម ។ ទន្ទឹមនឹងនោះក៏ត្រូវរក្សាឲ្យបាននូវការផ្តល់សេវាកម្មហិរញ្ញវត្ថុដែលមានដល់ដៃអតិថិជនគោលដៅឲ្យបានច្រើន ដើម្បីឲ្យពួកគាត់មានថាមពល និងលទ្ធភាពលើកកំពស់ជីវភាពរស់នៅពោលគឺ មានការកែលំអរជាបន្តបន្ទាប់

លើមុខរបរ អាហារទទួលទាន ទីជំរកសំលៀកបំពាក់ ការថែទាំសុខភាព ការអប់រំ ការសំរាកលំហែ ឧបករណ៍ប្រើប្រាស់ និងមធ្យោបាយផលិតកម្មផ្សេងៗទៀតជាដើម ។

- **ចក្ខុវិស័យ**

រួមចំណែកអភិវឌ្ឍន៍ជនបទក្នុងគោលបំណងដើម្បីធ្វើឲ្យកម្រិតជីវភាពរបស់ប្រជាជន កាន់តែប្រសើរឡើង ។

- **គោលដៅ**

- ពង្រីកខ្លួនទៅតំបន់ដែលជាប់នឹងតំបន់ប្រតិបត្តិការដែលមានស្រាប់
- បង្កើនទុន ៥0% នៃទុនឆ្នាំចាស់
- ការពារ និងថែរក្សាអតិថិជនដែលមានស្រាប់
- បង្កើតផលិតផល និងសេវាហិរញ្ញវត្ថុថ្មី
- កែប្រែគោលនយោបាយធនធានមនុស្សឲ្យមានលក្ខណៈប្រកួតប្រជែង ។

២.៧ ទម្លាប់ធម៌រួមរបស់អម្រឹត

- **និយមន័យ**

វប្បធម៌រួម របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **អម្រឹត** គឺជាជំនឿ តម្លៃ និងទំលាប់ ដែលកំណត់ឡើងដោយគ្រឹះស្ថាន ហើយត្រូវបានបុគ្គលិក យល់ថាគួរតែគោរព និងអនុវត្តន៍

- **គោលបំណងនៃការកសាងវប្បធម៌រួម**

- ចង់ឲ្យបុគ្គលិកធ្វើការក្នុងទិសដៅរួមគ្នា និងដោយស្រុះស្រួលគ្នា
- ដើម្បីជាប្រទីបមួយសំរាប់បុគ្គលិករៀបចំ និងកសាងលក្ខណៈសម្បត្តិរបស់ខ្លួន
- ចង់រក្សាលំនឹងសតិអារម្មណ៍បុគ្គលិកនៅពេល អម្រឹត ប្រឈមមុខនឹងការធ្វើសេចក្តីសម្រេចចិត្តធំៗ

- ចង់បង្កើតឲ្យមានចរិកលក្ខណៈសម្បត្តិសំខាន់ៗមួយចំនួនសម្រាប់បុគ្គលិកទូទៅ
- ធ្វើជាមូលដ្ឋានក្នុងការជ្រើសរើសរាយតម្លៃបេក្ខជនថ្មីចូលមកក្នុង អម្រឹត ។

- **ខ្លឹមសារវប្បធម៌រួម**

ខ្លឹមសារខាងក្រោមនេះត្រូវបានកសាងឡើងតាមរយៈការចូលរួមរបស់បុគ្គលិក អម្រឹតគឺដោយផ្អែកលើបទពិសោធន៍ ទំនៀមទំលាប់ប្រពៃណីព្រមទាំងស្របទៅនឹងតម្រូវការ។

<u>វប្បធម៌រួមអម្រឹត</u> (Amret Corporate Culture)

វប្បធម៌រួម របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **អម្រឹត** គឺជាជំនឿ តម្លៃ និងទំលាប់ ដែលកំណត់

ឡើងដោយគ្រឹះស្ថាន ហើយត្រូវបានបុគ្គលិក យល់ថាគួរតែគោរព និងអនុវត្តតាមAmret Corporate Culture is the belive, value, and characteristics established by Amret itself and followed and implemented by all of member

- **ភាពស្មោះត្រង់** ជាតម្រូវការចាំបាច់របស់ **អម្រឹត**
- **ទំនាក់ទំនងល្អ** ប្រកបដោយសេចក្តីថ្លៃថ្នូររវាងបុគ្គលិក និងផ្នែកខាងក្រៅ
- **ការលះបង់ខ្ពស់ ចំពោះការងារ** ជាគុណសម្បត្តិដ៏ធំមួយ របស់បុគ្គលិកឆ្នើម
- **មានតម្លាភាព** ធ្វើឲ្យយើងទុកចិត្តគ្នា
- **ការសម្រេចចិត្ត** ភាគច្រើនត្រូវធ្វើឡើងតាមរយៈការចូលរួមយោបល់
- **ភាពទៀងទាត់ និងម៉ឺងម៉ាត់** ជាជំហររបស់បុគ្គលិក
- **មិនបក្សពួកនិយម ឬគ្រួសារនិយម** ធ្វើឲ្យមានល្បាយស្មើភាពក្នុងស្ថាប័ន
- **សីលធម៌រស់នៅល្អ** នាំមកនូវសេចក្តីថ្លៃថ្នូរ
- **សមត្ថភាព និងគុណភាព ក្នុងការងារ** គឺការបង្ហាញស្នាដៃរបស់បុគ្គលិក
- **សន្សំសំចៃ និងថែរក្សាសម្បត្តិរួម** ជាការរួមចំណែកកាត់បន្ថយចំណាយ
- **មិនប្រកាន់ខ្លួន និង មើលបំណាំគ្នា** ជាកត្តាធានាសន្ទុះការងារ ។

២.៨ រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី

អម្រឹតមានរចនាសម្ព័ន្ធក្នុងការគ្រប់គ្រងអង្គភាពរបស់ខ្លួនដូចខាងក្រោម៖



២.៩ ផលិតផល និងសេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី

សព្វថ្ងៃនេះនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលបាននឹងកំពុងធ្វើប្រតិបត្តិការរបស់ខ្លួនទៅលើសេវាកម្មចំនួនបីគឺ សេវាឥណទាន សេវាប្រាក់សន្សំ និង សេវាផ្ទេរប្រាក់ ដែលកំពុងប្រតិបត្តិការ ។

❖ **សេវាផ្ទេរប្រាក់** គឺជាការផ្ទេរប្រាក់ពីគណនីមួយទៅគណនីមួយទៀត ។

❖ **សេវាឥណទាន** គឺជាប្រភពធនធានហិរញ្ញវត្ថុ ដែលផ្តល់ដោយគ្រឹះស្ថានដល់អតិថិជនតាមរយៈការខ្ចីដោយប្រយោល ឬផ្ទាល់ ហើយត្រូវសងត្រឡប់មកវិញតាមកាលបរិច្ឆេទជាក់លាក់នាពេលអនាគត ។

ចំពោះសេវាឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតមាន

➢ <u>ឥណទានក្រុមធានា</u> គឺជាប្រភេទឥណទានខ្នាតតូចបំផុត ដែលផ្តល់ជូនជាប្រាក់រៀល ដល់ប្រជាពលរដ្ឋនៅតាមជនបទ សម្រាប់ប្រើប្រាស់លើមុខរបរអាជីវកម្មទូទៅនៅក្នុងគ្រួសារ ក្នុងគោលបំណងលើកស្ទួយកម្រិតជីវភាពគ្រួសារឲ្យកាន់ទេប្រសើរឡើង ។

✓ ឥណទានក្រុមឯករាជ្យ គឺជាប្រភេទឥណទានក្រុមធានាមួយផ្សេងទៀត ដែលត្រូវបានបង្កើតោឡើងសម្រាប់អតិថិជនដែលចង់ខ្ចីឥណទានក្រុមធានារបស់ អម្រឹតដែលមានលក្ខណៈជាក្រុមដាច់ដោយឡែកពីគ្នា ។

➢ <u>ឥណទានបុគ្គល</u> គឺជាប្រភេទឥណទានដែលផ្តល់ជូនជាប្រាក់រៀល ឬដុល្លា ដល់ប្រជាពលរដ្ឋ សម្រាប់ប្រើប្រាស់លើមុខរបរអាជីវកម្មរបស់ខ្លួន ។

✓ ឥណទានសម្ភារៈប្រើប្រាស់ គឺជាប្រភេទសេវាប្រាក់កម្ចី ដែលផ្តល់ជូនជាលក្ខណៈបុគ្គលដល់អតិថិជនដែលមានគោលបំនងចង់ទិញឧបករណ៍ ឬសម្ភារៈប្រើប្រាស់ក្នុងផ្ទះឬផ្ទាល់ខ្លួន។

✓ ឥណទានកែលម្អគេហដ្ឋាន គឺជាសេវាប្រាក់កម្ចី ដែលផ្តល់ជូនអតិថិជនជាលក្ខណៈបុគ្គល ជាមួយនឹងទុនជាពិសេសសម្រាប់ការជួសជុល កែលម្អ ឬពង្រីលំនៅដ្ឋាន ។

✓ ឥណទានអាជីវកម្ម គឺជាប្រភេទសេវាប្រាក់កម្ចីខ្នាតតូច និងមធ្យោបាយដែលផ្តល់ជូនជាលក្ខណៈបុគ្គលដល់អតិថិជនដែលមានចំណងប្រើប្រាស់ប្រាក់កម្ចីនេះ សម្រាប់ធ្វើជាដើមទុនដើម្បីបង្កើនមុខរបរថ្មី ឬពង្រីកអាជីវកម្មរបស់ខ្លួនដែលមានស្រាប់ ។

✓ ឥណទានឡជីវឧស្ម័ន គឺជាសេវាប្រាក់កម្ចីដែលផ្តល់ជូនជាលក្ខណៈបុគ្គល ចំពោះអតិថិជនដែលមានបំណងចង់សាងសង់ឡជីវឧស្ម័ន ដើម្បីធ្វើឲ្យជីវភាពគ្រួសារកាន់តែប្រសើរឡើង និងចូលរួមចំណែកក្នុងការកាត់បន្ថយការបំពុល និងការបំផ្លាញបរិស្ថាន ។

❖ **សេវាប្រាក់បញ្ញើ** គឺជាសេវាទទួលធានារ៉ាប់រង ថែរក្សា គ្រប់គ្រង ឬ ចាត់ចែងសាច់ប្រាក់ដែលអតិថិជនបានផ្ញើរ ឬ តម្កល់តាមរយៈគណនីជាមួយគ្រឹះស្ថាន ។

➢ គណនីរីករាយ គឺជាមធ្យោបាយសាមញ្ញមួយ ដែលផ្តល់ភាពងាយស្រួលដល់លោកអ្នកក្នុងការដាក់ប្រាក់សន្សំ និងដកប្រាក់គ្រប់ពេលវេលាទៅតាមតម្រូវការ ។

➢ គណនីប្រាថ្នា គឺជាប្រភេទគណនីប្រាក់បញ្ញើដែលមានកិច្ចសន្យា និងផែនការសន្សំច្បាស់លាស់ ដោយគ្រាន់តែដាក់ប្រាក់តម្កល់បន្តិចបន្តួចទៅតាមផែនការតែប៉ុណ្ណោះ ។

➢ គណនីកើនទ្រព្យ គឺជាវិធីសន្សំដែលធ្វើឲ្យទឹកប្រាក់របស់លោកអ្នកកើនឡើងជានិច្ច

➢ គណនីពាណិជ្ជ គឺជាមធ្យោបាយងាយស្រួលមួយ សម្រាប់ក្រុមហ៊ុនេកជន សហគ្រាសខ្នាតតូច និងមធ្យម អង្គភាពអភិវឌ្ឍន៍ ក្នុងការចាត់ចែងសាច់ប្រាក់សម្រាប់ដំណើរការអាជីវកម្ម ។

ជំពូក៣

ការគ្រប់គ្រងឥណទាន

ខ្លាតតូចរបស់

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

អម្រឹត សាខាបាធី

ជំពូកទី ៣

ការគ្រប់គ្រងឥណទានខ្នាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី

៣.១ លក្ខណៈទូទៅនៃឥណទានខ្នាតតូច

៣.១.១ និយមន័យ

ឥណទានខ្នាតតូច គឺជាប្រភេទឥណទានមួយដែលផ្តល់កម្ចីជូនប្រជាពលរដ្ឋក្នុងទំហំមួយតូចដើម្បី ជួយកែលំអរដល់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត ។

៣.១.២ ទំហំ និងអត្រាការប្រាក់

៣.១.២.១ ឥណទានក្រុមធានា SC (Solidarity Credit)

ឥណទានក្រុមធានា គឺជាប្រភេទឥណទានខ្នាតតូចបំផុតជាប្រាក់រៀលដែលមិនតម្រូវឲ្យតំកល់ទ្រព្យបញ្ចាំទេ ប៉ុន្តែត្រូវមានការធានាក្នុងក្រុមសម្រាប់ការសងឥណទាន ។ ហើយវាក៏ជាផលិតផលហិរញ្ញវត្ថុលើកដំបូងដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត បានផ្តល់ចាប់តាំងពីឆ្នាំ ១៩៩១ មកម្លេះ ដោយធ្វើការសាកល្បងនៅក្នុងភូមិមួយចំនួនក្នុងខេត្តព្រៃវែង ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ដែលជាគំនិតផ្តួចផ្តើមរបស់អង្គការ ប្រ្គេត (GRET) ។ ការដាក់គំរោងនេះទៅឃើញថាទទួលបានជោគជ័យ ១០០ ភាគរយដោយមានការគាំទ្រយ៉ាងច្រើនពីសំណាកអតិថិជនដែលបានប្រើប្រាស់ប្រភេទឥណទានក្រុមធានានេះ ។

ប្រភេទឥណទានក្រុមធានាត្រូវបានបង្កើតដោយការជួបជុំជាមួយអតិថិជនគោលដៅ ដែលរស់នៅនៅក្នុងទីជនបទ និងតំបន់ដាច់ស្រយាលក្រីក្រ ហើយគោលការណ៍ និងលក្ខខ័ណ្ឌនៃឥណទានក្រុមធានានេះទាមទារឲ្យអតិថិជនបំពេញនៅកត្តាមួយចំនួន ដើម្បីទទួលបានកម្ចីនេះ ។

ចំពោះកំពស់ទុនអតិថិជនអាចស្នើសុំខ្ចីទឹកប្រាក់ ចាប់ពី ១០០,០០០ រៀល រហូតដល់ ២,០០០,០០០ រៀល សំរាប់រយៈពេលពី ៦ខែ ទៅ ១២ខែ ដែលមានអត្រាការប្រាក់ ៣% ។

៣.១.២.២ ឥណទានបុគ្គល IC (Individual Credit)

ឥណទានបុគ្គល គឺជាប្រភេទឥណទានប្រាក់រៀល និងដុល្លារអាមេរិកដែលមានកំពស់ទុនច្រើនជាងឥណទានក្រុមធានា ហើយតម្រូវឲ្យអតិថិជនមានទ្រព្យបញ្ចាំសម្រាប់ដាក់តំកល់ធានាបំណុល ។ ហើយបន្ទាប់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាខេត្តបានចាប់ផ្តើមបើកសេវាកម្មផ្នែកឥណទានក្រុមធានា (Solidaritty Credit) នៅឆ្នាំ ១៩៩១ មកឃើញថាតម្រូវការរបស់អតិថិជនចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃនោះ ធ្វើឲ្យឥណទានក្រុមធានាមិនអាចផ្តល់ទៅតាម

តម្រូវការរបស់អតិថិជនបានឡើយ ។ ព្រោះថាឥណទានទី ១ មានទឹកប្រាក់កម្រិតទាប ណាមួយត្រូវរកគ្នាឲ្យបានគ្រប់ចំនួនដើម្បីចងក្រងគ្នាជាក្រុមទើបអាចទទួលបានឥណទាន ។ មិនតែប៉ុណ្ណោះទេសមាជិកត្រូវតែធានាគ្នាទៅវិញទៅមកហើយសន្យាសងជំនួសគ្នា ប្រសិនបើមានសមាជិកណាម្នាក់មិនសង ឬគេចវេសពីបំណុលនោះ ។ ពេលខ្លះអតិថិជនមួយចំនួនមិនសូវមានតម្រូវការចាំបាច់ទេ តែបែរជាមកធានាឲ្យអ្នកដទៃទៅវិញ ដូច្នេះដើម្បីកែខ្លួនរបញ្ហាដែលជួបប្រទះនេះទើបគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាខេត្តបានចាប់ផ្តើមបង្កើតនូវឥណទានបុគ្គល (Individual Credit) មួយប្រភេទបន្ថែមទៀតដើម្បីបំពេញនូវសេចក្តីត្រូវការរបស់អតិថិជន ។ ហើយប្រភេទឥណទានបុគ្គលនេះបានផ្តល់ភាពងាយស្រួលដល់អតិថិជនដូចជា មានភាពលឿនរហ័សទាន់ចិត្តដោយមិនចាំបាច់ប្រមូលគ្នាជាក្រុមដូចឥណទានក្រុមធានាឡើយ ម៉្យាងទៀតចំពោះទំហំឥណទានវិញក៏មានទំហំធំជាងឥណទានក្រុមធានាដែរ ។

ចំពោះកំពស់ទុនអតិថិជនអាចស្នើសុំខ្ចីទឹកប្រាក់ចាប់ពី ១,០០០,០០០ រៀល រហូតដល់ ២០០,០០០,០០០ រៀល ឬចាប់ពី ១០០ដុល្លារ រហូតដល់ ៥០,០០០ ដុល្លារ ហើយចំពោះអត្រាការ គឺអាស្រ័យទៅតាមកំពស់ទុនជាក់ស្តែងដែលអតិថិជនសុំខ្ចី ដែលមានរយៈពេលចាប់ពី ៣ខែ រហូតដល់ ៤៨ខែ យ៉ាងយូរបំផុត ។

<u>អត្រាការប្រាក់</u>

ការកំណត់អត្រាការប្រាក់ គឺអាចមានការផ្លាស់ប្តូរដោយយោងទៅតាមយុទ្ធសាស្ត្រទីផ្សាររបស់ អម្រឹត ។ ដោយឡែកអត្រាការប្រាក់ឥណទានបុគ្គលបច្ចុប្បន្ន គឺត្រូវការកំណត់ទៅតាមប្រភេទនៃទំហំឥណទានដូចខាងក្រោម៖

- **បេឡាឥណទានភូមិ**

- ឥណទានបុគ្គល (រៀល): ការផ្តល់កម្ចីចាប់ពី៖
  ១,០០០,០០០ ដល់ ៤,០០០,០០០ អត្រាការប្រាក់ចន្លោះ ២.៨០% ទៅ ៣%
  ៤,០០០,១០០ ដល់ ៨,០០០,០០០ អត្រាការប្រាក់ចន្លោះ ២.២០% ទៅ ២.៧០%
  ៨,០០០,១០០ ដល់ ២០,០០០០០ អត្រាការប្រាក់ចន្លោះ ២% ទៅ ២.១០%
  ២០,០០០,១០០ ដល់ ៦០,០០០,០០០ អត្រាការប្រាក់ចន្លោះ ១.៨០% ទៅ ១.៩០%
- ឥណទានបុគ្គល (ដុល្លា): ការផ្តល់កម្ចីចាប់ពី៖
  ១០០ ដល់ ១.៥០០ អត្រាការប្រាក់ចន្លោះ ២.៦៥% ទៅ ២.៧៥%
  ១.៥០១ ដល់ ៣.០០០ អត្រាការប្រាក់ចន្លោះ ១.៩៥% ទៅ ២.០៩%

៣.០០១ ដល់ ១០.០០០ អត្រាការប្រាក់ចន្លោះ ១.៨៥% ទៅ ១.៩៥%

១០.០០១ ដល់ ១៥.០០០ អត្រាការប្រាក់ចន្លោះ ១.៧០%

- **បេឡាឥណទានទីស្នាក់ការ**

- ឥណទានបុគ្គល (រៀល): ការផ្តល់កម្ចីចាប់ពីៈ

  ១,០០០,០០០ ដល់ ៤,០០០,០០០ អត្រាការប្រាក់ចន្លោះ ២.៥០%

  ៤,០០០,១០០ ដល់ ៨,០០០,០០០ អត្រាការប្រាក់ចន្លោះ ២.២០% ទៅ ២.៤០%

  ៨,០០០,១០០ ដល់ ២០,០០០០០ អត្រាការប្រាក់ចន្លោះ ១.៩០% ទៅ ២%

  ២០,០០០,១០០ ដល់ ៦០,០០០,០០០ អត្រាការប្រាក់ចន្លោះ ១.៧០% ទៅ ១.៨០%

  ៦០,០០០,១០០ ដល់ ៨០,០០០,០០០ អត្រាការប្រាក់ចន្លោះ ១.៦០% ទៅ ៣%

- ឥណទានបុគ្គល (ដុល្លា): ការផ្តល់កម្ចីចាប់ពីៈ

  ១០០ ដល់ ១.៥០០ អត្រាការប្រាក់ចន្លោះ ២.៤៥%

  ១.៥០១ ដល់ ៣.០០០ អត្រាការប្រាក់ចន្លោះ ១.៧៥% ទៅ ១.៨៥%

  ៣.០០១ ដល់ ១០.០០០ អត្រាការប្រាក់ចន្លោះ ១.៥៥% ទៅ ១.៦៥%

  ១០.០០១ ដល់ ២០.០០០ អត្រាការប្រាក់ចន្លោះ ១.៤០% ទៅ ១.៥០%

៣.១.៣ គោលបំណងនៃការផ្តល់ឥណទានខ្លាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតបានផ្តល់សេវាហិរញ្ញវត្ថុជាច្រើនប្រភេទដល់ប្រជាពលរដ្ឋក្នុងគោលបំណង ៖

- លើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋ និងកង្វះខាត
- តាមគោលបំណងដែលប្រជាពលរដ្ឋបានស្នើ ។

៣.២ គោលការណ៍ឥណទាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាខេត្តដែលកំពុងតែប្រតិបត្តិការ គឺមានការគាំទ្រ និងពេញនិយមពីប្រជាជនដែលប្រើប្រាស់សេវាឥណទាន ហើយឥណទានដែលកំពុងតែប្រតិបត្តិការនោះមាន ពីរប្រភេទ

៣.២.១ គោលការណ៍ឥណទានក្រុមធានា SC (Solidarity Credit)

គោលការណ៍របស់ឥណទានក្រុមធានា គឺតម្រូវឲ្យមានសមាជិកចំនួនពី ៣ ទៅ ៦នាក់ ដើម្បីធានាគ្នាទៅវិញទៅមកសម្រាប់ការទទួលបានកម្ចី និងមានរយៈពេលស្មើៗគ្នា ប្រសិនបើមានករណីនរណាម្នាក់មិនសង ឬ គេចវេសបាត់នោះសមាជិកដទៃនឹងចេញសងជំនួស ។ ហើយ

សមាជិកក្រុមធានាទាំងអស់ត្រូវតែមានទីលំនៅរបស់ខ្លួននៅក្នុងតំបន់ប្រតិបត្តិការរបស់ អម្រឹត ។

ក្នុងគោលការណ៍ឥណទានក្រុមធានានេះមានពីរចំណុចគឺ៖

❖ **លក្ខខ័ណ្ឌនៃការខ្ចីឥណទាន**

នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតបានចងក្រងជាច្បាប់ ឬលក្ខខ័ណ្ឌផ្សេងៗទៀតដើម្បីឲ្យគ្រប់សាខា ខេត្ត-ក្រុងទាំងអស់គោរព និងអនុវត្តន៍ ។ លក្ខខ័ណ្ឌទាំងអស់នោះបានចែងយ៉ាងច្បាស់លាស់សម្រាប់ប្រភេទផលិតផលនីមួយៗ ។ នេះជាប្រភេទផលិតផលឥណទានក្រុមធានាដែលមានលក្ខខ័ណ្ឌដូចខាងក្រោម ៖

- ត្រូវមានសមាជិកចំនួនពី ៣ ទៅ ៦នាក់ហើយក្នុងសមាជិកទាំងនោះត្រូវហ៊ានទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក
- ចំពោះពេលវេលាដែលអនុញ្ញាតឲ្យខ្ចីនោះគឺចន្លោះពី ៦ ទៅ ១២ខែប៉ុណ្ណោះ
- អត្រាការប្រាក់ ៣%
- ហើយការទូទាត់មានលក្ខណៈ ៣យ៉ាង

  ទី១: ការប្រាក់ត្រូវបង់រាល់ខែ

  ទី២: ការបង់រំលោះប្រចាំខែលើប្រាក់ដើម និងការប្រាក់

  ទី៣: ការបង់រំលោះប្រាក់ដើមគិតជាភាគរយ (% ដើម) ។

❖ **នីតិវិធីផ្តល់ឥណទាន**

មានដំណាក់កាលជាច្រើនក្នុងការបង្កើតសមាគមន៍ភូមិថ្មីដូចខាងក្រោម ៖

ដំណាក់កាលទី១: ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន

ដំណាក់កាលទី២: ការវាយតម្លៃភូមិ

ដំណាក់កាលទី៣: ការប្រជុំរួម

ដំណាក់កាលទី៤: ការពិភាក្សាតាមគ្រួសារ

ដំណាក់កាលទី៥: ការពិភាក្សាតាមក្រុម

ដំណាក់កាលទី៦: ការបង្កើតនូវគណៈកម្មាឥណទាន

ដំណាក់កាលទី៧: ការបើកប្រាក់ជូនសមាជិក

៣.២.២ គោលការណ៍ឥណទានបុគ្គល IC (Indivindual Credit)

នៅក្នុងឥណទានបុគ្គល (Individual Credit) ក៏ត្រូវបានបែងចែកជាពីរចំណុចដែរគឺ៖

❖ **លក្ខខ័ណ្ឌនៃកម្ចីឥណទាន**

លក្ខខ័ណ្ឌនៃកម្ចីឥណទានបុគ្គលវាមានលក្ខណៈប្រហាក់ប្រហែល ទៅនឹងលក្ខខ័ណ្ឌនៃកម្ចីឥណទានក្រុមធានាដែរគ្រាន់តែបន្ថែមលើចំណុចខ្លះៗទៀតដើម្បីធានាឲ្យមានសុក្រឹតភាព ដែលចំណុចទាំងនោះរួមមានដូចខាងក្រោមនេះ ៖

ទី១: កម្ចីត្រូវភ្ជាប់មកជាមួយដោយវត្ថុបញ្ចាំ ឬអ្នកធានាហើយអនុញ្ញាតឲ្យខ្ចីស្មើនឹង ៧៥% នៃតម្លៃជាក់ស្តែង ។

ទី២: រយៈពេលពី ៣ខែ រហូតដល់ ៥៨ខែ យ៉ាងយូរបំផុត

ទី៣: កំពស់ទុនចាប់ពី ១,០០០,០០០ រៀលរហូតដល់ ២០០,០០០,០០០រៀល ឬ១០០ ដុល្លារ រហូតដល់ ៥០,០០០ ដុល្លារ

ទី៤: ចំពោះអត្រាការប្រាក់វិញគឺអាស្រ័យទៅតាមបរិមាណនៃកម្ចី

ទី៥: ការទូទាត់គឺបង់រំលោះប្រចាំខែលើការប្រាក់ និងប្រាក់ដើម

ទី៦: ការជាកពិន័យក្នុងករណីធ្វើការទូទាត់យឺតយ៉ាវ ។

❖ **នីតិវិធីនៃការផ្តល់ឥណទាន**

នៅត្រង់ចំណុចនេះមានសកម្មភាពជាច្រើនដូចជា

- ការផ្សព្វផ្សាយរបស់ភ្នាក់ងារឥណទាន
- ការដាក់សំណើរបស់អតិថិជនដល់ភ្នាក់ងារឥណទាន
- ការចុះសិក្សាសំណើ និងបំពេញបែបបទជាមួយអ្នកខ្ចី
- ការប្រជុំគណៈកម្មាការឥណទានបុគ្គល ។

៣.៣ សកម្មភាពអនុវត្តន៍ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលកំពុងតែអនុវត្តន៍ការងារផ្តល់កម្ចីសព្វថ្ងៃគឺដោយឈរទៅលើសកម្មភាពចំនួន បី គឺ សកម្មភាពមុនពេលទំលាក់ទុន សកម្មភាពពេលទំលាក់ទុន និងសកម្មភាពក្រោយពេលទំលាក់ទុន ដែលកំពុងតែប្រតិបត្តិការនៅគ្រប់សាខាខេត្ត-ក្រុង ។

៣.៣.១ សកម្មភាពមុនពេលទំលាក់ទុន

ជាបឋមមុននឹងសម្រេចចិត្តផ្តល់ឥណទានដល់អតិថិជនណាមួយនោះ ត្រូវសង្កេតឲ្យបានគ្រប់ជ្រុងជ្រោយដើម្បីជៀសវាងការផ្តល់ឥណទានទៅខុសគោលដៅ ។ ដូច្នេះហើយនៅក្នុង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត បានអនុវត្តន៍ទៅលើគោលការណ៍ដែលបានដាក់ចេញនូវសកម្មភាព បីយ៉ាងនេះ ក្នុងគោលបំណងគ្រប់គ្រងឥណទានឲ្យមានប្រសិទ្ធិភាព និងភាពជោគជ័យខ្ពស់បំផុត ។ ហើយសកម្មភាពទាំងនោះមិនមែនផ្តោតទៅលើតែផលិតផលណាមួយប៉ុណ្ណោះទេ គឺផ្តោតទៅលើទាំងឥណទានក្រុមធានា និង ឥណទានបុគ្គល ។

៣.៣.១.១ ឥណទានក្រុមធានា

សកម្មភាពមុនពេលទំលាក់ទុនរបស់ឥណទានក្រុមធានា ដែលកំពុងតែប្រតិបត្តិការសព្វថ្ងៃនេះត្រូវបានបែងចែកជាពីរ ផ្នែក គឺ ផ្នែកទី១: បើកបេឡាឥណទានថ្មី និងផ្នែកទី២: បេឡាមានស្រាប់

- **ផ្នែកទី១**: បើកបេឡាឥណទានថ្មី គឺជាសមាគមន៍ឥណទានដែលបានបង្កើតឡើងដោយប្រជាជនក្រុមណាមួយក្រោមការជួយគំនិតផ្តួចផ្តើមរបស់ភ្នាក់ងារឥណទាននៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ។ ដើម្បីបើកបេឡាឥណទានភូមិបាននៅក្នុងតំបន់ឬទីតាំងណាមួយនោះវាត្រូវចំណាយពេលវេលាយ៉ាងយូរហើយនឹងត្រូវអនុវត្តន៍តាមដំណាក់កាលដូចខាងក្រោម៖

<u>ដំណាក់កាលទី១</u> ការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន: នៅត្រង់ចំណុចនេះគឺជាកត្តាសំខាន់ណាស់សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលត្រូវជ្រើសរើសបុគ្គលិកណាដែលមានបទពិសោធន៍ និងទេព្យកោសល្យក្នុងការទំនាក់ទំនង ។ ផ្ទុយទៅវិញកាលណាបើយើងឲ្យបុគ្គលិកណាមួយដែលគ្មានភាពវៃឆ្លាតទេនោះប្រាកដជាមានភាពលំបាកក្នុងកិច្ចការនោះ ព្រោះថាកិច្ចការនោះវាមានការពាក់ព័ន្ធទៅដល់នាយកប្រតិបត្តិ ឬប្រធានសាខាខេត្ត ប្រធានសាខាស្រុក ឬអនុប្រធានសាខាស្រុក ឬក៏ភ្នាក់ងារឥណទាន ។ ការទំនាក់ទំនងនេះក្នុងគោលបំណងដើម្បី ៖

- ឧទ្ទេសនាមអំពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត
- ស្នើសុំការអនុញ្ញាត និងការសហការ
- សាកសួរពត៌មានអំពីសេដ្ឋកិច្ច ស្ថិត្តិប្រជាជន និងសន្តិសុខក្នុងតំបន់
- សាកសួរអំពីឥណទានរបស់អង្គភាពផ្សេងៗ ។

<u>ដំណាក់កាលទី២</u> ការវាយតម្លៃភូមិ: គឺជាការឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងរបស់ប្រជាជនដែលរស់នៅក្នុងភូមិនោះ ក្នុងការសម្រេចចិត្តផ្តល់ឥណទាន ឬ មិនគួរផ្តល់ដើម្បីជៀសវាងការផ្តល់ឥណទានខុសទិសដៅ ។

ការវាយតម្លៃភូមិណាមួយបានភ្នាក់ងារឥណទានត្រូវប្រើតារាងវាយតម្លៃភូមិ៖

ហើយចំណុចដែលទាក់ទងនឹងការវាយតម្លៃភូមិមានដូចជា

- ទីតាំងភូមិសាស្ត្រ: ដីធ្លី ធារាសាស្ត្រ ទីផ្សារ ទីផ្សារ ផ្លូវគមនាគមន៍

- សេដ្ឋកិច្ច: ស្ថានភាពសេដ្ឋកិច្ចនៅក្នុងភូមិកម្រិតជីវភាពរបស់ប្រជាជន និងមុខរបរចិញ្ចឹមជីវិតក្នុងភូមិ
- ប្រជាសាស្ត្រ: អត្តចរិតប្រជាជន អ្នកភូមិកំណើត អ្នកចំណូលថ្មី
- សហគមន៍: រវាងប្រជាជន និងរដ្ឋអំណាចមានការសហការគ្នា ឬ អត់
- រដ្ឋអំណាច: មានសិទ្ធិអំណាចពេញលេញក្នុងការដោះស្រាយបញ្ហាឲ្យប្រជាជនឬទេ
- ទំនៀមទំលាប់មិនល្អ: មានល្បែងអបាយមុខបីប្រការ គឺ ស្រី ស្រា ល្បែងជាដើម ។

បន្ទាប់ពីបានធ្វើការវាយតម្លៃគ្រប់ចំណុចទាំងអស់ខាងលើរួច ត្រូវធ្វើការប្រៀបធៀបលទ្ធផលជាមួយលក្ខខ័ណ្ឌដើម្បីធ្វើការផ្ទៀងផ្ទាត់ឃើញថាជាចំណុចវិជ្ជមាន ឬ អវិជ្ជមានទើបធ្វើការសម្រេចចិត្តផ្តល់ឥណទាន ឬមិនគួរផ្តល់ ។

លក្ខខ័ណ្ឌមានដូចខាងក្រោម៖

0< x ≤ ៥0 ⇨ ខ្សោយ ⇨ មិនអាចធ្វើឥណទានបានទេ

៥0< x ≤ ៦៥ ⇨ មធ្យម ⇨ អាចធ្វើឥណទានបាន តែត្រូវប្រុងប្រយ័ត្ន

៦៥< x ≤ ៨0 ⇨ ល្អបង្គួរ ⇨ អាចផ្តល់ឥណទានបាន

៨0< x ≤ ១00 ⇨ ល្អណាស់ ⇨ ផ្តល់ឥណទានបាន

✍ ចំណាំ: x ជាពិន្ទុមធ្យមភាគ

ក្រោយពីផ្ទៀងផ្ទាត់ទៅលើលទ្ធផលរួចហើយភ្នាក់ងារឥណទាន ត្រូវប្រគល់តារាងវាយតម្លៃភូមិទៅឲ្យប្រធានសាខាស្រុកដើម្បីត្រួតពិនិត្យ និងរក្សាទុកជាឯកសារព្រមទាំងទុកសម្រាប់ឲ្យអ្នកគ្រប់គ្រងខេត្ត ឬអ្នកផ្សេងៗទៀត ដែលការពាក់ព័ន្ធដើម្បីត្រួតពិនិត្យនៅពេលត្រូវការ ។

<u>ដំណាក់កាលទី៣</u> ការប្រជុំរួម: នៅត្រង់ចំណុចនេះធ្វើឡើងដើម្បីពន្យល់បង្ហើរបង្ហាញដល់ប្រជាជនទាំងអស់នៅក្នុងភូមិឲ្យកាន់តែច្បាស់ឡើងថែមមួយកម្រិតទៀត ដើម្បីកុំឲ្យមានបន្ទិលសង្ស័យ ព្រមទាំងផ្សព្វផ្សាយអំពីគោលការណ៍ឥណទានក្រុមធានា ។ ហើយការប្រជុំនោះក៏ត្រូវរើសកន្លែងណាមួយដែលសមរម្យ និងមានការចូលរួមពីសំណាក់មេឃុំ មេភូមិ និងប្រជាពលរដ្ឋ ។ ហើយចំណុចសំខាន់ៗនៃការប្រជុំ គឺផ្តោតសំខាន់ទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

- ឧទ្ទេសនាមអំពីឈ្មោះ ប្រភេទ និងសកម្មភាពរបស់ អម្រឹត
- ពន្យល់ពីអត្ថន័យ នៃពាក្យថាឥណទាន
- លក្ខខ័ណ្ឌនៃការខ្ចី
- លក្ខខ័ណ្ឌសង

- ទីកន្លែង ខ្ចី-សង
- ពត៌មានអំពីគណៈកម្មាការបេឡាឥណទាន

ដំណាក់កាលទី៤ ការពិភាក្សាតាមគ្រួសារ : បន្ទាប់ពីបានធ្វើចំណុចទី៣ រួចរាល់ហើយ ភ្នាក់ងារឥណទានផ្សេងទៀតចុះទៅជួបជាមួយគ្រួសារនីមួយៗ ដែលបានចូលរួមប្រជុំ ដើម្បីធ្វើការសង្កេតលើសេដ្ឋកិច្ចគ្រួសារ ។ ការធ្វើខាងលើនេះគឺដើម្បីស្ទាបស្ទង់ចង់ដឹងបន្ថែមទៅលើចំណុចមួយចំនួនដូចខាងក្រោម ៖

- ធ្វើឲ្យប្រាកដថាគ្រួសារនីមួយៗយល់ច្បាស់ពីគោលការណ៍ខ្ចីប្រាក់
- ស្វែងយល់អំពីជីវភាពគ្រួសារនីមួយៗឲ្យកាន់តែច្បាស់
- បំផុសឲ្យគ្រួសារនីមួយៗចងក្រងជាក្រុមធានាគ្នាប្រសិនបើពួកគេត្រូវការខ្ចីប្រាក់

ដំណាក់កាលទី៥ ការពិភាក្សាតាមក្រុម : ក្រោយពីពិភាក្សាតាមគ្រួសារនីមួយៗរួចរាល់ហើយ គ្រួសារណាមួយដែលមានសេចក្តីត្រូវការខ្ចីឥណទាននេះ ក៏បានបបួលគ្នីគ្នា បងប្អូនចងក្រងជាក្រុមចំនួន ៣ ទៅ ៦នាក់ ទើបភ្នាក់ងារឥណទានមានភារកិច្ចមួយទៀត គឺចុះពិភាក្សាតាមក្រុម ឬ បំប៉នក្រុម ។ បន្ទាប់មកទៀតភ្នាក់ងារឥណទានក៏បានចុះទៅជួបសមាជិកក្រុមម្តងមួយៗ នៅឯផ្ទះសមាជិកណាមួយនៃក្រុមហើយការធ្វើនេះក្នុងគោលបំណងដើម្បី ៖

- បញ្ជាក់ឲ្យច្បាស់លាស់ថាអ្នកណាជាសមាជិកពិតប្រាកដ (ប្តី ឬ ប្រពន្ធ)
- ធ្វើឲ្យប្រាកដថាសមាជិកនៃក្រុមធានាយល់ច្បាស់លាស់អំពីខ្លឹមសារ នៃក្រុមធានា និងបំប៉នបន្ថែមលើគោលការណ៍ខ្ចីប្រាក់ប្រសិនបើសមាជិកណាមួយនៅមានការស្រពិចស្រពិល
- ជ្រើសរើសប្រធានដែលប្រកបដោយសមត្ថភាព
- ពិភាក្សា និងសម្រេចលើប្រាក់កម្ចីរបស់សមាជិកម្នាក់ៗ ។

ដំណាក់កាលទី៦ ការបង្កើតគណៈកម្មាការឥណទាន : នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត មានគោលការណ៍ថា បើនរណាចង់ឈរឈ្មោះជាគណៈកម្មាការបាន លុះត្រាតែនាក់នោះចេះសរសេរអក្សរ និងអានបាន ព្រមទាំងជាមនុស្សដែលមានប្រជាប្រិយភាព ដែលប្រជាជនក្នុងភូមិរាប់អាន និងមានកេរ្តិ៍ឈ្មោះល្អទៀតផង ។ ក្នុងការបង្កើតគណៈកម្មាការឥណទានភូមិនេះមានចំនួនពីររូបគឺប្រធាន និងអនុប្រធានគណៈកម្មាការដែលត្រូវបានជ្រើសរើសចេញពីប្រធានក្រុមនីមួយៗ ។

➢ **<u>តួនាទី និងភារកិច្ចប្រធាន និង អនុប្រធានគណៈកម្មាការ</u>**

- ចុះហត្ថលេខាជាមួយកិច្ចសន្យាខ្ចីប្រាក់ជាមួយ អម្រឹត ដើម្បីយកប្រាក់ឲ្យសមាជិកខ្ចី
- សម្រេចឲ្យសមាជិកខ្ចី ឬមិនឲ្យខ្ចីប្រាក់ ដោយយោងទៅតាមគោលការណ៍ឥណទាន

របស់ អម្រឹត

- ជាអ្នកចុះជំរុញឲ្យសមាជិកយកបច្ច័យមកសងប៉ុន្តែប្រធាននិងអនុប្រធានគ្មានតួនាទីទទួលបច្ច័យសងពីសមាជិកឥណទានទេ
- ទទួលខុសត្រូវក្នុងការសងប្រាក់ពីសមាជិកឲ្យគ្រប់ចំនួន១០០% និងទាន់ពេលវេលា
- តាមដានការប្រើប្រាស់ទុនរបស់សមាជិក
- គោរពវិន័យ និងធ្វើជាគំរូគេ ដូចជា ចូលរួមការប្រជុំសងប្រាក់ទាន់ពេលវេលាជាដើម
- ចូលរួមជាមួយភ្នាក់ងារឥណទានដែលបានតែងតាំងដោយ អម្រឹត ក្នុងការពង្រីកបេឡាឥណទានភូមិ ។

<u>ដំណាក់កាលទី៧</u> ការបើកប្រាក់ជូនសមាជិកខ្ចី: ក្រោយពីបានបំពេញបែបបទទាំង ៦ ដំណាក់កាលរួចរាល់ហើយទើបបើកប្រាក់ជូនសមាជិកខ្ចី ។

- **ផ្នែកទី២**: បេឡាឥណទានមានស្រាប់ វាមិនមានភាពជំពាក់វាក់វិនដូចបេឡាឥណទានថ្មីនោះទេ គឺគ្រាន់តែភ្នាក់ងារឥណទានដែលបានទទួលបន្ទុករាយការណ៍ប្រាប់ដល់ប្រធានសាខាស្រុកអំពីកាលបរិច្ឆេទនៃការទំលាក់ទុនទៅឲ្យប្រជាជនដែលមានសមាជិកឥណទាននោះ ។

៣.៣.១.២ ឥណទានបុគ្គល

នៅក្នុងសកម្មភាពមុនពេលទំលាក់ទុនឥណទានបុគ្គលមានលក្ខណៈងាយស្រួលជាង ឥណទានក្រុមធានាហើយមិនចាំបាច់ប្រើពេលយូរឡើយ ។ សកម្មភាពទាំងឡាយមុនពេលទំលាក់ទុនមានដូចខាងក្រោមនេះ ៖

- ការផ្សព្វផ្សាយរបស់ភ្នាក់ងារឥណទាន : គឺជាភារកិច្ចរបស់ភ្នាក់ងារឥណទានដែលទទួលបន្ទុកបេឡាឥណទានភូមិណាមួយហើយត្រូវធ្វើការផ្សព្វផ្សាយអំពីគោលការណ៍និងលក្ខខ័ណ្ឌនៃកម្ចីឥណទានបុគ្គលទៅកាន់អតិថិជនរបស់ខ្លួននៅក្នុងភូមិនោះ ឲ្យកាន់តែច្បាស់ឡើងថែមទៀត
- ការដាក់សំណើរបស់អតិថិជនមកដល់ភ្នាក់ងារឥណទាន:បន្ទាប់ពីអតិថិជនបានយល់ច្បាស់ពីគោលការណ៍ និងលក្ខខ័ណ្ឌនៃកម្ចីដែលបានផ្សព្វផ្សាយដោយភ្នាក់ងារឥណទានហើយនោះប្រសិនបើអតិថិជនណាម្នាក់មានការចាប់អារម្មណ៍ចង់ខ្ចីឥណទានបុគ្គលនោះ គឺតម្រូវឲ្យអតិថិជនរូបនោះជូនដំណឹង ទៅឲ្យភ្នាក់ងារឥណទានតាមរយៈគណៈកម្មាការ ឬប្រាប់ទៅដល់ភ្នាក់ងារឥណទានដោយផ្ទាល់ដើម្បីចុះត្រួតពិនិត្យ និងធ្វើការពិភាក្សា
- ការចុះសិក្សាសំណើ និងបំពេញបែបបទជាមួយអ្នកខ្ចី: បន្ទាប់ពីភ្នាក់ងារឥណទាន

បានទទួលសំណើខ្ចីរបស់អតិថិជនក្នុងភូមិនោះរួចមក ភ្នាក់ងារឥណទានក៏បានចុះទៅជួបជជ្ជាល់ជាមួយអ្នកខ្ចីនោះដើម្បីធ្វើការសិក្សាទៅលើមុខរបរ ការបំពេញបែបបទ និងត្រួតពិនិត្យទៅលើទ្រព្យសម្បត្តិរបស់គាត់ដែលបាន កត់ត្រាថាជាវត្ថុបញ្ចាំ ឬវត្ថុធានា ហើយភ្នាក់ងារឥណទានត្រូវធ្វើការវាយតម្លៃទៅលើទ្រព្យសម្បត្តិ គឺប្រហែលជា ៧៥% នៃប្រាក់កម្ចីធៀបទៅនឹងតម្លៃរបស់វត្ថុបញ្ចាំជាក់ស្តែង

- ការប្រជុំគណៈកម្មាការឥណទានបុគ្គល : បន្ទាប់ពីភ្នាក់ងារឥណទានបានបំពេញនូវសំណើរបស់អ្នកខ្ចីរួចរាល់ហើយក៏ចាប់ផ្តើមការប្រជុំដែលចូលរួមពី គណៈកម្មាការឥណទានបុគ្គលក្រោមការដឹកនាំរបស់ប្រធានសាខាស្រុក ។

✓ <u>ដោយមានសមាសធាតុ ៣ រូបគឺ</u>

- ប្រធានសាខាស្រុក ឬអនុប្រធានសាខាស្រុក
- ប្រធានសាខាខេត្ត ឬអនុប្រធានស្រុក
- ភ្នាក់ងារឥណទានធម្មតា ឬ អនុខេត្តទៅតាមទំហំឥណទាន ។

✓ <u>ក្នុងការប្រជុំគឺដើម្បី</u>

- ត្រួតពិនិត្យទៅលើការវាយតម្លៃវត្ថុបញ្ចាំរបស់ភ្នាក់ងារឥណទាន
- ធ្វើការសម្រេចចិត្តថាត្រូវឲ្យខ្ចី ឬមិនឲ្យខ្ចី
- បើឲ្យខ្ចីត្រូវកំណត់ពេលទំលាក់ទុន
- ពិភាក្សាទៅលើមុខរបរម្តងទៀត (ករណីអតិថិជនសងហើយខ្ចីវិញ)

✓ ក្រោយពីពិភាក្សានៅក្នុងបរិបទយ៉ាងម៉ត់ចត់ក្នុងការសម្រេចចិត្តលើកម្ចីនេះ គឺយើងត្រូវផ្អែកលើគោលការណ៍ចំនួន ១០ ចំណុចគឺ ៖

- លក្ខណៈសម្បត្តិ
- ប្រភេទអតិថិជន
- អាស័យដ្ឋាន
- កម្រិតយល់ដឹង
- ការដឹងឮ ពីប្តីប្រពន្ធ
- សាក្សី ឬអ្នកធានា
- ស្ថានភាពបំណុលមិនឲ្យលើសពី ៣០% នៃទុនវិនិយោគ
- ការចាត់ចែងអាជីវកម្ម

- ទីផ្សារអាជីវកម្ម
- ជំនាញ និងបទពិសោធន៍ ។

៣.៣.២ សកម្មភាពពេលចំណាក់ឆុង

បន្ទាប់ពីបានបំពេញចប់សព្វគ្រប់លក្ខខ័ណ្ឌនៃដំណាក់កាលទី១ រួចរាល់ហើយឃើញថាសមគួរដល់ការផ្តល់ឥណទាន ។ ហើយការអនុវត្តជាក់ស្តែងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ក្នុងការផ្តល់ឥណទានក្រុមធានា និងឥណទានបុគ្គលមានដូចខាងក្រោម ៖

៣.៣.២.១ ឥណទានក្រុមធានា

ឈានដល់ដំណាក់កាលនេះ មិនសូវមានការលំបាកដូចដំណាក់កាលទី១ទេ គឺគ្រាន់តែបើកប្រាក់ជូនដល់សមាជិកដែលខ្វីហើយត្រូវធ្វើឡើងនៅផ្ទះប្រធានគណៈកម្មាការ ឬអនុគណៈកម្មាការ យោងទៅលើការព្រមព្រៀងរបស់ពួកគេក្នុងនោះដែរក៏មានការចូលរួមពីភ្នាក់ងារបេឡា ដែលទទួលបន្ទុកហើយភ្នាក់ងារបេឡាដែលទទួលបន្ទុកចាំបាច់ត្រូវមានជំនួយការម្នាក់ ដើម្បីជួយ ហើយអ្នកជំនួយការនោះអាចជាប្រធានស្រុក ឬភ្នាក់ងារឥណទានដូចគ្នា ។ ជាបន្តមកទៀតអ្នកជំនួយការភ្នាក់ងារបេឡានោះក៏ចាប់ផ្តើមសួរសំនួរម្តងមួយក្រុមៗ ដោយយ៉ាងហោចណាស់ក៏មានប្រាំមួយទៅប្រាំពីរ សំនួរដែរដើម្បីជៀសវាងការមិនច្បាស់លាស់អំពីគោលការណ៍ និងលក្ខខ័ណ្ឌនៃកម្ចីសម្រាប់សមាជិកនីមួយៗ ។ បន្ទាប់ពីបានសួរសំនួរជាច្រើនឃើញថាសមាជិកទាំង ៦នាក់ធ្វើការផ្តិតមេដៃដើម្បីធានាគ្នាទៅវិញទៅមក ក្នុងនោះដែរក៏មានប្រធានគណៈកម្មាការជាអ្នកតាមដាននិងត្រួតពិនិត្យដើម្បីវាយតម្លៃទៅលើសំនួរ និងចម្លើយរវាងអ្នកសួរ និងអ្នកឆ្លើយ ហើយប្រៀបធៀបទៅនឹងទំរងបែបបទសុំខ្ចី ថាវាពិតប្រាកដមែន ឬអត់ ។ ក្រោយពីប្រធាន និងអនុប្រធានគណៈកម្មាការចុះហត្ថលេខាទៅលើកិច្ចសន្យានោះរួចបន្ទាប់មកក៏បញ្ជូនទៅ ឲ្យភ្នាក់ងារដែលទទួលបន្ទុកបេឡាពិនិត្យមើលម្តងទៀតឃើញថាវាត្រឹមត្រូវហើយទើបចុះហត្ថលេខា និងបើកប្រាក់ជូនសមាជិកម្នាក់ម្តងៗក្នុងក្រុម ។ ទន្ទឹមនឹងនោះដែរ ភ្នាក់ងារឥណទានដែលទទួលបន្ទុកក៏បានណែនាំឲ្យសមាជិកទាំងអស់ធ្វើការរាប់ និងពិនិត្យមើលក្រដាស់ប្រាក់ឲ្យបានច្បាស់លាស់ ពិតប្រាកដ ត្រឹមត្រូវ តើគ្រប់ចំនួនហើយ ឬនៅ ឬក៏មានក្រដាសប្រាក់រហែកដែរ ឬអត់ ។ ប្រសិនបើមានក្រដាសប្រាក់រហែកអាចដូរបាន ឬបើខ្លះអាចទារបង្គ្រប់បានតែត្រូវរាប់នៅមុខភ្នាក់ងារឥណទានទទួលបន្ទុកផ្ទុយទៅវិញ បើមិនបានរាប់នៅមុខភ្នាក់ងារបេឡាដែលទទួលបន្ទុកទេនោះ យើងនឹងមិនទទួលខុសត្រូវទេ។ម៉្យាងទៀតក្នុងករណីជិតដល់ពេលបើកលុយហើយស្រាប់តែក្នុងក្រុមណាមួយមានបញ្ហាជំលោះ ត្រូវផ្អាកសិនឬក៏បានបើប្រាក់ឲ្យមួយចំនួនហើយត្រូវទាមទារមកវិញ និងមានសំនួរមួយចំនួនដែលទាក់ទងនឹង

ឥណទានក្រុមធានាដែលមាន ១២ចំណុច ដើម្បីសួរសំនួរទៅដល់អតិថិជនឡើងវិញទៀតដូចខាងក្រោម៖

- តើការប្រាក់មានប៉ុន្មានភាគរយក្នុង ១ខែ ?
- ប្រាក់ដែលឲ្យខ្ចីខ្ពស់បំផុតមានចំនួនប៉ុន្មាន ?
- ក្នុងអំឡុងពេលខ្ចីប៉ុន្មានខែយ៉ាងយូរ ?
- អ្នកណាជាអ្នកឲ្យជ្រើសរើសក្រុម ?
- ហេតុអ្វីបានជាត្រូវឲ្យបង្កើតក្រុម ?
- ការខ្ចីរបៀបណា ?
- ប្រសិនបើសមាជិកក្នុងក្រុមណាមិនសងតើសមាជិកក្នុងក្រុមគិតដូចម្តេច ?
- ប្រសិនបើសមាជិកក្រុម ៥នាក់ទៀតមិនព្រមចេញសង តើគណៈកម្មាការសម្រេចចិត្តដូចម្តេច ?
- ប្រសិនបើមានបញ្ហាកើតឡើងនៅក្នុងក្រុម តើទៅជួបអ្នកណាដើម្បីដោះស្រាយ ?
- របៀបសងប្រាក់ (ការប្រាក់ និងប្រាក់ដើម)
- ពេលសងតើត្រូវយកអ្វីមកផង ?
- នៅពេលសងតើត្រូវយកក្រដាសប្រាក់ប្រភេទណាមកសង ?

៣.៣.២.២ ឥណទានបុគ្គល

ក្រោយពីបានបំពេញតាមលក្ខខ័ណ្ឌចប់សព្វគ្រប់ហើយ បន្ទាប់មកភ្នាក់ងារឥណទានដែលទទួលបន្ទុកបើកប្រាក់ពីកន្លែងទីស្នាក់ការគ្រប់ចំនួនរួចហើយ ក៏បានយកប្រាក់ទាំងនោះទៅបើកជូនអ្នកខ្ចីនៅផ្ទះរបស់គាត់ ។ នៅក្នុងខណៈនោះដែរភ្នាក់ងារឥណទានបានអានកិច្ចសន្យាដល់អ្នកខ្ចីស្តាប់បើអ្នកខ្ចីយល់ថាត្រឹមត្រូវហើយទើបចុះហត្ថលេខានៅពេលរួចរាល់ហើយទើបប្រគល់ប្រាក់ ឲ្យអតិថិជនរាប់សារចុះ សារឡើងជាច្រើនដង ដើម្បីកុំឲ្យមានបញ្ហាកើតឡើងនៅថ្ងៃក្រោយ លុះអ្នកខ្ចីយល់ថាគ្រប់ចំនួនហើយនោះទើបជាការស្រេចបាច់ ។ ដើម្បីធានាលើកិច្ចសន្យាដែលបានចុះហត្ថលេខា រវាងភ្នាក់ងារឥណទាន និងអ្នកខ្ចីឲ្យមានសុពលភាពនោះចាំបាច់តម្រូវឲ្យមានសាក្សីយ៉ាងតិចចំនួនពីររូបដែលអ្នកទាំងនោះមិនមែនជាសាច់ញាតិរបស់អ្នកខ្ចីឡើយ ដើម្បីធ្វើជាភស្តុតាងដោយមានការផ្តិតមេដៃផងដែរ ។ ក្នុងប្រភេទឥណទាននេះកំពស់ទុនទាបបំផុត ចាប់ពី ១,០០០,០០០ រៀល ឬ ១០០ ដុល្លារ រហូតដល់ ២០០,០០០,០០០ រៀល ឬ ៥០,០០០ ដុល្លារ ។ ដោយឡែកអ្នកធានាត្រូវតែមានមុខរបរពិតប្រាកដហើយមុខរបរនោះ មិនជាប់ពាក់ព័ន្ធជាមួយអ្នកខ្ចី

ឡើយនិងមានលទ្ធភាពសងគ្រប់គ្រាន់ក្នុងករណីដែលអ្នកខ្ចីមិនសង ។ ការអនុម័តត្រូវធ្វើនៅកម្រិតស្រុក ចំពោះសំណើឥណទានដែលមានទំហំតិចជាង ៤០,០០០,០០០ រៀល ឬ ១០,០០០ ដុល្លារ ប្រសិនបើលើសពីនេះត្រូវ មានប្រធានសាខាខេត្តឬអនុប្រធានសាខាខេត្តចូលរួមជាចាំបាច់ក្នុងការអនុម័តសម្រេច ។

ហើយកិច្ចសន្យាត្រូវធ្វើឡើងចំនួន ២ច្បាប់ ក្នុងករណីអត់មានអ្នកធានា

- ឲ្យទៅអតិថិជនចំនួន ១ច្បាប់
- ទុកនៅក្នុងស្រុកចំនួន ១ច្បាប់

ប៉ុន្តែក្នុងករណីមានអ្នកធានានោះ កិច្ចសន្យាត្រូវធ្វើឡើងចំនួន ៣ច្បាប់

- ឲ្យទៅអតិថិជនចំនួន ១ច្បាប់
- ទុកនៅក្នុងស្រុកចំនួន ១ច្បាប់
- ឲ្យអ្នកធានាមួយច្បាប់ ។

៣.៣.៣ សកម្មភាពក្រោយពេលចំណាកទុន

៣.៣.៣.១ ឥណទានក្រុមធានា

ការងារក្រោយពេលទំលាក់ទុន គឺជាការងារមានសារៈសំខាន់ណាស់ក្នុងការធ្វើឥណទានជាពិសេស គឺការគ្រប់គ្រងឥណទានភូមិដែលការខ្ចីមានលក្ខណៈជាសមូហភាពនេះ ។

- **ការតាមដានឥណទាន**

ក្រោយពីពេលទំលាក់ទុនរួចរាល់កាលណាហើយបានជាប្រហែលកន្លះខែមក ភ្នាក់ងារឥណទានដែលទទួលបន្ទុកចាប់ផ្តើមបំពេញភារកិច្ចរបស់ខ្លួន ក្នុងការចុះទៅតាមដានដោយផ្ទាល់ ឬក៏ដោយប្រយោលទៅតាមផ្ទះរបស់សមាជិកនីមួយៗ ដើម្បីមើលពីស្ថានភាពប្រើប្រាស់ទុនរបស់គាត់ផង និងសាកសួរបញ្ហាមួយចំនួនដែលទាក់ទងទៅនឹងមុខរបរ ធ្វើស្រែចំការ និងការចិញ្ចឹមសត្វរបស់គាត់បានទទួលផលកម្រៃយ៉ាងណាដែរ ? បន្ទាប់ពីអតិថិជនបានទទួលទុនកម្ចីហើយនោះ នៅក្នុងលំនៅដ្ឋានរបស់ពួកគាត់ តើមានអ្វីប្លែកចាប់តាំងពីមុនពេលគាត់ខ្ចីនិងក្រោយពេលគាត់ខ្ចី ។ ជាពិសេសទៅទៀតការតាមដាននេះ គឺផ្តោតអារម្មណ៍ទៅលើសមាជិកឥណទានដែលបានខ្ចីទុននោះថាតើប្រើប្រាស់បានត្រឹមត្រូវទៅតាមកិច្ចសន្យាដែលសមាជិកឥណទាននីមួយៗ បានបំពេញ ឬទេ និងធ្វើឲ្យមានភាពស្និតស្នាលរវាងស្ថាប័ន ជាមួយនឹងអតិថិជនកាន់តែប្រសើរឡើង ព្រមទាំងស្វែងយល់ថាតើពួកគាត់មានតម្រូវការបន្ថែមទៀត ឬទេ ។

- <u>បែបបទនៃការបញ្ចូលក្រុមថ្មី</u>

បន្ទាប់ពីការតាមដានហើយឃើញថា មានតម្រូវការរបស់សមាជិកឥណទានណាមួយដែលមិនទាន់ខ្ចី តែមកដល់ប៉ុន្មានខែក្រោយមកក៏ស្រាប់តែខ្ចីនោះ ត្រូវបញ្ចូលទៅក្នុងក្រុម ។ នៅក្នុងករណីបញ្ចូលទៅក្នុងក្រុមថ្មីបានបែងចែកជាពីរ៖ ការបញ្ចូលក្រុមថ្មីនៅក្នុងវគ្គ និងការបញ្ចូលក្រុមថ្មីនៅដើមវគ្គថ្មី ។

- <u>ការបញ្ចូលក្រុមថ្មីនៅក្នុងវគ្គ</u>: ជាការពង្រីកក្រុមបន្ថែមទៀតចូលទៅក្នុងវគ្គនៅពេលដែលអ្នកខ្ចីបានបំពេញជំហានទាំង ប្រាំ រួចរាល់ហើយ

✓ ការបញ្ចូលក្រុមថ្មីនៅក្នុងវគ្គមានលក្ខខ័ណ្ឌដូចខាងក្រោម:

- សមាជិកចាស់បានសងការប្រាក់គ្រប់ចំនួន និងទាន់ពេលវេលា
- មិនត្រូវបញ្ចូលក្រុមថ្មីនៅរយៈពេល១ខែមុនកំណត់បិទវគ្គចំពោះការពង្រីកនៅភូមិថ្មី

- <u>ការបញ្ចូលក្រុមថ្មីនៅដើមវគ្គថ្មី</u>: ជាការបញ្ចប់វគ្គចាស់ហើយត្រូវធ្វើការបើកវគ្គថ្មីបន្ត

✓ លក្ខខ័ណ្ឌដើម្បីបញ្ចូល

សមាជិកចាស់បានសងប្រាក់គ្រប់ចំនួន ១០០% ឬ នៅពេលដែលបេឡា ឥណទានភូមិអាចបើកដំណើរការវគ្គថ្មីបន្តទៀតបាន

- <u>ការរំលឹកមុនថ្ងៃបិទវគ្គ</u>

នៅពេលជិតដល់ថ្ងៃសងប្រាក់មកដល់ភ្នាក់ងារឥណទានដែលទទួលបន្ទុក ត្រូវរៀបចំការប្រជុំ៣សប្តាហ៍មុនថ្ងៃកំណត់ប្រមូលប្រាក់បញ្ចប់វគ្គក្នុងគោលបំណងដើម្បី ៖

- រំលឹកសមាជិកពីថ្ងៃកំណត់សងប្រាក់បញ្ចប់វគ្គ
- ប៉ាន់ប្រមាណអំពីបញ្ហា
- ជំរុញឲ្យគណៈកម្មាការឥណទានអនុវត្តន៍នាទីរបស់ខ្លួន
- ដោះស្រាយបញ្ហាប្រសិនបើមាន

- <u>ការប្រជុំបិទវគ្គ និងបើកវគ្គ</u>

នៅពេលកាលអវសានៃឥណទានក្រុមធានាមកដល់ហើយ ភ្នាក់ងារឥណទានដែលទទួលបន្ទុកក៏ប្រញាប់ប្រញាលរៀបចំការប្រជុំឡើងក្នុងគោលបំណង ដើម្បីបង្ហាញពីសកម្មភាពដែលបានអនុវត្តន៍កន្លងមកនេះពីបញ្ហាដែលកើតឡើងក្នុងក្រុមនីមួយៗ តាំងពីពេលចាប់ផ្តើមរហូតដល់បញ្ចប់វគ្គ ដូចជាការបង់ប្រាក់យឺតយ៉ាវ បើសិនជាក្រុមណាមួយមានបញ្ហានេះកើតឡើងភ្នាក់ងារឥណទានក៏ពន្យល់ពីមូលហេតុមួយចំនួនដល់ក្រុមនោះនៅវគ្គក្រោយទៀត ដើម្បីកុំឲ្យមានបញ្ហានេះកើតឡើង

ម្តងទៀត ។ បន្ទាប់មកទៀតភ្នាក់ងារឥណទានក៏បានគោរពអញ្ជើញគណៈកម្មាការបញ្ចេញយោបល់ និងធ្វើការសំណូមពរចំពោះប្រធានក្រុមនីមួយៗ និងសមាជិកទាំងអស់ដែលបានចូលរួមខិតខំយកចិត្តទុកដាក់ចំពោះកិច្ចការទាំងនោះដើម្បីកុំឲ្យមានភាពយឺតយ៉ាវក្នុងការបង់ការប្រាក់និងប្រាក់ដើម។

ការប្រជុំបិទវគ្គនេះ គឺបិទវគ្គចាស់ និងបើកវគ្គថ្មី ហើយក៏មានការជ្រើសរើសគណៈកម្មាការថ្មី ហើយក្នុងនោះសមាសភាគដែលចូលរួមមាន៖

- មេឃុំ មេភូមិ
- ភ្នាក់ងារឥណទានដែលទទួលបន្ទុក
- ភ្នាក់ងារជំនួយ (ប្រធានសាខាស្រុក បើសិនមានពេល)
- ប្រធាន និងអនុប្រធានគណៈកម្មាការ
- សមាជិកឥណទាន ។

៣.៣.៣.២ ឥណទានបុគ្គល

- **ការតាមដានឥណទាន**

ភ្នាក់ងារឥណទានត្រូវធ្វើការតាមដានអតិថិជនឲ្យបាន២ដងសម្រាប់ខែដំបូងនិងយ៉ាងហោចណាស់ឲ្យបាន ១ដងនៅរៀងរាល់ខែនីមួយៗបន្ទាប់ពីការទំលាក់ទុន ។ ចំពោះភ្នាក់ងារឥណទានទូទៅ គឺអាចធ្វើការតាមដាននៅរាល់ពេលដែលចុះទៅប្រមូលការប្រាក់នៃខែនីមួយៗ ។

ក្នុងខណៈពេលដែលចុះតាមដានឥណទានភ្នាក់ងារឥណទានទៅជួបអតិថិជន ដោយផ្ទាល់នៅផ្ទះរបស់ពួកគាត់ និងធ្វើការសំណេះសំណាលជាមួយអតិថិជនដោយប្រើពាក្យសំដីទន់ភ្លន់សុភាពរាបសារ ដោយកាយ និងវាចារចិត្តព្រមទាំងសង្កេតមើល និងស្វែងយល់អំពីស្ថានភាពប្រើប្រាស់ឥណទាន ថាតើមានលក្ខខណៈសមស្របទៅតាមអ្វីដែលគាត់បានបំពេញបែបបទស្នើសុំខ្ចីឬអត់ និងស្ថានភាពនៃមុខរបរអាជីវកម្មមានការអភិវឌ្ឍ ឬអត់ ក្រោយការប្រើប្រាស់ឥណទានព្រមទាំងពិនិត្យមើលទៅលើស្ថានភាពសងឥណទានមានប៉ុន្មានភាគរយ ដែលយើងសង្ឃឹមថាអតិថិជននឹងសងវិញ ។ ក្នុងការពិនិត្យនេះ ដោយផ្អែកទៅលើស្ថានភាពក្នុងតារាងសងប្រាក់ និងសៀវភៅតាមដាន អង្កេត និងសាកសួរអ្នកជិតខាងអំពីស្ថានភាពបំណុល គ្រួសារនិងការផ្លាស់ទីលំនៅរបស់អតិថិជន ចុងក្រោយនេះត្រូវពិនិត្យពិច័យទៅលើទ្រព្យសម្បត្តិដាក់បញ្ចាំរបស់អតិថិជនតើនូវមានសុពលភាព និងមានតម្លៃសម្រាប់ដាក់ធានាសុវត្ថិភាពឥណទានរបស់អម្រឹត ។

៣.៤ លក្ខខ័ណ្ឌភ្ជុំគការសង

៣.៤.១ ឥណទានក្រុមធានា

ឥណទានក្រុមធានា មានលក្ខខ័ណ្ឌមួយចំនួនដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតកំណត់ឡើងនៅពេលផ្តល់សេវាឥណទានដល់អតិថិជនជាលក្ខណៈសមូហភាព ឬក្រុមធានា ។ ដើម្បីអាចទទួលបាននូវសេវាឥណទានទាំងនេះតម្រូវឲ្យកសិករ ឬអតិថិជនបំពេញនូវលក្ខខ័ណ្ឌដូចតទៅនេះ៖

- ត្រូវតែជាប្រជាជនដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិ និងមានមុខរបរច្បាស់លាស់
- ក្រុមកម្ចីត្រូវមានគ្នាពី ៣ ទៅ ៦នាក់
- ស្ម័គ្រចិត្តក្នុងការធានាគ្នាទៅវិញទៅមក (បើមានសមាជិកណាម្នាក់មិនសងនោះសមាជិកក្នុងក្រុមទាំងអស់ត្រូវសងជំនួស)
- រយៈពេលខ្ចីពី ៦ រហូតដល់ ១២ ខែ
- កំពស់ទុនខ្ពស់បំផុត ២,០០០,០០០ រៀល
- អត្រាការប្រាក់ ៣% ក្នុងមួយខែលើចំនួនប្រាក់ដើមដែលនៅជំពាក់ជាក់ស្តែង
- ការប្រាក់ត្រូវបង់រាល់ខែ
- ប្រាក់ដើមអាចបង់បានតាម ៣របៀប ៖ បង់ផ្តាច់ក្នុងវគ្គ បង់រំលោះក្នុងវគ្គ និងបង់ពេលបញ្ចប់វគ្គ
- ទីកន្លែង ខ្ចី-សងនៅផ្ទះប្រធានគណៈកម្មាការបេឡាឥណទានភូមិ(ត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកខ្ចីប្រាក់ទាំងអស់នៅក្នុងភូមិ)

៣.៤.២ ឥណទានបុគ្គល

- មានចរិកលក្ខណៈល្អនៅក្នុងសង្គម
- ជានីតិជនសកម្ម
- ប្តី ឬប្រពន្ធ ឬអ្នកស្នងមរតករបស់អ្នកសុំខ្ចីត្រូវតែដឹងឮពីការសុំខ្ចីឥណទានពីអម្រឹត
- រស់នៅជាអចិន្ត្រៃយ៍ក្នុងតំបន់ប្រតិបត្តិការរបស់ អម្រឹត
- យល់ច្បាស់ពីគោលនយោបាយ និង នីតិក្រមឥណទានបុគ្គលរបស់ អម្រឹត
- មានស្ថានភាពបំណុលល្អ (បំណុលពីប្រភពឥណទានផ្សេងៗមិនឲ្យលើសពី ៣០% នៃទុនវិនិយោគសរុប)
- មានគំរោងអាជីវកម្មច្បាស់លាស់មានការចាត់ចែងទីផ្សារអាជីវកម្មបានល្អ និងមានជំនាញ ឬបទពិសោធន៍ខ្លះលើមុខរបរអាជីវកម្មដែលជាប្រភពសងប្រាក់មកដល់អម្រឹត និងអតិថិជន

- ទ្រព្យសម្បត្តិដាក់បញ្ចាំ គឺមានតម្លៃយ៉ាងតិច ២ដងនៃទំហំឥណទាន ដោយក្នុងនោះ អចលនទ្រព្យចំបងៗត្រូវមានតម្លៃយ៉ាងតិច ១៥០% និងចលនទ្រព្យ ៥០% នៃទឹកប្រាក់ស្នើសុំខ្ចី សរុប ។

៣.៥ វិធីសាស្ត្រនៃការគណនាការប្រាក់ និងប្រាក់ដើមត្រូវសង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត បានប្រើប្រាស់នូវវិធីសាស្ត្រលោះប្រាក់ដើមថេរ និងការប្រាក់ (Declining Balance Calculation Method) ដើម្បីគណនាផលិតផលឥណទានទាំងពីរនេះ ។

❖ ឥណទានក្រុមធានា

ចំពោះឥណទានក្រុមធានាការគណនាការប្រាក់ គឺយកប្រាក់ដើមដែលគាត់បានខ្ចីមកគុណនឹងអត្រាការប្រាក់ ៣% ហើយការប្រាក់ត្រូវសងជារៀងរាល់ខែតាមរយៈពេលកំណត់នៃតារាងសងប្រាក់ ។

❖ ឥណទានបុគ្គល

ឧទាហរណ៍: សមាជិកម្នាក់បានខ្ចីប្រាក់ឥណទានចំនួន ១,០០០,០០០រៀលរយៈពេល ១០ខែ អត្រាការប្រាក់ ៣% ក្នុងមួយខែ ។

ចំនួនប្រាក់ដើមដែលត្រូវសងក្នុង ១ខែៗគឺស្មើនឹង ប្រាក់ដើមដែលត្រូវបានខ្ចីទាំងអស់ ចែកនឹងរយៈពេលខ្ចីសរុប

ខែទី១: -ចំនួនប្រាក់ដើមត្រូវសងរាល់ខែ ១,០០០,០០០/១០ខែ= ១០០,០០០ រៀល

-ការប្រាក់ដែលត្រូវសងមាន: ១,០០០,០០០×៣%= ៣០,០០០ រៀល

-ប្រាក់ទាំងអស់ដែលត្រូវសង: ១០០,០០០+៣០,០០០= ១៣០,០០០ រៀល

ខែទី២:-ប្រាក់ដើមជំពាក់នៅសល់ ១,០០០,០០០-១០០,០០០= ៩០០,០០០ រៀល

ការប្រាក់ត្រូវសងស្មើនឹងប្រាក់ដើមនៅជំពាក់គុណនឹងអត្រាការប្រាក់ ៣%

-ការប្រាក់ដែលត្រូវសង: ៩០០,០០០×៣%= ២៧,០០០ រៀល

-ប្រាក់ដែលត្រូវបង់ទាំងអស់: ១០០,០០០+២៧,០០០= ១២៧,០០០ រៀល

ចំនួនដែលសងក្នុង១ខែៗស្មើនឹងចំនួនប្រាក់ដើមទាំងអស់ដែលត្រូវខ្ចី ចែកនឹងរយៈពេលខ្ចី អាស្រ័យទៅលើមុខរបរ ដែលប្រើប្រាស់ក្នុងរយៈពេលច្រើនខែទើបមានប្រាក់ចំណូល ដូច្នេះការបង់ប្រាក់សងត្រូវពន្យាពេលរហូតដល់សកម្មភាពត្រូវបានផ្គត់ផ្គង់ ។

ឧទាហរណ៍: ចំនួនទឹកប្រាក់ឥណទាន ១,២០០,០០០ រៀល រយៈពេល ១០ខែ និងមានរយៈពេលអនុគ្រោះចំនួន ៥ខែ និងអត្រាការប្រាក់ចំនួន ៣% ។

ដូច្នេះ ឥណទានត្រូវសងវិញជាទៀងទាត់ក្នុងរយៈពេល ៦ខែ ដោយ៥ខែដំបូងត្រូវសងតែការប្រាក់ ។ ចំនួនប្រាក់ដើមសងរំលោះរៀងរាល់ខែគឺ ១,២០០,០០០/៦= ២០០,០០០ រៀល ។

៣.៥.១ ការគណនាការប្រាក់

ការគណនាការប្រាក់តាមរបៀប Declining balance calculation សម្រាប់គ្រប់ផលិតផលឥណទានបុគ្គលទាំងអស់ហើយគណនាតាមចំនួនថ្ងៃដែលបានប្រើប្រាស់

- រូបមន្តគណនាការប្រាក់

I= (PB× MIR ×12 × ND)/365

I (Interest) : ការប្រាក់

PB (Principle Balance) : ចំនួនប្រាក់កម្ចីក្នុងដៃអតិថិជន

MIR (Monthly Interest Rate) : អត្រាការប្រាក់ឥណទានប្រចាំខែ

12 (Number of Monthy per year : ចំនួនខែក្នុង ១ឆ្នាំ

ND : ចំនួនថ្ងៃបានប្រើប្រាស់កម្ចី

365 (Number of days Per Year) : ចំនួនថ្ងៃក្នុង ១ឆ្នាំ

- រូបមន្តការប្រាក់តំរឹម

ការប្រាក់តំរឹម=(ប្រាក់ខ្ចីសរុប×អត្រាការប្រាក់ប្រចាំខែ×១២×ចំនួនថ្ងៃតំរឹម)/365

- រូបមន្តនៃការគណនាការប្រាក់ដើមត្រូវសង
  - ប្រាក់ដើមត្រូវសងគ្មានរយៈពេលអនុគ្រោះ=ប្រាក់ខ្ចីសរុប/រយៈពេលខ្ចីសរុប
  - ប្រាក់ដើមត្រូវសងមានរយៈពេលអនុគ្រោះ= ប្រាក់ខ្ចីសរុប / (រយៈពេលខ្ចីសរុប - រយៈពេលអនុគ្រោះ)
  - សេវារដ្ឋបាល=ប្រាក់សងលើសដែនការក្នុងពីរដំណាក់កាលដំបូង × អត្រាប្រចាំខែ

៣.៥.២ ការគណនាការប្រាក់បន្តលើចំណុលខកខានមិនបានសង

ក្នុងករណីដែលអតិថិជនខកខានមិនបានសងប្រាក់តាមតារាងសងប្រាក់ឥណទាន ឬតាមកិច្ចសន្យាខ្ចីប្រាក់នោះ ត្រូវគិតការប្រាក់បន្តរហូតដល់ ១២ខែ បន្ទាប់ពីបញ្ចប់វគ្គនៃការសងឥណទានរបស់អតិថិជន ឬរហូតដល់បំណុលនេះមានការប្តឹងទៅតុលាការដើម្បីដោះស្រាយ ។

៣.៥.៣ ការពន្យាពេលសងប្រាក់

ក្នុងករណីដែលអតិថិជនមានបញ្ហាខ្លះៗលើចរាចរណ៍សាច់ប្រាក់របស់ខ្លួននោះ អតិថិជនអាចសុំធ្វើការពន្យាពេលសងប្រាក់ឥណទានចំនួនម្តងក្នុង ១វគ្គនៃការខ្ចីប្រាក់ ដែលមានរយៈពេលអតិបរមាចំនួន ៤ខែ ។

- **លក្ខខ័ណ្ឌនៃការពន្យាពេលសង**

ការពន្យាពេលសងប្រាក់ឥណទានអាចអនុញ្ញាតិឲ្យបានគ្រប់ប្រភេទនៃទំហំឥណទាន(ទោះបីជាការខ្ចីដោយមាន ឬគ្មានរយៈពេលអនុគ្រោះក៏ដោយ) ប៉ុន្តែត្រូវអនុលោមតាមលក្ខខ័ណ្ឌដូចខាងក្រោម៖

- អតិថិជនអាចស្នើសុំធ្វើការពន្យាពេលសងបានតែម្តងក្នុង ១វគ្គ នៃការខ្ចីប្រាក់តែប៉ុណ្ណោះ
- អតិថិជនត្រូវតែសងប្រាក់ក្នុងខែមុនៗឲ្យបានគ្រប់ចំនួនទាំងការប្រាក់ និងប្រាក់ដើម
- អតិថិជនត្រូវមានប្រវត្តិសងល្អពីមុនកន្លងមក
- អតិថិជនត្រូវផ្តល់ពត៌មានជាមុនរយៈពេល ១ខែ ។

- **ការអនុម័តលើការពន្យាពេលសង**

ការអនុម័តលើចំនួនរយៈពេលនៃការពន្យាពេលសង គឺត្រូវធ្វើឡើងយ៉ាងហោចណាស់ត្រឹមប្រធានសាខាស្រុកដោយមានការចូលរួមនិងសំណើបញ្ជាក់ពីភ្នាក់ងារឥណទាន ដែលទទួលខុសត្រូវ ។

៣.៦ ការផាកពិន័យ និងការលុបចោលប្រាក់ពិន័យ

៣.៦.១ ការពិន័យ

ការខកខានមិនបានសងប្រាក់ឲ្យគ្រប់ចំនួនតាមកាលកំណត់នៃតារាងសងប្រាក់ឬកិច្ចសន្យាខ្ចីប្រាក់ គឺជាផ្នែកមួយដែលត្រូវចាត់ទុកជាការរំលោភបំពានលើកិច្ចសន្យា ។ ដូច្នេះ ភាគីណាដែលរំលោភបំពានលើកិច្ចសន្យាខ្ចីប្រាក់ត្រូវតែទទួលការផាកពិន័យ ។ ប្រាក់ផាកពិន័យត្រូវតែធ្វើការគណនាស្មើនឹង ២ដង នៃអត្រាការប្រាក់ដែលបានខ្ចីទៅលើចំនួនប្រាក់សរុប (រួមមានប្រាក់ដើម និងការប្រាក់) ដែលខកខានមិនបានសងទៅតាមចំនួនថ្ងៃដែលសងយឺត ។

- រូបមន្តនៃការពិន័យត្រូវកំណត់ដូចខាងក្រោម

$$P=(OA \times 2 \times MIR \times 12 \times OD)/365$$

P (Penalty) : ជាប្រាក់ពិន័យ

OA (Overdue Amount) : ជាចំនួនប្រាក់សរុបដែលខកខានមិនបានសង

MIR (Monthly Interest Rate) : ជាអត្រាការប្រាក់ប្រចាំខែ

12 (Number of Month a year : ចំនួនខែក្នុង ១ឆ្នាំ

OD (Number of Overdue days) : ចំនួនថ្ងៃដែលខកខានមិនបានសង

365 (Number of days per year) : ចំនួនថ្ងៃក្នុង ១ឆ្នាំ

✍ **ចំណាំ:** ការពិន័យនេះ គឺត្រូវអនុវត្តន៍រហូតដល់មានការសងត្រឹមត្រូវឡើងវិញ ។ ប៉ុន្តែអតិថិជនមិនអាចខកខានសងឥណទានលើសពី ២ដងបានទេ ពោលគឺនៅខែទី៣ ភ្នាក់ងារឥណទានត្រូវមានចំណាត់ការតាមច្បាប់ចំពោះអតិថិជនណា ដែលខកខានមិនបានសងប្រាក់តាមកិច្ចសន្យាដើម្បីរកប្រភពទូទាត់សងប្រាក់ឥណទានដល់ អម្រឹត ។

៣.៦.២ ការលុបបំណុលបាត់បង់

ការលុបបំណុលដែលបាត់បង់ គឺត្រូវធ្វើឡើយតាមលក្ខខ័ណ្ឌដូចខាងក្រោម៖

- ជាបំណុលដែលខកខានមិនបានសង ហើយមានរយៈពេលលើសពី ៣៦៥ថ្ងៃ
- ជាបំណុលបាត់បង់ដែលធ្វើសំវិធានធន ១០០% រួចហើយ

✍ **ចំណាំ:** ករណីបន្ទាប់ពីលុបចោលបំណុលរួចហើយ ក្រោយមកអតិថិជននោះមកសងប្រាក់វិញ ប្រាក់នោះនឹងក្លាយជាប្រាក់ចំណូលសុទ្ធរបស់ អម្រឹតដែលរកបាន ។

៣.៧ ហានិភ័យឥណទានដែលឆ្លាប់ជួបប្រទះ

ហានិភ័យឥណទានដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ធ្លាប់បានជួបប្រទះកន្លងមកមានពីរប្រភេទ៖

- **ហានិភ័យផ្ទៃក្នុង**

ហានិភ័យផ្ទៃក្នុង គឺជាហានិភ័យដែលបង្កឡើងដោយសារភ្នាក់ងារឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ហើយមូលហេតុដែលនាំឲ្យមានហានិភ័យកើតឡើងគឺដោយសារ :

- ភ្នាក់ងារឥណទានជាអ្នកកាន់លុយ
- ភ្នាក់ងារឥណទានត្រូវអ្នកដទៃបោកប្រាស់
- ខ្វះការត្រួតពិនិត្យពីប្រធានសាខ៉ី
- ការទុកចិត្តរបស់ប្រធានសាខ៉ីទៅលើភ្នាក់ងារឥណទាន ។

- **ហានិភ័យអតិថិជន**

ហានិភ័យអតិថិជន គឺជាហានិភ័យដែលបង្កឡើងដោយអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ។ ហើយហានិភ័យអតិថិជននេះអាចកើតឡើងដោយសារមួយមូលហេតុមួយចំនួនដូចខាងក្រោម :

- អតិថិជនដែលខ្វីប្រាក់យកទៅប្រកបអាជីវកម្មទទួលបរាជ័យ
- អតិថិជនទទួលការបោកប្រាស់ពីអ្នកដទៃ
- អតិថិជនធ្វើចំណាកស្រុកបន្ទាប់ពីទទួលបានឥណទាន
- អតិថិជនធ្វើការខ្វីលុយពីច្រើនប្រភព
- អតិថិជនយកប្រាក់ឥណទានដែលទទួលបានទៅប្រើប្រាស់ខុសគោលដៅ ។

៣.៨ យុទ្ធសាស្ត្រក្នុងការទប់ស្កាត់ហានិភ័យ

- **ហានិភ័យផ្ទៃក្នុង**

ដើម្បីទប់ស្កាត់នូវហានិភ័យផ្ទៃក្នុងដែលកើតមានឡើងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតបានបង្កើតឡើងនូវយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម ៖

- រៀបចំគោលនយោបាយចាប់កំហុស
- បុគ្គលិកដែលចូលធ្វើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ត្រូវមានកិច្ចសន្យា និងការធានាពីសំណាក់ ឪពុកម្តាយ ញាតិមិត្តបងប្អូនដែលមានសម្តភាពគ្រប់គ្រាន់ក្នុងការធានា
- លើកទឹកចិត្តបុគ្គលិកដែលហានរាយការណ៍ដោយបង្កើតជាប្រអប់អនាមិក
- បង្កើតជាគណៈកម្មាការឥណទានដើម្បីត្រួតពិនិត្យទៅលើការផ្តល់ឥណទាន និងអតិថិជន
- ប្រធានសាខីត្រូវពង្រឹងការតាមដាន និងត្រួតពិនិត្យឡើងវិញ
- រៀបចំបង្កើតច្បាប់សម្រាប់ធ្វើការផ្លាស់ប្តូរទីតាំងការងាររបស់ភ្នាក់ងារឥណទាន នូវរៀងរាល់ ២ឆ្នាំម្តងប្រធានសាខាស្រុករៀងរាល់ ៣ឆ្នាំម្តង និងប្រធានសាខាខេត្តរៀងរាល់ ៥ឆ្នាំម្តង ។

- **ហានិភ័យអតិថិជន**

ចំពោះហានិភ័យអតិថិជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត បានរៀបចំយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម ៖

- បង្កើតទំនាក់ទំនងល្អជាមួយអតិថិជន
- តាមដានការប្រើប្រាស់ទុនរបស់អតិថិជន

- ផ្តល់សេវាឲ្យអតិថិជនឲ្យបានលឿន
- ផ្តល់យោបល់ដល់អតិថិជនក្នុងការប្រើប្រាស់ទុន ។

៣.៩ នីតិវិធីដោះស្រាយបញ្ហាពេលជួបហានិភ័យ

៣.៩.១ ឥណទានបុគ្គល

- **មូលហេតុដែលនាំឲ្យមានហានិភ័យគឺ៖**

- ការពិនិត្យលើសំណើនៃគម្រោងសុំខ្ចីមិនច្បាស់លាស់
- វត្ថុដាក់ធានាសំខាន់មានដីធ្លីដែលជំរុញឲ្យអតិថិជនសងប្រាក់
- ការពិនិត្យមិនច្បាស់លាស់នូវសកម្មភាពសងប្រាក់របស់អតិថិជន ។

- **បញ្ហា និងការដោះស្រាយ**

ការយឺតយ៉ាវក្នុងការសងប្រចាំខែដែលមានដំណោះស្រាយដូចតទៅ៖

- ភ្នាក់ងារត្រូវដឹងច្បាស់ពីបញ្ហាដែលបណ្តាលឲ្យសងយឺតយ៉ាវ ត្រូវជួបប្រាស្រ័យទាក់ទងជាមួយនឹងអ្នកខ្ចីដើម្បីរកវិធានការសងប្រាក់ឲ្យបាននូវពេលក្រោយ (ប្រសិនជាគេមិនសង ប៉ុន្តែចង់សង)

- ក្នុងករណីអ្នកខ្ចីចង់រត់ចេញពីភូមិដោយមិនចង់សងប្រាក់ ដល់ភ្នាក់ងារត្រូវបញ្ជូនដំណឹងដល់អ្នកទំនាក់ទំនងខេត្តព្រមទាំងប្តឹងទៅអាជ្ញាធរដើម្បីដោះស្រាយបញ្ហានេះ

- ភ្នាក់ងារត្រូវរកពីមូលហេតុមិនសងនេះ បន្ទាប់មកត្រូវគិតគូរលើចំណូលរបស់អ្នកខ្ចីសារជាថ្មី រួចកំណត់រយៈពេលសងដោយអាស្រ័យលើលទ្ធភាពរបស់អ្នកខ្ចីជាក់ស្តែង ។ បើមានបញ្ហារហូតដល់មិនចង់សងនោះ ភ្នាក់ងារត្រូវបញ្ជូនពត៌មានទៅអ្នកទំនាក់ទំនងខេត្ត ដើម្បីដកហូតយកនូវទ្រព្យសម្បត្តិដែលអតិថិជនបានដាក់ធានា ឬលក់ដើម្បីសងនូវប្រាក់ដែលបានជំពាក់ ។

- **ការមិនសងគ្រប់ចំនួននៅពេលបញ្ចប់វគ្គឥណទានមានដំណោះស្រាយដូចតទៅ៖**

- បើអតិថិជនមានបំណងចង់សងតែគ្មានលទ្ធភាពសងភ្នាក់ងារត្រូវភាក្សា ជាមួយសមាជិកខ្ចី ហើយផ្តល់នូវរយៈពេលមួយកំណត់ដោយមើលលើលទ្ធភាពពិតប្រាកដរបស់អ្នកខ្ចីនោះ ដោយធ្វើការកែសំរួលលើរយៈពេលសង

- បើអតិថិជនមិនចង់សងតែម្តងនោះភ្នាក់ងារ ត្រូវបញ្ជូនដំណឹងទៅអ្នកទំនាក់ទំនងខេត្ត ហើយទំនាក់ទំនងនឹងអាជ្ញាធរដើម្បីធ្វើការរឹបអូសទ្រព្យសម្បត្តិ (របស់ធានា) ទៅតាមតម្លៃទឹកប្រាក់ដែលជំពាក់ ។

៣.៩.២ ឥណទានក្រុមធានា

បញ្ហាដែលកើតឡើងក្នុងឥណទានក្រុមធានា ជាទូទៅមានតែ ២ប៉ុណ្ណោះ គឺការមិនសងរបស់សមាជិកណាម្នាក់នៃក្រុម និងការសងយឺតយ៉ាវ

- **ការមិនសងរបស់សមាជិកណាម្នាក់នៃក្រុម**

- ដំណោះស្រាយមានដូចតទៅ៖

- ប្រជុំក្រុមណាដែលមិនសងនោះលើបញ្ហាដែលគាត់មិនសង

- ជំរុញឲ្យក្រុមទាំងមូលចេញសង បើមិនដូច្នេះទេនៅវគ្គក្រោយក្រុមនេះនឹងត្រូវរំសាយ

- ករណីក្រុមនៅតែមិនជួយចេញសង ជាលក្ខណៈធានានោះទេភ្នាក់ងារត្រូវប្រជុំគណៈកម្មាការបេឡាភូមិឲ្យធ្វើអន្តរាគមន៍ហើយប្រាក់ឧបត្ថម្ភនឹងមិនផ្តល់ជូនប្រសិនបើបិទវគ្គមិនជិត

- បើធ្វើដូច្នេះ ហើយនៅតែមិនបានសម្រេចទៀតនោះ ភ្នាក់ងារត្រូវរៀបចំប្រជុំភូមិដោយជំរុញអ្នកភូមិប្រើសម្ពាធភូមិដើម្បីឲ្យសមាជិកនោះសង ព្រោះខ្លាចមិនបានខ្ចីនៅវគ្គក្រោយៗទៀតត្រូវគេបិទបេឡាភូមិនេះចោល

- ម៉្យាងទៀតយើងត្រូវប្រើកិច្ចសន្យាដែលអ្នកខ្ចីបានធ្វើជាមួយ ឲ្យគាត់អនុវត្តន៍តាមផ្លូវច្បាប់ជាលាយលក្ខអក្សរ បើនៅតែមិនបានសម្រេចទៀតនោះ គឺត្រូវប្តឹងអាជ្ញាធរដើម្បីដោះស្រាយពីការមិនសងនោះ ។

- **ការសងយឺតយ៉ាវ**

- ដំណោះស្រាយមានដូចតទៅ៖

- ជំរុញឲ្យប្រធានក្រុមប្រមូលនូវប្រាក់ដើម និងការប្រាក់ត្រូវបង់ប្រចាំខែដើម្បីយកមកសងឲ្យទាន់ពេលវេលា

- មុនពេលដល់ថ្ងៃបង់ប្រាក់ត្រូវ ឲ្យគណៈកម្មាការរំលឹកដល់ក្រុមទាំងអស់ ពីថ្ងៃបង់ប្រាក់

- ព្រមានក្រុមទាំងឡាយដែលបង់យឺតយ៉ាវដោយឲ្យសងទាន់ពេលវេលា បើមិនដូច្នេះទេនឹងរំសាយក្រុមនោះចោលសម្រាប់វគ្គថ្មី ឬព្រមានឲ្យសមាជិកដែលបង់យឺតដោយដកចេញពីក្រុម គឺប្រើសម្ពាធក្រុមសម្រាប់គៀបឲ្យសង

- ប្រសិនបើសមាជិកដែលបង់យឺតយ៉ាវពិតជាគ្មានលទ្ធភាពសងមែន ត្រូវឲ្យក្រុមនោះជួយចេញសង និងពន្យាពេលឲ្យសមាជិកនោះសងយ៉ាងយូរបំផុតរយៈពេល ៥ថ្ងៃ ។

សរុបសេចក្តីមកសម្រាប់ប្រតិបត្តិការនៃឥណទានក្រុមធានា និងឥណទានបុគ្គល គឺមិនមានជាបញ្ហាអ្វីដើម្បីផ្តល់ការលំបាកដល់ភ្នាក់ងារក្នុងការដោះស្រាយនោះទេ ផ្ទុយមកវិញភ្នាក់ងារជួបបញ្ហាក្នុងការធ្វើដំណើរ និងរក្សាប្រាក់សងមកទីស្នាក់ការខេត្តតែប៉ុណ្ណោះ ។

៣.១០ លទ្ធផលនៃការស្រាវជ្រាវ

៣.១០.១ សមតុល្យឥណទានខ្នាតតូចពីឆ្នាំ ២០១៤-២០១៦

តារាងបង្ហាញពីភាពប្រែប្រួលនៃសមតុល្យឥណទានពីឆ្នាំ ២០១៤-២០១៦

ឆ្នាំ	២០១៤	២០១៥	២០១៦
	KHR	KHR	KHR
សមតុល្យឥណទានខ្នាតតូចសរុប	១៩.៦៨៦.៦១៤	២៤.៨៧៤.៦៧២	៣០.២៨១.៣២៥
បំរែបំរួលឥណទាន	-	៥.១៨៨.០៥៨	៥.៤០៦.៦៥៣
អត្រាបំរែបំរួល	-	២៦%	២២%

ប្រភព: របាយការណ៍ឥណទានប្រចាំឆ្នាំ២០១៤-២០១៦របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាបាទី (ឧបសម្ព័ន្ធទី៣)

ដ្យាក្រាមបង្ហាញពីភាពប្រែប្រួលនៃសមតុល្យឥណទាន



យោងតាមទិន្នន័យ ដែលទទួលបានពីរបាយការណ៍ឥណទានប្រចាំឆ្នាំ ២០១៤-២០១៦ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាទីបានបង្ហាញឲ្យឃើញថា សមតុល្យឥណទានដែលបានបញ្ចេញសរុបក្នុងឆ្នាំ ២០១៤ មានចំនួន ១៩.៦៨៦.៦១៤ រៀល ហើយនៅក្នុងឆ្នាំ ២០១៥ វិញមានចំនួន ២៤.៨៧៤.៦៧២ រៀល ។ បើធៀបនឹងឆ្នាំ ២០១៤ ការផ្តល់ឥណទានមានការកើឡើង

ចំនួន ៥.១៨៨.០៥៣ រៀល ដែលស្មើនឹង ២៦% ។ នៅឆ្នាំ ២០១៦ វិញចំនួននៃការផ្តល់ឥណទានមាន ៣០.២៨១.៣២៥ រៀល ហើយបើធៀបនឹងឆ្នាំ ២០១៥ ឃើញថាមានការកើនឡើងចំនួន ៥.៤០៦.៦៥៨ រៀល ដែលស្មើនឹង ២២% ។

៣.១០.២ សមតុល្យឥណទានខ្នាតតូចដែលសងយឺត ២០១៤-២០១៦

តារាងបង្ហាញពីភាពប្រែប្រួលនៃឥណទានដែលសងយឺតពីឆ្នាំ ២០១៤-២០១៦

ឆ្នាំ	២០១៤	២០១៥	២០១៦
	KHR	KHR	KHR
សមតុល្យឥណទានដែលសងយឺត	២២.៧៦៤	៩.៦៥៧	១៩.៥៩១
សមតុល្យឥណទានខ្នាតតូច	១៩.៦៨៦.៦១៤	២៤.៨៧៤.៦៧២	៣០.២៨១.៣២៥
អត្រាបំរែបំរួល	០,១២%	០,០៤%	០,០៦%

ប្រភព:របាយការណ៍ឥណទានប្រចាំឆ្នាំ ២០១៤- ២០១៦របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាបាទី (ឧបសម្ព័ន្ធទី៣)

ដ្យាក្រាមបង្ហាញពីភាពប្រែប្រួលនៃឥណទានដែលសងយឺត



យោងតាមទិន្នន័យ ដែលទទួលបានពីរបាយការណ៍ឥណទានប្រចាំឆ្នាំ ២០១៤-២០១៦ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាទីបានបង្ហាញឲ្យឃើញថា សមតុល្យឥណទាន

សរុបក្នុងឆ្នាំ ២០១៤ មានចំនួន ១៩.៨៦៦.៦១៤ រៀល ហើយនៅក្នុងនោះ ឥណទានដែលសងយឺតមានចំនួន ២២.៧៦៤ រៀល ដែលស្មើនឹង ០,១២% ។ ហើយនៅក្នុងឆ្នាំ ២០១៥ មានចំនួន ២៤.៨៧៤.៦៧២ រៀល ដែលក្នុងនោះឥណទានដែលសងយឺតមានចំនួន ៩.៦៥៧ រៀល ដែលស្មើនឹង ០,០៤% ។ ហើយនៅឆ្នាំ ២០១៦ វិញចំនួននៃការផ្តល់ឥណទានមាន ៣០.២៨១.៣២៥ រៀល ដែលក្នុងនោះឥណទានដែលសងយឺតមានចំនួន ១៩.៥៩១ រៀល ស្មើនឹង ០,០៦% ។

៣.១០.៣ សមតុល្យឥណទានដែលលុបចេញពីបញ្ជី ២០១៤-២០១៦

តារាងបង្ហាញពីភាពប្រែប្រួលនៃឥណទានដែលលុបចេញពីឆ្នាំ ២០១៤-២០១៦

ឆ្នាំ	២០១៤	២០១៥	២០១៦
	KHR	KHR	KHR
សមតុល្យឥណទានដែលលុបចេញពីបញ្ជី	៦៤.៨៥៣	៨៣.៨៨២	៥៥.២៨៨
សមតុល្យឥណទានខ្នាតតូច	១៩.៦៨៦.៦១៤	២៤.៨៧៤.៦៧២	៣០.២៨១.៣២៥
អត្រាបំរែបំរួល	០,៣៣ %	០,៣៤ %	០,១៨ %

ប្រភព:របាយការណ៍ឥណទានប្រចាំឆ្នាំ ២០១៤ ២០១៦របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាបាទី (ឧបសម្ព័ន្ធទី៣)

ដ្យាក្រាមបង្ហាញពីភាពប្រែប្រួលនៃឥណទានដែលលុបចេញពីបញ្ជី



យោងតាមទិន្នន័យដែលទទួលបានពីរបាយការណ៍ឥណទានប្រចាំឆ្នាំ ២០១៤-២០១៦ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាបាទីបានបង្ហាញឲ្យឃើញថា សមតុល្យឥណទានសរុបក្នុងឆ្នាំ ២០១៤មានចំនួន ១៩.៦៨៦.៦១៤ រៀល ហើយនៅក្នុងនោះឥណទានដែលបានលុបចេញពី

បញ្ជើមានចំនួន ៦៥.៨៥៣ រៀល ដែលស្មើនឹង ០,៣៣% ។ ហើយនៅឆ្នាំ ២០១៥ មានចំនួន ២៤.៨៧៤.៦៧២ រៀល ដែលក្នុងនោះឥណទានដែលបានលុបចេញពីបញ្ជើមានចំនួន ៨៣.៨៨២ រៀល ដែលស្មើនឹង ០,៣៤% ។ ហើយនៅឆ្នាំ ២០១៦ វិញចំនួននៃការផ្តល់ឥណទានមាន ៣០.២៨១.៣២៥ រៀល ដែលក្នុងនោះឥណទានដែលបានលុបចេញពីបញ្ជើមានចំនួន ៥៥.២៨៨ រៀល ស្មើនឹង ០,១៨% ។

យោងតាមការបកស្រាយខាងលើយើងអាចសន្និដ្ឋានបានដូចខាងក្រោម:

- **<u>ឆ្នាំ ២០១៤</u>**

សមតុល្យឥណទានដែលបានបញ្ចេញគឺមានចំនួន ១៩.៦៨៦.៦១៤ រៀល ហើយសមតុល្យឥណទានដែលសងយឺតមានចំនួន ២២.៧៦៤ រៀល ត្រូវជា ០,១២% ។ ចំណែកឯសមតុល្យឥណទានដែលលុបចេញពីបញ្ជើមានចំនួន៦៤.៨៥៣ រៀលត្រូវជា ០,៣៣ % ។

- **<u>ឆ្នាំ ២០១៥</u>**

សមតុល្យឥណទានដែលបានបញ្ចេញគឺមានចំនួន ២៤.៨៧៤.៦៧២ រៀល ហើយសមតុល្យឥណទានដែលសងយឺតមានចំនួន ៩.៦៥៧ រៀល ត្រូវជា ០,០៤% ។ ចំណែកឯសមតុល្យឥណទានដែលលុបចេញពីបញ្ជើមានចំនួន ៨៣.៨៨២ រៀល ត្រូវជា ០,៣៤ % ។ យើងសង្កេតឃើញថាសមតុល្យឥណទានដែលបញ្ចេញលើសពីឆ្នាំ ២០១៤ ហើយសមតុល្យឥណទានដែលសងយឺតតិចជាងឆ្នាំ ២០១៤ នាំឲ្យយើងអាចសន្និដ្ឋានបានថា ការគ្រប់គ្រងឥណទានឆ្នាំ ២០១៥ មានប្រសិទ្ធិភាពជាងឆ្នាំ ២០១៤ ទោះបីជាមានសមតុល្យឥណទានដែលលុបចេញពីបញ្ជីច្រើនជាង ២០១៤ ក៏ដោយពីព្រោះសមតុល្យនេះកើនឡើងដោយសារតែបង្គរពីឆ្នាំមុនៗ ។

- **<u>ឆ្នាំ ២០១៦</u>**

សមតុល្យឥណទានដែលបានបញ្ចេញគឺមានចំនួន ៣០.២៨១.៣២៥ រៀល ហើយសមតុល្យឥណទានដែលសងយឺតមានចំនួន ១៩.៥៩១ រៀល ត្រូវជា ០,០៦% ។ ចំណែកឯសមតុល្យឥណទានដែលលុបចេញពីបញ្ជើមានចំនួន ៥៥.២៨៨ រៀល ត្រូវជា ០,៣៤% ។ យើងសង្កេតឃើញថាសមតុល្យឥណទានដែលបញ្ចេញលើសពីឆ្នាំ ២០១៥ ហើយសមតុល្យឥណទាន ដែលសងយឺតមានចំនួនច្រើនជាងឆ្នាំ ២០១៥ នាំឲ្យយើងអាចសន្និដ្ឋានបានថា ការគ្រប់គ្រងឥណទានឆ្នាំ ២០១៦ មានប្រសិទ្ធិភាពជាងឆ្នាំ ២០១៥ ព្រោះសមតុល្យឥណទាន ដែលលុបចេញពីបញ្ជើមានចំនួនតិចជាង ២០១៥ ដោយសារតែសមតុល្យនេះអាចប្រមូលមកវិញបានមួយចំនួន ។

៣.១១ ការសិក្សាទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ អម្រឹតសាខាបាទី

តាមរយៈការសិក្សាស្រាវជ្រាវ ពីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ឃើញថា សេវាកម្មផ្នែកឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី យើងសង្កេតឃើញថាការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាមានចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម:

៣.១១.១ ចំណុចខ្លាំងរបស់អម្រឹត

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតមាននីតិវិធីនិងគោលការណ៍ច្បាស់លាស់ក្នុងការផ្តល់កម្ចីដល់អតិថិជន
- ការខ្ចី-សងអាចធ្វើឡើងនៅមូលដ្ឋានរបស់អតិថិជនផ្ទាល់ គឺបានផ្តល់ដល់ភាពងាយស្រួលដល់ពួកគាត់ក្នុងការខ្ចីប្រាក់ និងសងប្រាក់ដល់ អម្រឹត
- បុគ្គលិកមាន ទំនាក់ទំនងល្អជាមួយ អាជ្ញាធរ និងចំពោះប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ប្រតិបត្តិការរបស់ អម្រឹត ដែលផ្តល់ឲ្យអម្រឹតដំណើរការសកម្មភាពបានយ៉ាងរលូន
- ករណីអតិថិជនដែលមានសមត្ថភាពបង់ផ្តាច់ គឺមិនត្រូវបានគិតការប្រាក់ ឬ ប្រាក់ពិន័យសម្រាប់ខែដែលនៅសល់នោះទេ ។
- សមតុល្យឥណទានកើនឡើងជារៀងរាល់ឆ្នាំ
- គ្រឹះស្ថានមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ផ្តល់ជូនអតិថិជន

៣.១១.២ ចំណុចខ្សោយរបស់អម្រឹត

អ្វីៗគ្រប់យ៉ាងដែលកើតឡើងគ្មានអ្វីដែលល្អឥតខ្ចោះនោះទេ គឺសុទ្ធតែមានចំណុចខ្លាំង និងចំណុចខ្សោយ ។ ដូចគ្នាដែរចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី ទោះបីមានចំណុចខ្លាំងជាច្រើន ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតនៅមិនទាន់មានទូ ATM គ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់អតិថិជននោះទេ ។
- គ្រឹះស្ថានមានដំណាក់កាល និងលក្ខខ័ណ្ឌច្រើនក្នុងការផ្តល់កម្ចីទៅឲ្យអតិថិជន
- គ្រឹះស្ថាននៅមិនទាន់មានស្លាកសញ្ញាដែលដាក់បង្ហាញនៅតាមផ្ទះគណៈកម្មាការនៅឡើយ
- ការផ្សព្វផ្សាយមិនទាន់ទូលំទូលាយ ។

១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើដំណើរការនៃការផ្តល់ឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី រួចមកបានឲ្យឃើញថា ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី មានការរីកចម្រើនឥតឈប់ឈរ ពីមួយថ្ងៃទៅមួយថ្ងៃ និងទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋខ្មែរមួយភាគធំ ម៉្យាងទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានគោលនយោបាយដ៏ប្រសើរដែលអំណោយផលល្អដល់គ្រឹះស្ថានដូចជា គោលនយោបាយមិនប្រកាន់បក្សពួក ដែលជាគោលនយោបាយមួយធ្វើឲ្យបុគ្គលិកយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងធ្វើការងារអស់ពីសមត្ថភាពរបស់ខ្លួន ព្រោះថាអ្នកណាជាអ្នកធ្វើ អ្នកនោះជាអ្នកទទួលផល ហើយក៏មាននូវគោលនយោបាយផ្តល់ប្រាក់រង្វាន់ជូនដល់បុគ្គលិកឆ្នើម ដែលបានជួយឲ្យការងារកាន់តែមានសន្ទុះខ្លាំងក្លាឡើងថែមមួយកម្រិតទៀត និងជួយឲ្យ អម្រឹត ឆាប់សម្រេចបាននូវទិសដៅការងារដែលខ្លួនដាក់ចេញនោះ ។ គ្រឹះស្ថានក៏បានដាក់ចេញនូវច្បាប់វិន័យហ្មត់ចត់ព្រមទាំងមានផ្តល់នូវសេវាកម្មថ្មីៗជាច្រើនដែលផ្តល់លក្ខណៈងាយស្រួលដល់អតិថិជន ។ លើសពីនេះទៅទៀត គ្រឹះស្ថានក៏បានផ្តល់ជូនអតិថិជននូវ រយៈពេលអនុគ្រោះដោយទុកលទ្ធភាពឲ្យពួកគាត់អាចប្រមូលផលពីមុខរបររបស់ខ្លួនបាន ហើយប្រសិនបើពួកគាត់បង់ផ្តាច់នៅខែទី ៣វិញនោះសម្រាប់ខែដែលនៅសល់ គឺពុំត្រូវបានគិតការប្រាក់បន្តទៀតឡើយ ។ កត្តាទាំងនេះហើយបានជំរុញឲ្យអតិថិជនពេញចិត្តសម្រាប់ការទទួលយកឥណទានពីគ្រឹះស្ថាន អម្រឹត ហើយព្រមជាមួយគ្នានេះទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ក៏មានទំនាក់ទំនងល្អជាមួយធអាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ និងប្រជាជនទាំងអស់គ្នា ដែលជួយឲ្យ អម្រឹត កាន់តែមានភាពងាយស្រួលក្នុងដំណើរការនៃសកម្មភាពការងារ ។ មួយវិញទៀត គ្រឹះស្ថានក៏កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមវិភាគទាន ក្នុងគម្រោងកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមទីជនបទ តាមរយៈការផ្តល់ហិរញ្ញប្បទានទៅលើវិស័យកសិកម្ម និងសហគ្រាសខ្នាតតូចជាដើម ។ យ៉ាងណាមិញឥណទានដែលបានបញ្ចេញរបស់គ្រឹះស្ថាន ឃើញថាមានការកើនឡើងជារៀងរាល់ឆ្នាំ នេះបញ្ជាក់ឲ្យឃើញថាការផ្តល់ឥណទានរបស់គ្រឹះស្ថានមានដំណើរការល្អ ។ ថ្វីត្បិតតែការបញ្ចេញឥណទានមានការកើនឡើងក៏ពិតមែន ប៉ុន្តែគ្រឹះស្ថានក៏ត្រូវប្រឈមមុខនឹងបញ្ហាមួយចំនួនដោយសារអតិថិជនមាន ការសងយឺតយ៉ាវ និងការខកខានមិនបានសងផងដែរ ។

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបានថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតពិតជាមានការរីកចម្រើន និងរឹងមាំព្រោះថាមានចំណុចជាច្រើនដែលអំណោយផលល្អដល់ប្រតិបត្តិការអាជីវកម្ម

សេចក្តីសន្និដ្ឋាន

និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើដំណើរការនៃការផ្តល់ឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី រួចមកបានឲ្យឃើញថា ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតសាខាបាទី មានការរីកចម្រើនឥតឈប់ឈរ ពីមួយថ្ងៃទៅមួយថ្ងៃ និងទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋខ្មែរមួយភាគធំ ម៉្យាងទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានគោលនយោបាយដ៏ប្រសើរដែលអំណោយផលល្អដល់គ្រឹះស្ថានដូចជា គោលនយោបាយមិនប្រកាន់បក្សពួក ដែលជាគោលនយោបាយមួយធ្វើឲ្យបុគ្គលិកយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងធ្វើការងារអស់ពីសមត្ថភាពរបស់ខ្លួន ព្រោះថាអ្នកណាជាអ្នកធ្វើ អ្នកនោះជាអ្នកទទួលផល ហើយក៏មាននូវគោលនយោបាយផ្តល់ប្រាក់រង្វាន់ជូនដល់បុគ្គលិកឆ្នើម ដែលបានជួយឲ្យការងារកាន់តែមានសន្ទុះខ្លាំងក្លាឡើងថែមមួយកម្រិតទៀត និងជួយឲ្យ អម្រឹត ឆាប់សម្រេចបាននូវទិសដៅការងារដែលខ្លួនដាក់ចេញនោះ ។ គ្រឹះស្ថានក៏បានដាក់ចេញនូវច្បាប់វិន័យហ្មត់ចត់ព្រមទាំងមានផ្តល់នូវសេវាកម្មថ្មីៗជាច្រើនដែលផ្តល់លក្ខណៈងាយស្រួលដល់អតិថិជន ។ លើសពីនេះទៅទៀត គ្រឹះស្ថានក៏បានផ្តល់ជូនអតិថិជននូវ រយៈពេលអនុគ្រោះដោយទុកលទ្ធភាពឲ្យពួកគាត់អាចប្រមូលផលពីមុខរបររបស់ខ្លួនបាន ហើយប្រសិនបើពួកគាត់បង់ផ្តាច់នៅខែទី ៣វិញនោះសម្រាប់ខែដែលនៅសល់ គឺពុំត្រូវបានគិតការប្រាក់បន្តទៀតឡើយ ។ កត្តាទាំងនេះហើយបានជំរុញឲ្យអតិថិជនពេញចិត្តសម្រាប់ការទទួលយកឥណទានពីគ្រឹះស្ថាន អម្រឹត ហើយព្រមជាមួយគ្នានេះទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ក៏មានទំនាក់ទំនងល្អជាមួយធអាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ និងប្រជាជនទាំងអស់គ្នា ដែលជួយឲ្យ អម្រឹត កាន់តែមានភាពងាយស្រួលក្នុងដំណើរការនៃសកម្មភាពការងារ ។ មួយវិញទៀត គ្រឹះស្ថានក៏កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមវិភាគទាន ក្នុងគម្រោងកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមទីជនបទ តាមរយៈការផ្តល់ហិរញ្ញប្បទានទៅលើវិស័យកសិកម្ម និងសហគ្រាសខ្នាតតូចជាដើម ។ យ៉ាងណាមិញឥណទានដែលបានបញ្ចេញរបស់គ្រឹះស្ថាន ឃើញថាមានការកើនឡើងជារៀងរាល់ឆ្នាំ នេះបញ្ជាក់ឲ្យឃើញថាការផ្តល់ឥណទានរបស់គ្រឹះស្ថានមានដំណើរការល្អ ។ ថ្វីត្បិតតែការបញ្ចេញឥណទានមានការកើនឡើងក៏ពិតមែន ប៉ុន្តែគ្រឹះស្ថានក៏ត្រូវប្រឈមមុខនឹងបញ្ហាមួយចំនួនដោយសារអតិថិជនមាន ការសងយឺតយ៉ាវ និងការខកខានមិនបានសងផងដែរ ។

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបានថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹតពិតជាមានការរីកចម្រើន និងរឹងមាំព្រោះថាមានចំណុចជាច្រើនដែលអំណោយផលល្អដល់ប្រតិបត្តិការអាជីវកម្ម

របស់គ្រឹះស្ថាន ។ ទោះបីជាងយ៉ាងនេះក្តី ប្រសិនបើជាគ្រឹះស្ថានមិនយកចិត្តទុកដាក់លើចំណុចខ្វះខាតដែលនៅសេសសល់នេះទេ គ្រឹះស្ថានក៏ពុំទទួលបានជោគជ័យទាំងស្រុងទៅលើដៃគូប្រកួតប្រជែងបានដែរ ។

២. អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ ទៅលើដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត រួចមកយើងអាចនិយាយបានថា គ្រឹះស្ថានពិតជាមានការរីកចម្រើនមែន ។ ប៉ុន្តែទន្ទឹមននឹងភាពរីកចម្រើននេះដែរ ក៏នៅចំណុចខ្វះខាតមួយចំនួនទៀតដែលតម្រូវឲ្យគ្រឹះស្ថានត្រូវមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ឲ្យបានខ្ពស់ហើយយើងខ្ញុំក៏សូមសំណូមពរដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ត្រូវធ្វើការត្រួតពិនិត្យ និងកែលំអរនៅចំណុចខ្វះខាតមួយចំនួនដូចខាងក្រោម៖

- គ្រឹះស្ថានគួរតែបង្កើតទូ ATM បន្ថែមទៀតដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការដកសាច់ប្រាក់
- រយៈពេលបញ្ចេញឥណទានគួរតែធ្វើឲ្យបានឆាប់ជាងនេះទៅទៀត
- ស្តាប់ឆនគួរតែមានស្លាកសញ្ញារបស់ខ្លួននៅតាមផ្ទះប្រធានគណៈកម្មាបេឡាភូមិ ។
- ពង្រីកប្រព័ន្ធផ្សព្វផ្សាយឲ្យបានខ្លាំងក្លា ដើម្បីយកប្រៀបលើដៃគូប្រកួតប្រជែងលើផ្នែកឥណទាន ។

ឯកសារយោង

ឯកសារយោង

- ងួន ហោង, រូបិយវត្ថុ និងធនាគារ (២០១៤),សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច
- ព្រុំ សុគុណ, គណិតវិទ្យាហិរញ្ញវត្ថុ (២០១៤), សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សាស្ត្រាចារ្យ សួន ចំរើន, ទីផ្សារ និងស្ថាប័ន (២០១៥), សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សាស្ត្រចារ្យ អេង កែវពិសិដ្ឋ, គ្រប់គ្រងឥណទាន (២០១៥),សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សៀវភៅសារណារបស់រៀមច្បង ម៉ាប់ សុទ្ធា, ដំណើរការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត (២០១១)
- ឯកសាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត
- WWW.Amret.com

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

ការម្រុងសំណួរ

1) តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាបាទីបង្កើតឡើងនៅឆ្នាំណា?
2) តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតមានទស្សន:និងបេសកម្មយ៉ាងដូចម្តេច?
3) តើឈ្មោះថាអម្រឹតមានអត្ថន័យនិងខ្លឹមសារយ៉ាងណាដែរ?
4) ចូរពន្យល់និងពណ៌នាអំពីផ្លាកសញ្ញារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត?
5) តើអ្វីជាទីផ្សារគោលដៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត?
6) តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាបាទីមានសេវាឥណទានប៉ុន្មានប្រភេទ? អ្វីខ្លះ?
7) តើអតិជិជនត្រូវមានលក្ខណៈសម្បត្តិនិងលក្ខខ័ណ្ឌដូចម្តេចខ្លះទើបទទួលបានឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត?
8) តើគោលការណ៍ឥណទានក្រុមធានានិងឥណទានបុគ្គលរបស់អម្រឹតមានអ្វីខ្លះ?
9) តើទំហំអតិបរមារបស់ឥណទាននីមួយៗមានចំនួនប៉ុន្មាន?
10) តើរយៈពេលខ្ចីរបស់ឥណទានៗនីមួយមានចំនួនប៉ុន្មាន?
11) តើរយៈពេលអនុគ្រោះដែលផ្តល់ដល់អតិថិជនមានន័យយ៉ាងដូចម្តេច?
12) តើភ្នាក់ងារត្រូវធ្វើអ្វីខ្លះនៅពេលមានការស្នើសុំខ្ចីឥណទានពីអតិថិជន?
13) តើអម្រឹតមានវិធានការយ៉ាងណាដើម្បីទប់ស្កាត់ហានិភ័យឥណទាន?
14) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតមានវិធានការយ៉ាងណាចំពោះអតិថិជនដែលបង់យឺតយ៉ាវ?
15) តើអម្រឹតដោះស្រាយយ៉ាងដូចម្តេចនៅពេលដែលជួបប្រទះនូវហានិភ័យ?
16) ដើម្បីអោយដំណើរការនៃការផ្តល់ឥណទានរបស់ខ្លួនទទួលបានជោគជ័យតើអម្រឹតមានយុទ្ធសាស្ត្រយ៉ាងដូចម្តេចខ្លះ?
17) តើអម្រឹតមានភាពខ្លាំងនិងភាពខ្សោយយ៉ាងណាខ្លះទៅលើការផ្តល់ឥណទានរបស់ខ្លួន?
18) បន្ទាប់ពីពេលផ្តល់ឥណទានដល់អតិថិជនរួចតើភ្នាក់ងារត្រូវធ្វើអ្វីខ្លះ?
19) ដើម្បីអាចវិភាគនូវប្រសិទ្ធិភាពនៃការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាយើងខ្ញុំស្នើសុំឯកសារមួយចំនួនដូចជា:
    - ទំហំឥណទានដែលបានបញ្ចេញឆ្នាំ 2014, 2015 និង2016
    - ចំនួនអតិថិជនឆ្នាំ 2014 – 2016
    - ទំហំឥណទានដែលសងយឺតឆ្នាំ 2014 – 2016
    - ទំហំឥណទានដែលលប់ចេញពីបញ្ជី 2014 - 2016

ឧបសម្ព័ន្ធទី២

អ្រមីត

KH0010184-TA-BATI

សក្ខីប័ត្រអោយខ្ចីប្រាក់

26-01-17 1:32:09 PM

គណនីលេខ	(341378-IC0000000232211)
ចំនួនប្រាក់	***3,000.00 ដុល្លារអាមេរិក
ជាអក្សរ	បី ពាន់ដុល្លារអាមេរិក

កាលបរិច្ឆេទប្រគល់ប្រាក់ 26-01-17

ប្រធានបញ្ជរបេឡា	មន្ត្រីឥណទាន	អតិថិជន(បានទទួលប្រាក់)
AMR.SREYLEAK612	ស៊ូ រតនា	មឿន ហេង

អ្នម៊ីក

តារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គល

KH0010184 - TA-BATI
Tel : 023 999 033
LD:1618176955

ឈ្មោះអតិថិជន: កែប ឡុក
លេខសម្គាល់អតិថិជន: 237857
វគ្គទី: 1
អត្រាការប្រាក់ប្រចាំខែ: 2.45%
រយៈពេលខ្ចី(ជាខែ): 15 ខែ
រយៈពេលអនុគ្រោះ(ជាខែ): 0 ខែ

កាលបរិច្ឆេទផ្តល់ប្រាក់កម្ចី: 29/06/16
ទឹកប្រាក់ខ្ចី (1) : 1,000.00 ដុល្លារអាមេរិក
ការប្រាក់សរុបត្រូវសង (2) : 210.61 ដុល្លារអាមេរិក
ថ្លៃសេវាប្រតិបត្តិការ (3) : 0.00 ដុល្លារអាមេរិក
ថ្លៃសេវា CBC (4) : 2.68 ដុល្លារអាមេរិក
សរុបប្រាក់ត្រូវទូទាត់(5)=(1)+(2)+(3)+(4): 1,213.29 ដុល្លារអាមេរិក

ខែទី (ចំនួនថ្ងៃ)	ប្រាក់ដើមនៅជំពាក់	ប្រាក់ដើមត្រូវសង	ការប្រាក់ត្រូវសង	ប្រាក់សរុបត្រូវសង	កាលបរិច្ឆេទត្រូវសង
1 (49)	1,000.00	67.00	39.47	106.47	17/08/16
2 (33)	933.00	67.00	24.80	91.80	19/09/16
3 (28)	866.00	67.00	19.53	86.53	17/10/16
4 (31)	799.00	67.00	19.95	86.95	17/11/16
5 (32)	732.00	67.00	18.87	85.87	19/12/16
6 (29)	665.00	67.00	15.53	82.53	17/01/17
7 (31)	598.00	67.00	14.93	81.93	17/02/17
8 (28)	531.00	67.00	11.98	78.98	17/03/17
9 (31)	464.00	67.00	11.59	78.59	17/04/17
10 (30)	397.00	67.00	9.59	76.59	17/05/17
11 (33)	330.00	67.00	8.77	75.77	19/06/17
12 (28)	263.00	67.00	5.93	72.93	17/07/17
13 (31)	196.00	67.00	4.89	71.89	17/08/17
14 (32)	129.00	67.00	3.33	70.33	18/09/17
15 (29)	62.00	62.00	1.45	63.45	17/10/17
សរុប		**1,000.00**	**210.61**	**1,210.61**	

ក្រោយពីបានអាន និងស្តាប់នូវរាល់ខ្លឹមសារនៃកិច្ចសន្យាខ្ចីបរិភោគលេខ ICLA1617467039 ចុះថ្ងៃទី 29 ខែ មិថុនា ឆ្នាំ 2016 ខ្ញុំបាទ/នាងខ្ញុំ ឯកភាពសងប្រាក់ទៅតាមចំនួនដែលបានកំណត់ក្នុងតារាងសងប្រាក់នេះ រហូតគ្រប់ចំនួន តាមរយៈគណនីរឹករាយ/គណនីសម្រួលប្រតិបត្តិការលេខ 1044656 ។

ចំណាំ: ក្នុងករណីមានប្រធានសំណើមួយកើតឡើង អតិថិជនអាចទំនាក់ទំនង និងពិភាក្សាជាមួយមន្ត្រីឥណទានដើម្បីស្វែងរកដំណោះស្រាយសមរម្យណាមួយ។

ថ្ងៃទី 29 ខែ 06 ឆ្នាំ 2016

ហត្ថលេខាមន្ត្រីឥណទាន ឬហេរញ្ញិកសាខា

ស្នាមមេដៃស្តាំ អតិថិជន

កែប ឡុក

ពាក្យស្នើសុំខ្ចីប្រាក់ឥណទានក្រុម

Group Loan Request Form

សាខា		ឈ្មោះបេឡា/ភូមិ		វគ្គទី	

ព័ត៌មានសមាជិក

ល.រ	ឈ្មោះអ្នកខ្ចី	ឈ្មោះអ្នករួមខ្ចី	ចំនួនទឹកប្រាក់ស្នើសុំខ្ចី	ប្រភេទរូបិយប័ណ្ណក្នុងក្រុម	រយៈពេលស្នើខ្ចី
១				☐ ប្រាក់រៀល ☐ ប្រាក់ថៃបាត ☐ ប្រាក់ដុល្លារ	ចំនួន .....ខែ
២					
៣					
៤					
៥					
៦					
ចំនួនទឹកប្រាក់សរុប ស្នើសុំខ្ចីក្នុងក្រុម					

ផែនទីអាសយដ្ឋានបច្ចុប្បន្ន របស់ប្រធានក្រុម (ករណីក្រៅបេឡាឥណទានភូមិ សម្រាប់ឥណទានក្រុមឯករាជ្យ)

ដោយយោងទៅតាម ប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន របស់ធនាគារជាតិ នៃកម្ពុជា លេខ ធ៧-០១១-១៤៥ ប្រ.ក។ យើងខ្ញុំទាំងអស់គ្នាជា អតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត យល់ព្រមបង្ហាញព័ត៌មានរបស់យើងខ្ញុំទៅដល់ការិយាល័យឥណទាន ដើម្បីអនុលោមទៅតាមច្បាប់នេះតាមប្រការទាំងពីរខាងក្រោម:

